# សំណួរដែលត្រូវបានគេសួរញឹកញាប់
# ស្តីអំពី
# ការចាត់ចែងរក្សាការពារ

បោះពុម្ពនៅខែ ឧសភា ឆ្នាំ ២០០៩

# អារម្ភកថា

ចាប់តាំងពីពេលដែលចាប់ផ្តើមអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណីនៅក្នុងខែ កក្កដា ឆ្នាំ ២០០៧ មក កម្មវិធីរបស់យើង (កម្មវិធីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលផ្នែករដ្ឋប្បវេណីនៅសាលាភូមិន្ទចៅក្រម) បានទទួលនូវសំណួរជាច្រើនទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ពីបណ្តាលចៅក្រម និង ព្រះរាជអាជ្ញា ហើយក៏បានឆ្លើយនូវរាល់បណ្តាសំណួរទាំងអស់នោះដែរ ។

ហើយយើងគិតថា រាល់បណ្តាសំណួរ និង ចម្លើយទាំងអស់នោះ គឺជាពត៌មានដែលមានប្រយោជន៍សំរាប់អ្នកដែលកំពុងដោះស្រាយរឿងក្តីក្នុងការអនុវត្ត ។ ដូច្នេះហើយ កម្មវិធីរបស់យើង ក៏បានប្រមូល និង រៀបចំ សំណួរចំលើយទាក់ទងនឹងនីតិវិធីនៃការចាត់ចែងរក្សាការពារ ហើយក៏បង្កើតសៀវភៅ " សំណួរដែលត្រូវបានគេសួរញឹកញាប់ស្តីអំពីការចាត់ចែងរក្សាការពារ " នេះឡើង ដោយមានការជួយគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ។

***សំគាល់ : រាល់បណ្តាចំលើយនៅក្នុង សំណួរដែលត្រូវបានគេសួរញឹកញាប់នេះ ត្រូវបានបង្កើតឡើងដោយកម្មវិធីរបស់យើង ហើយក្រសួងយុត្តិធម៌ ឬ អាជ្ញាធរដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនទាន់អនុញ្ញាតឱ្យជាផ្លូវការ នៅឡើយទេ ។***

" សំណួរដែលត្រូវបានគេសួរញឹកញាប់ស្តីអំពីការចាត់ចែងរក្សាការពារ " នេះ ត្រូវបានបោះពុម្ពនៅក្នុង ខែ ឧសភា ឆ្នាំ ២០០៩ ។

# មាតិកា

## ជំពូកទី ១ បញ្ញាទូទៅ

១- ចូរផ្តល់ឧទាហរណ៏អំពី “ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ” ?

២- សូមផ្តល់ឧទាហរណ៏អំពី “ ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ” ?

៣- តើការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន មានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ? តើការចាត់ចែងជាបណ្តោះអាសន្ន ហាមឃាត់ការផ្ទេរកម្មសិទ្ធិ និងការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការសាងសង់ស្ថិតក្នុងប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្នមួយណា?

៤- តើការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និងការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ មានចំណុចដូចគ្នា និងខុសគ្នាអ្វីខ្លះ?

៥- រឿងក្តីព្រហ្មទណ្ឌមួយ មានបទល្មើសព្រហ្មទណ្ឌ និង សំណងរដ្ឋប្បវេណី ។

(១) -ដើម្បីរក្សាវត្ថុមានទ្រព្យសម្បត្តិរបស់ជនសង្ស័យ តើជនរងគ្រោះអាចដាក់ពាក្យសុំឱ្យតុលាការចេញដីកាសំរេចរក្សាការពារបានដែរឬទេ?

(២) -តើរឿងព្រហ្មទណ្ឌខាងលើនេះ គេចាត់ទុកថាជាបណ្តឹងអង្គសេចក្តីបានដែរឬទេ ក្នុងរឿងរដ្ឋប្បវេណី (ម. ៥៥៧) ?

## ជំពូកទី ២ ពាក្យសុំ

៦- ក្នុងករណីឈ្មោះ និង អាសយដ្ឋានរបស់កូនបំណុលមិនបានកំណត់ច្បាស់ក្នុងពាក្យសុំដីកាសម្រេចរក្សាការពារ (ឧទាហរណ៏ ក្នុងករណីពាក្យសុំការរក្សាការពារហាមឃាត់ការសាងសង់ ឬហាមឃាត់បិទផ្លូវ គេមិនដឹងតើនរណាជាអ្នកសាងសង់ ឬនរណាជាអ្នកបិទផ្លូវ) តើតុលាការចាត់ការចំពោះពាក្យសុំនេះដោយវិធីណា?

៧- ១- ក្នុងករណីពាក្យសុំដីកាសំរេចការចាត់ចែងជាបណ្តោះអាសន្ន ត្រូវគេលើកចោល តើគេអនុញ្ញាតឱ្យដាក់ពាក្យសុំការរក្សាការពារមួយទៀតបានដែរឬទេនៅក្នុងរឿងដដែលនោះ?

២- ក្នុងករណីពាក្យសុំដីកាសំរេចរក្សាការពារ ត្រូវបានគេទទួលស្គាល់ ប៉ុន្តែការអនុវត្តមិនអាចធ្វើបានដោយសារពេលវេលាពីរសប្តាហ៏បានកន្លងផុត-ដែលជាអាជ្ញាយុកាលការរក្សាការពារចែងក្នុងមាត្រា ៥៦២-២ តើគេអនុញ្ញាតឱ្យដាក់ពាក្យសុំការរក្សាការពារមួយទៀតបានដែរឬទេនៅក្នុងរឿងដដែលនោះ?

៨- តើការបញ្ជូនពាក្យសុំដីកាសំរេចរក្សាការពារដល់កូនបំណុល មានលក្ខណៈចាំបាច់ដែរឬទេ?

៩- ប្រសិនបើបណ្តឹងអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តើម្ចាស់បំណុលអាចដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅតុលាការនៃការជំនុំជំរះលើកទី ១ ដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទបានដែរឬទេ?

១០- ប្រសិនបើបណ្តឹងអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីបណ្តឹងសាទុក្ខ តើម្ចាស់បំណុលអាចដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅសាលាឧទ្ធរណ៍បានដែរឬទេ?

## ជំពូកទី ៣ ការវិនិច្ឆ័យ

១១- តើក្រុមប្រឹក្សាជំនុំជម្រះអាចចាត់ការរឿងក្តីចាត់ចែងរក្សាការពារបានដែរឬទេ?

១២- ក្នុងករណីមានការដាក់ពាក្យសុំដីកាសំរេចចាត់ចែងរក្សាការពារ ហើយបណ្តឹងអង្គសេចក្តីកំពុងតែចាត់ការ តើចៅក្រមដែលជំរះក្តីបណ្តឹងអង្គសេចក្តី អាចទទួលបន្ទុកលើរឿងចាត់ចែងការរក្សាការពារបន្ថែម ទៀតបានដែរឬទេ?

១៣- សូមផ្តល់ឧទាហរណ៍ "ករណីដែលមានស្ថានភាពពិសេស" ( មាត្រា ៥៤៨ កថាខណ្ឌ ទី ៤ វាក្យខណ្ឌ) គេអាចចេញដីកាចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នដោយមិនចាំបាច់រៀបចំនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬសាកសួរទេ។

១៤- តើអាចសួរតតិយជនដែលជាជនក្រៅពីភាគីបានដែរឬទេ ក្នុងការវិនិច្ឆ័យលើពាក្យសុំដីកាសំរេចចាត់ចែងរក្សាការពារ ឬក្នុងការវិនិច្ឆ័យបណ្តឹងតវ៉ាចំពោះការចាត់ចែងរក្សាការពារ?

## ជំពូកទី ៤ ប្រាតិភោគ

១៥- សូមផ្តល់ឧទាហរណ៍គំរូក្នុងករណីតុលាការចេញដីកាចាត់ចែងរក្សាការពារ ដោយមិនបង្គាប់ឱ្យដាក់ប្រាតិភោគ?

១៦- តើវាជាការចាំបាច់ទេ ក្នុងការបញ្ជូនដីកាទាក់ទងនឹងការដាក់ប្រាតិភោគទៅកាន់កូនបំណុល ឬក្នុងការជូនដំណឹងកូនបំណុលអំពីដីកានោះ?

១៧- ក្នុងករណីម្ចាស់បំណុលចាញ់ក្តីនៅក្នុងបណ្តឹងអង្គសេចក្តី ក្រោយពេលតុលាការបានចេញ និងអនុវត្តដីកាចាត់ចែងរក្សាការពាររួចហើយ តើការខូចខាតដែលកើតមានចំពោះកូនបំណុល តាមរយៈការចាត់ចែងរក្សាការពារនេះ ត្រូវសងវិញដោយវិធីណា?

១៨- តើតុលាការគួរធ្វើដូចម្តេច នៅពេលតុលាការបានចេញដីកាសំរេចដោយមិនទាមទារឱ្យដាក់ប្រាតិភោគ និងការខូចខាតបានកើតឡើងចំពោះកូនបំណុល? សូមពន្យល់អំពីភាពខុសគ្នារវាងការដាក់តម្កល់ប្រាតិភោគ និងការមិនដាក់តម្កល់ប្រាតិភោគ?

## ជំពូកទី ៥ ដីកាសម្រេច

១៩- ប្រសិនបើកម្មវត្ថុនៃការចាត់ចែងរក្សាការពារ ត្រូវបានគេចាត់ចែងហើយ តើតុលាការអាចចេញដីកាសំរេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងនោះបានដែរឬទេ?

២០- ទ្រព្យសម្បត្តិរបស់កូនបំណុល ស្ថិតក្រោមហ៊ីប៉ូតែកៈ

(១) តើតុលាការអាចចេញដីកាសំរេចរឹបអូសជាបណ្តោះអាសន្នបានដែរឬទេចំពោះទ្រព្យសម្បត្តិ ដូចខាងលើនេះ? តើមាននីតិវិធីអ្វីក្នុងការអនុវត្តនូវដីកាសំរេចរឹបអូសជាបណ្តោះអាសន្ន?

(២) ប្រសិនបើគេគណនានូវទ្រព្យសម្បត្តិរបស់កូនបំណុល ហើយឃើញថា មិនមានសល់ទ្រព្យអ្វីសោះ តើតុលាការអាចចេញដីកាសំរេចចាត់ចែងរក្សាការពារបានដែរឬទេ?

២១- តើគេអាចកំណត់នូវទឹកប្រាក់រំដោះពីការចាត់ចែងជាបណ្តោះអាសន្ន ដូចគ្នានឹងទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នបានដែរឬទេ?

២២- តើដីកាសំរេចចាត់ចែងរក្សាការពារគួរចែងអំពីបន្ទុកនៃសោហ៊ុយសំរាប់នីតិវិធីដែរឬទេ?

២៣- តើចាំបាច់ត្រូវតែបញ្ជូន ឬជូនដំណឹងដល់កូនបំណុលអំពីសេចក្តីសំរេចលើកចោលពាក្យសុំចាត់ចែងរក្សាការពារ ឬសេចក្តីសំរេចលើកចោលបណ្តឹងជំទាស់នឹងសេចក្តីសំរេចនេះដែរឬទេ?

២៤- តុលាការបានចេញដីកាសំរេចទទួលស្គាល់នូវពាក្យសុំ ហើយលើកចោលផ្នែកដែលនូវសេសសល់ ។ តើតុលាការគួរបញ្ជូនដីកាសំរេចនេះដែរឬទេ?

២៥- ក្នុងករណីចៅក្រមបានចេញដីកាសំរេចចាត់ចែងរក្សាការពារ ហើយក្រោយមកទៀតទើបរកឃើញកំហុសក្នុងសំរេចចិត្ត តើចៅក្រមអាចលុបចោល ឬកែប្រែដីកាសំរេចនោះ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនបានដែរឬទេ?

## ជំពូកទី ៦ ការតវ៉ា ការលុបចោល ជាអាទិ៍

២៦- នៅពេលដែលពាក្យតវ៉ាចំពោះការចាត់ចែងរក្សាការពារត្រូវបានដាក់មក តើចៅក្រមរូបណាទទួលបន្ទុកជំរះក្តីជាចៅក្រមដែលចេញដីកាសំរេចមុនដំបូងគេ ឬចៅក្រមផ្សេងទៀត?

២៧- ទាក់ទងនឹងការដាក់ពាក្យសុំការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ប្រសិនបើតុលាការចេញដីកាសំរេចក្រោយពេលសាកសួរ (ម.៥៤៨-៤) ហើយបន្ទាប់មកទៀតមានពាក្យសុំតវ៉ាចំពោះដីកាសំរេចនេះ ក្នុងករណីនេះតើចាំបាច់ត្រូវរៀបចំការសាកសួរម្តងទៀតដែរឬទេក្នុងពេលតវ៉ានេះ (ម.៥៥២)?

២៨- តើត្រូវសរសេរខ្លឹមសារសំខាន់នៃដីកាសំរេចអំពីពាក្យសុំតវ៉ាចំពោះការចាត់ចែងរក្សាការពារដោយរបៀបណា?

២៩- សូមពន្យល់ខ្លឹមសារនៃមាត្រា ៥៥៧ (ការលុបចោលដីកាសំរេចរក្សាការពារដោយសារមិនបានដាក់ពាក្យ

បណ្តឹងអង្គសេចក្តី ជាអាទិ៍) កថាខណ្ឌទី ២ ដែលចែងថា " អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ខាងលើ នេះត្រូវ មានរយៈពេលមិនតិចជាង ២ សប្តាហ៍។" តើនៅប្រទេសជប៉ុន ការអនុវត្តជាក់ស្តែងចំពោះមាត្រានេះយ៉ាង ដូចម្តេចដែរ?

៣០- តើ " សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ " ក្នុងដីកាសំរេចរក្សាការពារចាំបាច់ត្រូវដូចគ្នានឹង " សិទ្ធិ ឬទំនាក់ទំនងគតិយុត្តទាមទារ " នៅក្នុងបណ្តឹងអង្គសេចក្តីដែរឬទេ?

៣១- ក្រោយពេលដីកាសំរេចអំពីការចាត់ចែងរក្សាការពារបានចេញ ទាក់ទងនឹងវិវាទដីធ្លី កូនបំណុលដាក់ពាក្យសុំ " លុបចោលដីកាសំរេចចាត់ចែងរក្សាការពារ ដោយហេតុថា ម្ចាស់បំណុលមិនបានដាក់បណ្តឹងអង្គសេចក្តី" ( ម. ៥៥៧) ហើយបន្ទាប់មកម្ចាស់បំណុលដាក់ពាក្យសុំសំរបសំរួល ឬសុំសេចក្តីសំរេចពីភ្នាក់ងាររដ្ឋបាល (ដូចជា គណៈកម្មការសុរិយោដី ជាអាទិ៍) ក្នុងករណីនេះ តើពាក្យសុំរបស់ម្ចាស់បំណុលអាចចាត់ទុកថាជាករណីបណ្តឹងអង្គសេចក្តីបានដែរឬទេ?

៣២- ករណីកូនបំណុលដាក់ពាក្យសុំតវ៉ាចំពោះដីកាសំរេចចាត់ចែងរក្សាការពារ តើការអនុវត្តការចាត់ចែងរក្សាការពារដែលកំពុងប្រព្រឹត្តទៅត្រូវផ្អាកដែរឬទេ?

៣៣- ក្នុងករណីដែលសេចក្តីសំរេចត្រូវបានធ្វើឡើងដោយទទួលស្គាល់ដីកាសំរេចចាត់ចែងរក្សាការពារ ប្រឆាំងចំពោះពាក្យសំតវ៉ានឹងដីកាសំរេចនេះ ហើយកូនបំណុលធ្វើបណ្តឹងជំទាស់ចំពោះសេចក្តីសំរេចនេះ តើការអនុវត្តដីកាសំរេចចាត់ចែងរក្សាការពារដែលកំពុងប្រព្រឹត្តទៅត្រូវផ្អាកដែរឬទេ?

៣៤- សូមផ្តល់ករណីគំរូអំពី " បើយល់ឃើញថាចាំបាច់ពិសេស " ក្នុងមាត្រា ៥៥៦ វាក្យខណ្ឌ។

## ជំពូកទី ៧ ការអនុវត្ត

៣៥- តើមានករណីណាខ្លះដែលយើងអាចធ្វើដីកាសំរេចចាត់ចែងរក្សាការពារ និងដីកាសំរេចអនុវត្តនៃដីកាសំរេចចាត់ចែងរក្សាការពារនោះ ដោយតាមរយៈពាក្យសុំតែមួយ ? ឧទាហរណ៍ តើគេអាចសុំដីកាសំរេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និងការអនុវត្តដីកាសំរេចនោះដោយគ្រាន់តែធ្វើពាក្យសុំតែមួយបានដែរឬទេ?

៣៦- ដីរបស់កូនបំណុលមិនបានចុះបញ្ជី បើសិនជាតុលាការចេញដីកាបង្គាប់ចាត់ចែងរក្សាការពារ តើតុលាការត្រូវធ្វើដូចម្តេច?

៣៧- ១-តើការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើដោយរបៀបណា?

២-នៅពេលអចលនវត្ថុ ត្រូវគេរឹបអូសជាបណ្តោះអាសន្ន តើត្រូវបង្ខំកូនបំណុលឱ្យចាកចេញពីអចលនវត្ថុនោះដែរឬទេ? ឬ កូនបំណុលអាចជួលទ្រព្យសម្បត្តិនោះបានដែរឬទេ?

៣-តើការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមានអានុភាពអ្វីខ្លះ?

៣៨- ហេតុអ្វីបានជា ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ជារឿងចាំបាច់? តើអានុភាពនៃការអនុវត្តរបស់វាមានអ្វីខ្លះ?

៣៩- ១- តើគេអនុវត្តការរឹបអូសជាបណ្ដោះអាសន្នលើចលនវត្ថុដោយវិធីណា?

២-ក្នុងករណីចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានផ្ទេរ និងប្រគល់ដល់តតិយជនហើយ តើមានវិធានការតតាំងណាខ្លះដែលយើងអាចធ្វើបាន?

៤០- តើគេអនុវត្តដីកាសំរេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ដោយមិនកំណត់ជាក់លាក់នូវកម្មវត្ថុរឹបអូសនោះដោយវិធីណា (ម.៥៤៦)? ក្នុងករណីនេះ តើមានការរឹតត្បិតអ្វីខ្លះចំពោះកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ននោះ?

៤១- តើគេអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់មិនឱ្យធ្វើសកម្មភាពណាមួយដោយវិធីណា? ឧទាហរណ៍ តើគេអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នក្នុងការហាមឃាត់ ដូចជា ១-ការសាងសង់ និង ២- សំលេងរំខាន ដោយវិធីណា?

៤២- ក្នុងករណីដីកាសំរេចចាត់ចែងរក្សាការពារត្រូវគេលុបចោលក្រោយពេលអនុវត្ត (ដោយសារការតវ៉ាចំពោះដីកា ការលុបចោលការចាត់ចែងរក្សាការពារ ការបង់ប្រាក់រំដោះរឹបអូសជាបណ្ដោះអាសន្ន ។ល។) តើត្រូវចាត់នីតិវិធីអ្វីខ្លះ?

## ជំពូកទី ៨ ផ្សេងៗ

៤៣- ក្រោយពេលតុលាការចេញដីកាសំរេចរឹបអូសជាបណ្ដោះអាសន្នទាក់ទងនឹងកម្មវត្ថុ ហើយតតិយជន X ម្នាក់ បានបង្ហាញខ្លួនដោយអះអាងអំពីកម្មសិទ្ធិរបស់គាត់លើកម្មវត្ថុនោះ តើតតិយជនរូបនោះ អាចចាត់វិធានការដូចម្ដេចខ្លះ ដើម្បីដកអានុភាពនៃការរឹបអូសជាបណ្ដោះអាសន្ន?

៤៤- សូមពន្យល់ នៅពេលប្រាក់រំដោះបានបង់ហើយ តើយើងគិតដូចម្ដេចចំពោះការផ្អាកការអនុវត្ត?

## សេចក្ដីបន្ថែម

១- ប្រភេទនៃការចាត់ចែងរក្សាការពារ

២- ប្រាតិភោគ និង ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

៣- បណ្ដឹងតវ៉ា និង បណ្ដឹងជំទាស់ ជាអាទិ៍

៤- លំហូរនីតិវិធីនៃពាក្យសុំឧបាស្រ័យចំពោះការចាត់ចែងរក្សាការពារ

| | |
|---|---|
| ១- | ចូរផ្តល់ឧទាហរណ៍អំពី" ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ"? |

១- ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានន័យថាជា "ការចាត់ចែងដើម្បីរក្សានូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២- នៅក្នុងច្បាប់នៅប្រទេសជប៉ុន ស្តីអំពីការរក្សាការពារផ្នែករដ្ឋប្បវេណី (មាត្រាផ្សេង១ដែលគេដកស្រង់ទាក់ទងនឹងសំណួរនេះ គឺសំដៅលើច្បាប់នេះ) "ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់នូវការចាត់ចែង" និង "ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់" គឺជាប្រភេទពីរយ៉ាងនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ" ។ ខ្លឹមសារចំបងនៃប្រភេទចាត់ចែងបណ្តោះអាសន្នទាំងនេះមានលើកឡើងដូចខាងក្រោមដើម្បីធ្វើជាឯកសារយោង :

១. ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង (ករណីសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារការចុះបញ្ជី)

ក- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងលើអចលវត្ថុ-ប្រភេទទី១ (ដើម្បីធានាសិទ្ធិទាមទារការចុះបញ្ជីការផ្ទេរកម្មសិទ្ធិនៃអចលវត្ថុ, ម.៥៣(១), ម.៥៨(១)និង(២) :

ប្រភេទរក្សាការពារនេះ ត្រូវអនុវត្តដោយ "ធ្វើការចុះបញ្ជីការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង "នៅក្នុងសៀវភៅចុះបញ្ជី ។

ក្នុងករណីម្ចាស់បំណុលឈ្នះក្តីក្នុងបណ្តឹងអង្គសេចក្តី ការចុះបញ្ជីដែលធ្វើក្រោយ "ការចុះបញ្ជីចាត់ចែង បណ្តោះអាសន្នហាមឃាត់ការចែងចែង" ហើយវាមានវិវាទជាមួយនឹងកម្មសិទ្ធិរបស់ម្ចាស់បំណុល អាចត្រូវគេលុប ចោល ។

ខ- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងអចលវត្ថុ-ប្រភេទទី២ (ដើម្បីធានាសិទ្ធិទាមទារការចុះបញ្ជីលើសិទ្ធិ ក្រៅពីកម្មសិទ្ធិ(ឧទាហរណ៍ ការចុះបញ្ជីលើការបង្កើត

ហ៊ីប៉ូតែក ឬសិទ្ធិជួលអចិន្ត្រៃយ៍, ម.៩៣(១)និង (២), ម. ៩៨(១)ដល់(៤)): ការរក្សាការពារប្រភេទនេះ ត្រូវអនុវត្តដោយ "ការចុះបញ្ជីការ ចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែង" និង ក្នុងពេលជាមួយគ្នានឹងការ "ចុះបញ្ជីការរក្សាការពារជាបណ្ដោះអាសន្ន"(ឧទាហរណ៍ ការចុះបញ្ជីបណ្ដោះអាសន្នលើការបង្កើតហ៊ីប៉ូតែក ឬសិទ្ធិជួលអចិន្ត្រៃយ៍)ក្នុងបញ្ជី ។

ក្នុងករណីម្ចាស់បំណុលឈ្នះក្ដីក្នុងបណ្ដឹងអង្គសេចក្ដី ការចុះបញ្ជីដែលធ្វើក្រោយ "ការចុះបញ្ជីការចាត់ចែង ជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែង" ហើយវាមានវិវាទនឹងសិទ្ធិរបស់ម្ចាស់បំណុល (ឧទាហរណ៍ សិទ្ធិជួល អចិន្ត្រៃយ៍) អាចត្រូវគេលុបចោល ។

លើសពីនេះទៀត "ការចុះបញ្ជីបណ្ដោះអាសន្នលើការរក្សាការពារ" ត្រូវច្បាស់លាស់ ។ សិទ្ធិដែលគេចុះមុន តាមរបៀបនេះ(ឧទាហរណ៍ ហ៊ីប៉ូតែក, សិទ្ធិជួលអចិន្ត្រៃយ៍ ។ល។) អាចតតាំងនឹងម្ចាស់ថ្មី ឬម្ចាស់បំណុលហ៊ីប៉ូតែក ដែលបង្ហាញខ្លួនក្រោយការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នខាងលើនេះ ។

គ- ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងវត្ថុដែលអាចចុះបញ្ជី(ម.៥៤,ម.៦១)

ទាក់ទងនឹងវត្ថុ ក្រៅពីអចលនវត្ថុដែលអាចចុះបញ្ជីបាន(ឡាន កប៉ាល់ យន្តហោះ ។ល។) បញ្ញត្តិនៃចំណុច ក និង ខ ខាងលើនឹងអនុវត្តដូចគ្នា ហើយគេអាចបង្កើតការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការ ចាត់ចែង ដែលជាប្រភេទដូចគ្នាបាន ។

២. ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ (ករណីសិទ្ធិដែលត្រូវរក្សាការពារជាសិទ្ធិ ទាមទារប្រគល់វត្ថុ)

ដើម្បីធានានូវសិទ្ធិទាមទារប្រគល់វត្ថុ គេត្រូវធ្វើការចាត់ចែងជាបណ្ដោះអាសន្នតាមរយៈ ÷ ទី១ ហាម ឃាត់កូនបំណុលមិនឱ្យផ្ទេរការកាន់កាប់កម្មវត្ថុដែលមានវិវាទ ។ ទី២ បង្គាប់ឱ្យកូនបំណុលបោះបង់ការកាន់កាប់ កម្មវត្ថុដែលមានវិវាទ ហើយប្រគល់វាទៅឱ្យសាលាអាជ្ញា ។ ទី ៣ បង្គាប់ឱ្យសាលាអាជ្ញារក្សាទុកនូវកម្មវត្ថុនោះ ដោយគ្រប់គ្រងដោយខ្លួនឯង ។ ទី៤ បង្គាប់ឱ្យអាជ្ញាសាលា បិទប្រកាសជាសាធារណៈនូវចំណុច ១ និង ៣ ខាងលើ (មាត្រា២៥(៣)) ។

នៅពេលការកាន់កាប់ បានផ្ទេរទៅឱ្យតតិយជន ក្រោយពេលអនុវត្តនូវការចាត់ចែងជាបណ្តោះអាសន្ន ក្នុង ករណីភាគច្រើន តតិយជននោះមិនតតាំងជាមួយនឹងម្ចាស់បំណុលទេ ( ម.៦២) ។

៣- ទិសដៅអនុវត្តនៅកម្ពុជា

ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា មានចែងនូវបញ្ញត្តិដែលមានអានុភាពដូចគ្នានឹងចំណុច ២(២) ខាងលើ ស្តីពីការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ ( ម.៥៧១) ហើយគេចាត់ទុកថាការអនុវត្តនៅប្រទេសជប៉ុន ត្រូវគេយកមកប្រើដូចគ្នា ។

ម្យ៉ាងវិញទៀត បញ្ញត្តិអំពីការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង ដែលមិនមានចែងក្នុងក្រម ក៏មានសារប្រយោជន៍ផងដែរ ។ ខ្លឹមសារនៃបទបញ្ជាដែលត្រូវចេញក្នុងដីការចាត់ចែងជាបណ្តោះអាសន្នបែប នេះ វិធីសាស្ត្រអនុវត្ត និង អានុភាពរបស់វា គួរតែចែងឱ្យស្របតាមការអនុវត្តជាក់ស្តែង ក្នុងពេលអនាគត ហើយ ឧទាហរណ៍គំរូរបស់ប្រទេសជប៉ុន អាចយកមកធ្វើជាឯកសារពិគ្រោះបាន ។

២- សូមផ្តល់ឧទាហរណ៍អំពី "ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន"

១-ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន គឺជាការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាង ការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតមានឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តិដែលមានវិវាទ ( មាត្រា ៥៣១ ចំណុច គ) ។

ខណៈពេលដែលប្រភេទនៃការចាត់ចែងរក្សាការពារទី ១.ការរឹបអូសជាបណ្តោះអាសន្ន និងទី ២.ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺមានការកំណត់ច្បាស់លាស់ ប្រភេទនៃការចាត់ចែងរក្សាការពារទី ៣. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គល ជាបណ្តោះអាសន្នមានច្រើនយ៉ាង ហើយមិនមានការកំណត់ច្បាស់ទេ (ឬប្រភេទទី ៣.នេះរួមបញ្ចូលប្រភេទទាំងអស់នៃការចាត់ចែងជាបណ្តោះអាសន្នលើកលែងប្រភេទ ១. និង ២.ចេញ) ។

២. ឧទាហរណ៍ខាងក្រោមអំពីការចាត់ចែងជាបណ្តោះអាសន្ន ច្រើននិយមឃើញនៅក្នុងប្រទេសជប៉ុន

(១) ការបង់ប្រាក់ជាបណ្តោះអាសន្ន

ក. ឧទាហរណ៍ នៅពេលបុគ្គលិកម្នាក់ប្តឹងចៅហ្វាយរបស់ខ្លួនអំពីការបញ្ឈប់ការងារដោយអយុត្តិធម៌ បុគ្គលិកនោះទាមទារការបង់ប្រាក់ខែជាបណ្តោះអាសន្ន ដោយសារភាពលំបាកខាងជីវភាពរបស់គាត់ មុនពេលសាលក្រមនៃបណ្តឹងអង្គសេចក្តីចេញ ។

ខ. ឧទាហរណ៍ នៅពេលជនរងគ្រោះ ដោយគ្រោះថ្នាក់ចរាចរណ៍ម្នាក់ធ្វើពាក្យបណ្តឹងចំពោះជនប្រព្រឹត្តិខុស ជនរងគ្រោះនោះ ទាមទារការបង់ប្រាក់ជាបណ្តោះអាសន្នដែលជាផ្នែកមួយនៃសំណងជំងឺចិត្តដោយសារភាពលំបាកខាងជីវភាពរបស់គាត់ មុនពេលសាលក្រមនៃបណ្តឹងអង្គសេចក្តីចេញ ។

(២) ការហាមឃាត់ការសាងសង់អាគារ

ឧទាហរណ៍ នៅពេលកូនបំណុលម្នាក់ចាប់ផ្តើមការសាងសង់អាគារលើដីមួយកន្លែងដោយមិនមានសិទ្ធិអនុញ្ញាត ហើយកម្មសិទ្ធិនៃដីនោះជារបស់ម្ចាស់បំណុល ម្ចាស់បំណុលនោះទាមទារការផ្អាកការសាងសង់ដោយផ្អែកលើកម្មសិទ្ធិរបស់គាត់ ។

(៣) ការបណ្តេញចេញដោយបង្ខំ

ឧទាហរណ៍ នៅពេលរថយន្តមួយបានចតលើកន្លែងចតរបស់ភោជនីយដ្ឋានមួយកន្លែងអស់រយៈពេលច្រើនសប្តាហ៍ ម្ចាស់ភោជនីយដ្ឋាននោះទាមទារការយកឡានចេញជាបន្ទាន់ ដោយសារវាមានផលប៉ះពាល់អវិជ្ជមានលើមុខជំនួញរបស់គាត់ ។

(៤) ការហាមឃាត់នូវការបិទផ្លូវចេញចូល

នៅពេលមានវិវាទកើតឡើងរវាងអ្នកជិតខាងអំពីសិទ្ធិចេញចូល ហើយមានអ្នកជិតខាងម្នាក់បិទច្រកមិនអោយអ្នកជិតខាងម្នាក់ទៀតចេញចូលបានដោយសាងសង់របងបិទ អ្នកជិតខាងនោះទាមទារអោយរុះរើរបងនោះចេញ ។

(៥) ការហាមឃាត់សំលេងរំខាន

(៦) ការហាមឃាត់មិនអោយជួបជនណាម្នាក់

វិធានការទប់ស្កាត់ចំពោះការប្រមូលបំណុលដោយកំរោលដោយជនអ្នកលែងម្នាក់ ។ វិធានការទប់ស្កាត់ចំពោះដៃគូទំនាក់ទំនងស្នេហាដែលមានបញ្ហាជំពាក់ជំពិន ដែលបង្ខំចង់ជួបគ្នា ។

(៧) បញ្ជាហាមមិនអោយបោះពុម្ពផ្សាយ

៣- តើការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន មានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ? តើការចាត់ចែងជាបណ្តោះអាសន្ន ហាមឃាត់ការផ្ទេរកម្មសិទ្ធិ និងការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការសាងសង់ស្ថិតក្នុងប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្នមួយណា?

១- និយមន័យ

ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុមានវិវាទ មានន័យថា "ជាការចាត់ចែងដើម្បីរក្សានូវស្ថានភាពដើមនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិដោយសារការប្រែប្រួល ស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ (ម.៥៣១(២)) ។

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន មានន័យថា "ជាការចាត់ចែងដែល កំណត់នូវស្ថានភាពជាបណ្តោះអាសន្ន រហូតដល់ពេលសាលក្រមចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ " (ម. ៥៣១(៣)) ។

២- ភាពខុសគ្នា

ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានគោលបំណងរក្សាស្ថានភាពដើមនៃកម្មវត្ថុនោះ ដើម្បីធានានូវការប្រើប្រាស់សិទ្ធិតាមរយៈការអនុវត្តដោយបង្ខំនៅពេលអនាគត ចំណែកឯការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្តោះអាសន្ន មានគោលបំណង បំបាត់ចោលជាបណ្តោះអាសន្ននូវហានិភ័យដែលកើតមានឡើងចំពោះម្ចាស់បំណុល ឬស្ថានភាពអស្ថេរភាពដែលបង្កដោយវិវាទលើសិទ្ធិរបស់គាត់ ប៉ុន្តែមិនមែនដើម្បីធានានូវការប្រើប្រាស់សិទ្ធិនៅពេលអនាគតនោះទេ ។

បើពិនិត្យមើលអំពីភាពខុសគ្នាខាងនីតិវិធីវិញ ការកាត់ក្តីរឿងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុ ដែលជាកម្មវត្ថុនៃវិវាទនេះ គឺត្រូវធ្វើឱ្យបានលឿន ហើយក្នុងករណីជាច្រើន គេចេញដីកាបានដោយគ្រាន់តែស្តាប់ការអះអាងរបស់ម្ចាស់បំណុលដោយមិនចាំបាច់សាកសួរកូនបំណុលឡើយ។ (ម.៥៣៩,ម.១១៤(១)និង(២)

ចំណែកឯ សវនាការអំពីការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈបុគ្គលជាបណ្ដោះអាសន្នវិញត្រូវចំណាយពេលវែងជាង ហើយជាគោលការត្រូវសាកសួរកូនបំណុល ( ម.៥៤៨(៤) ) ។

ភាពខុសគ្នានេះ គឺដោយសារថាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ទាមទារនូវការសំងាត់ ក្នុងគោលបំណងរក្សាស្ថានភាពដើមនៃវត្ថុជាកម្មវត្ថុនៃវិវាទ ចំណែកឯការ ចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គឺវាជះឥទ្ធិពលខ្លាំងដល់កូនបំណុល ក្នុងការបំពេញទៅតាមការទាមទាររបស់ម្ចាស់បំណុល ។

៣. ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ អាចចាត់ទុកជាឧទាហរណ៍មួយអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយសារវាហាមឃាត់កូនបំណុលមិនឱ្យធ្វើការផ្ទេរការកាន់កាប់កម្មវត្ថុនោះទៅឱ្យតតិយជនផ្សេងទៀត ដើម្បីធានានូវការអនុវត្តការទាមទារប្រគល់វត្ថុរបស់ម្ចាស់បំណុលនៅពេលអនាគត ។

ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការសាងសង់ គឺទាក់ទងនឹងអគារដែលត្រូវធ្វើការសាងសង់ ឬ អគារដែលកំពុងតែសាងសង់ ។ ប្រវត្តិរបស់វា អាចបង្កើតនូវចំណងគតិយុត្តផ្សេងៗ ដូចជាវិវាទអំពីសិទ្ធិប្រើប្រាស់បរិវេណដី ឬមានវិវាទអំពីកិច្ចសន្យាការងារសាងសង់ ។ល។ ក្នុងករណីណាក៏ដោយ ការចាត់ចែងនេះ កំណត់នូវឋានៈជាបណ្ដោះអាសន្ន ដោយមិនអនុញ្ញាតឱ្យមានការសាងសង់អគារ រហូតដល់ពេលសាលក្រមចូលជាស្ថាពរ ក្នុងបំណងជៀសវាងការខូចខាតធ្ងន់ធ្ងរដែលអាចកើតឡើងចំពោះម្ចាស់បំណុល ។ លើសពីនេះទៀត ដោយសារមានហេតុផលដូចខាងក្រោម ការចាត់ចែងជាបណ្ដោះអាសន្ននេះ ត្រូវបានគេចាត់ទុកថាជាការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នចំពោះកម្មវត្ថុនោះ :

- មិនមានការទាមទារខ្ពស់ទេ ចំពោះ "ការរក្សាការសំងាត់" ក្នុងការចាត់ចែងនេះ

- ទាមទារឱ្យមានការសាកសួរដោយហ្មត់ចត់ ដោយសារការចាត់ចែងនេះ ជះឥទ្ធិពលខ្លាំងលើកូនបំណុលដែលកំពុងត្រៀមការសាងសង់ ទិញសម្ភារៈ និង កម្មករ ។

៤- តើការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ និង ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ មានចំណុចដូចគ្នា និង ខុសគ្នាអ្វីខ្លះ?

១- និយមន័យ

ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ មានន័យថាជាការចាត់ចែងដែលក៏រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាទឹកប្រាក់ (ម.៥៣១(១)) ។

ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ គឺជាប្រភេទមួយនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ម. ៥៣១(២)) ដែលក៏រិតនូវការចាត់ចែងទ្រព្យសម្បត្តិដែលមានវិវាទចំពោះកូនបំណុល ដើម្បីធានាការអនុវត្តដោយបង្ខំចំពោះសិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារការចុះបញ្ជីទ្រព្យសម្បត្តិផ្អែកលើកម្មសិទ្ធិរបស់គាត់ (មើលសំនួរ១)

២- ចំណុចដូចគ្នា

ប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្នទាំងពីរនេះ មានគោលបំណងរក្សានូវស្ថានភាពដើមនៃទព្យសម្បត្តិដែលជាកម្មវត្ថុ ដោយធ្វើការក៏រិតនូវការចាត់ចែងរបស់កូនបំណុល ហើយវិធីសាស្ត្រអនុវត្ត និង ប្រសិទ្ធភាពរបស់វាគឺដូចគ្នា ។

និយាយម្យ៉ាងវិញទៀត ទាំងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ (ម.៥៦៧) និងការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ ត្រូវអនុវត្តតាមរយៈការចុះបញ្ជីអចលនវត្ថុ ដែលមានវិវាទនោះ ហើយអាជ្ញាសាលាមិនត្រូវកាន់កាប់ទ្រព្យសម្បត្តិនោះទេ ។ ដូច្នេះហើយ គេមិនគួររារាំងកូនបំណុលពីការប្រើប្រាស់ ឬអាស្រ័យផលពីទ្រព្យសម្បត្តិនោះតាមវិធីប្រើធម្មតាឡើយ ។

លើសពីនេះទៀត នៅពេលធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យសម្បត្តិ ឬ ការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងទ្រព្យសម្បត្តិ គេត្រូវហាមឃាត់កូនបំណុលកុំឱ្យចាត់ចែងទ្រព្យសម្បត្តិនោះ ។ ក្រោយពេលចុះបញ្ជីនៃប្រភេទនីមួយៗហើយ បើទោះបីជាកូនបំណុលផ្ទេរទ្រព្យសម្បត្តិនោះ ឬយកទ្រព្យនោះដាក់ជាប្រាតិភោគក៏ដោយ កូនបំណុលមិនអាចតតាំងនឹងម្ចាស់បំណុល ដោយអានុភាពនៃទង្វើ

របស់ខ្លួនបានឡើយ (ទោះបីជាគេទទួលស្គាល់ការចុះបញ្ជីនូវទង្វើនោះក៏ដោយ) ។ ដូចនេះហើយ ក្នុងករណីដែលក្រោយមកម្ចាស់បំណុលចាប់ផ្តើមនូវនីតិវិធីអនុវត្តដោយបង្ខំ តាមនីតិវិធីគេចាត់ទុកថាទង្វើដូចខាងលើរបស់កូនបំណុល មិនមានអានុភាពទេ (មើលសំណួរ ៣៨) ។

៣- ចំណុចខុសគ្នា

ចំណុចខុសគ្នាដែលសំខាន់បំផុតនោះ គឺសិទ្ធិដែលត្រូវរក្សា ។

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដែលនេះជាសិទ្ធិត្រូវការពារ ។

ផ្ទុយទៅវិញ ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុមានគោលបំណងរក្សាការពារសិទ្ធិទាមទារការចុះបញ្ជីទាក់ទងនឹងអចនលវត្ថុដែលមានវិវាទ នេះជាសិទ្ធិដែលត្រូវការពារ (សិទ្ធិលើបំណុលដែលមិនមានគោលបំណងឱ្យសងជាប្រាក់) ។

៥- រឿងក្ដីព្រហ្មទណ្ឌមួយ មានបទល្មើសព្រហ្មទណ្ឌ និង សំណងរដ្ឋប្បវេណី ។

១. ដើម្បីរក្សាវត្ថុមានទ្រព្យសម្បត្តិរបស់ជនសង្ស័យ តើជនរងគ្រោះអាចដាក់ពាក្យសុំឱ្យតុលាការចេញដីការក្សាការពារបានដែរឬទេ?

២. តើរឿងព្រហ្មទណ្ឌខាងលើនេះ គេចាត់ទុកថាជាបណ្ដឹងអង្គសេចក្ដីបានដែរឬទេ ក្នុងរឿងរដ្ឋប្បវេណី (ម. ៥៥៧)?

១. អាចបាន ។ ជនរងគ្រោះអាចដាក់ពាក្យសុំការរក្សាការពារ ។

ជនរងគ្រោះអាចដាក់ពាក្យសុំការរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យសម្បត្តិរបស់ជនសង្ស័យ ដោយផ្អែកលើសិទ្ធិទាមទារសំណងការខូចខាត ដែលជាសិទ្ធិត្រូវរក្សាការពារ ទោះបីជាវាកើតមុន ឬក្រោយការដាក់ពាក្យបណ្ដឹងរឿងក្ដីព្រហ្មទណ្ឌក៏ដោយ ។

២. បណ្ដឹងរដ្ឋប្បវេណី ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺគេចាត់ទុកថាជា"បណ្ដឹងអង្គសេចក្ដី" ក្នុងមាត្រា ៥៥៧ នៃក្រម នីតិវិធីរដ្ឋប្បវេណី ។

"បណ្ដឹងអង្គសេចក្ដី" ក្នុងមាត្រា ៥៥៧ មិនក៏រឹតត្រឹមតែបណ្ដឹងធម្មតាប៉ុណ្ណោះទេ (៧៥) ប៉ុន្តែថែមទាំងបណ្ដឹងតប (៨៦) ឬករណីដីកាសម្រេចដាស់តឿន (៣១៩) ផងដែរ ពីព្រោះករណីទាំងនេះជានីតិវិធីកំណត់ អត្ថិភាព ឬនិត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារដោយអាជ្ញាធរ ។

បណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ជានីតិវិធីកំណត់អត្ថិភាព ឬនិត្ថិភាពនៃសិទ្ធិរក្សាការពារដោយអាជ្ញាធរផងដែរ ដូច្នេះបណ្ដឹងរដ្ឋប្បវេណីក៏អាចចាត់ទុកថាជា "បណ្ដឹងអង្គសេចក្ដី" មាត្រា៥៥៧ ។

| | |
|---|---|
| ៦. | ក្នុងករណីឈ្មោះ និង អាសយដ្ឋានរបស់កូនបំណុល មិនបានកំណត់ច្បាស់ក្នុងពាក្យសុំដីកាសម្រេចរក្សាការពារ (ឧទាហរណ៍ ក្នុងករណីពាក្យសុំការរក្សាការពារហាមឃាត់ការសាងសង់ ឬហាមឃាត់បិទផ្លូវ គេមិនដឹងតើនរណាជាអ្នកសាងសង់ ឬនរណាជាអ្នកបិទផ្លូវ) តើតុលាការចាត់ការចំពោះពាក្យសុំនេះដោយវិធីណា? |

ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល គឺជាចំណុចដែលត្រូវតែសរសេរក្នុងពាក្យសុំដីកាសម្រេចរក្សា ការពារជាដាច់ខាត (ម.៥៤១(១)(ក)) ។ ដូច្នេះ ពាក្យសុំណាដែលខ្វះនូវពត៌មាននេះ គឺមិនត្រឹមត្រូវតាមច្បាប់ទេ ។ កាលណាគេមិនស្គាល់ឈ្មោះ និង អាសយដ្ឋានរបស់កូនបំណុលទេ គេមិនអាចបន្តនូវនីតិវិធីបន្ទាប់ទៀតបានទេ (ការបញ្ជូនដីកា ការអនុវត្តការរក្សាការពារ) ។

ដំបូងតុលាការត្រូវប្រាប់ឱ្យដើមចោទកែតំរូវចំណុចខ្វះខាតដែលមានក្នុងពាក្យសុំ ហើយប្រសិនបើដើមចោទមិនកែតំរូវចំណុចខ្វះខាតនោះទេ តុលាការត្រូវបង្គាប់ឱ្យកែតំរូវ (ម.៥៣៩, ម.៧៨(១)) ។ ក្នុងករណីដើមចោទមិនធ្វើតាមការបង្គាប់របស់តុលាការទេនោះ តុលាការត្រូវលើកចោលនូវពាក្យសុំនោះ តាមរយៈដីកា (មាត្រា ៥៣៩, មាត្រា ៧៨(២)) ។

| | |
|---|---|
| ៧- | ១. ក្នុងករណីពាក្យសុំដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្ន ត្រូវគេលើកចោល តើគេអនុញ្ញាតឱ្យ ដាក់ពាក្យសុំការរក្សាការពារមួយទៀត បានដែរឬទេនៅក្នុងរឿងដដែលនោះ? |
| ៧- | ២. ក្នុងករណីពាក្យសុំដីកាសម្រេចរក្សាការពារ ត្រូវបានគេទទួលស្គាល់ ប៉ុន្តែការអនុវត្តមិនអាចធ្វើបាន ដោយសារពេលវេលាពីរសប្តាហ៍បានកន្លងហួស-ដែលជាអាជ្ញាយុកាលការរក្សា ការពារចែងក្នុងមាត្រា ៥៦២(២) តើគេអនុញ្ញាតឱ្យដាក់ពាក្យសុំការរក្សាការពារមួយទៀតបានដែរឬទេនៅក្នុងរឿងដដែលនោះ? |

១- ទាក់ទងចំណុច(១)

ក្នុងករណី ក្រោយពេលពាក្យសុំដីកាសម្រេចរក្សាការពារត្រូវបានគេលើកចោល គេដាក់ពាក្យសុំដដែលសំណួរអាចលេចឡើង ថាតើការអនុញ្ញាតឱ្យមានការដាក់ពាក្យសារថ្មីនៃពាក្យសុំដដែលនោះ វាប៉ះពាល់ដល់ ស្ថេរភាពគតិយុត្ត ឬការចំណាយលើការវិនិច្ឆ័យដែរឬទេ ។ ប៉ុន្តែ "សិទ្ធិដែលត្រូវបានរក្សាការពារ" និង "ភាពចាំបាច់នៃការរក្សាការពារ" ចាំបាច់ត្រូវតែពិនិត្យមើលក្នុងការវិនិច្ឆ័យរឿងក្តីការរក្សាការពារនេះ (ម.៥៤១) គេត្រូវពិនិត្យឱ្យបានហ្មត់ចត់ ថាតើពាក្យសុំក្រោយ ដូចនឹងពាក្យសុំលើកមុនដែរឬទេ ។

ក. ក្នុងករណី "សិទ្ធិដែលត្រូវបានរក្សាការពារ" "ភាពចាំបាច់នៃការរក្សាការពារ" និង "សេចក្តីបញ្ជាក់ដំបូង" នៃពាក្យសុំទាំងពីរដូចគ្នា ពាក្យសុំទាំងពីរនេះ គឺដូចគ្នាហើយដូចដែលបានពន្យល់ខាងលើ ហើយក្នុងករណីនេះ គេបកស្រាយថា ការដាក់ពាក្យសុំម្តងទៀតនេះគឺគ្រាន់តែជា "ការលើកឡើងនូវរឿង ចាស់" ប៉ុណ្ណោះ ហេតុដូចនេះហើយ គេមិនអនុញ្ញាតិឡើយតាមគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់(ម.៥ នៃក្រមរដ្ឋប្បវេណី និង ម.៤នៃក្រម នីតិវិធីរដ្ឋប្បវេណី) ។

ខ. ក្នុងករណី បើទោះបីជាសិទ្ធិដែលត្រូវបានការពារដូចគ្នា តែភាពចាំបាច់នៃការរក្សាការពារខុសគ្នា ពាក្យសុំក្រោយ មិនត្រូវបានចាត់ទុកថា"ដូចគ្នា"នឹងពាក្យសុំមុននោះទេ ដូចដែលបានរៀបរាប់ខាងលើ ហើយការដាក់ ពាក្យសុំមួយទៀត គឺអាចអនុញ្ញាតបាន ។ គេគិតថា មានករណីជាច្រើនដែលការផ្លាស់ប្តូរពេលក្រោយមកទៀតអាចបង្កើតឱ្យមានភាពចាំបាច់នៃការរក្សាការពារ ទោះបីជាពាក្យសុំដីកាសម្រេចរក្សាការពារត្រូវបានលើកចោលម្តងហើយក៏ដោយ ដោយសារហេតុផលភាពមិនចាំបាច់ក្នុងការសុំការរក្សាការពារនេះ។ ហេតុនេះហើយ ក្នុងករណីបែបនេះ ការដាក់ពាក្យសុំសារជាថ្មីត្រូវបានគេអនុញ្ញាត ។

គ. ក្នុងករណីសិទ្ធិដែលត្រូវរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារនៅក្នុងពាក្យសុំក្រោយ ដូចគ្នានឹងពាក្យសុំមុន ប៉ុន្តែមានបន្ថែមចំណុចថ្មីលើសេចក្តីបញ្ជាក់ដំបូងនៅក្នុងពាក្យសុំចុងក្រោយ មានមតិច្រើនលេចឡើងទាក់ទិន ថាតើពាក្យសុំទាំងពីរនេះ ដូចគ្នាឬមិនដូចគ្នា ។ ទ្រឹស្តីមួយលើកឡើងថា កាលណាសិទ្ធិដែលត្រូវបានការពារ និងភាពចាំបាច់នៃការរក្សាការពារដូចគ្នាហើយ គេមិនចាំបាច់បកស្រាយអ្វីផ្សេងទេ ក្រៅអំពីថាពាក្យសុំទាំងពីរនេះដូចគ្នា ទោះបីជាមានចំណុចបន្ថែមលើសេចក្តីបញ្ជាក់ដំបូងក៏ដោយ ។ ដូច្នេះ ការដាក់ពាក្យសារជាថ្មី គឺមិនត្រូវបានអនុញ្ញាតទេ ដោយសារថាវាជាការលើកឡើងនូវរឿងចាស់ដដែលៗ ។ ប៉ុន្តែ បើធ្វើការពិចារណាថាក្រៅអំពីលក្ខខណៈ "បណ្តោះអាសន្ន"នៃនីតិវិធីរក្សាការពារ គេអាចប្រទះឃើញនូវចំណុចសំខាន់នៃសេចក្តីបញ្ជាក់ដំបូង ក្រោយពេលដាក់ពាក្យសុំ ដោយសារនៅក្នុងពាក្យសុំមុនមានបញ្ហាពេលវេលាក្នុងការប្រមូលចំណុចនៃសេចក្តីបញ្ជាក់ដំបូង ទ្រឹស្តីដែលអនុញ្ញាតឱ្យមានការដាក់ពាក្យសុំដដែលនោះសារជាថ្មី គឺចាត់ទុកថាសមហេតុផល ។

២- ទាក់ទងនឹងសំណួរ (២)

ក្នុងករណី ក្រោយពេលដីកាសម្រេចយល់ព្រមលើពាក្យសុំការរក្សាការពារចេញហើយ មានការដាក់ពាក្យសុំដដែលនោះ អាចលេចចេញនូវសំណួរថាតើពាក្យសុំក្រោយ ខ្វះនូវភាពចាំបាច់ដែរឬទេ ដូច្នេះហើយគេបកស្រាយថា ការដាក់ពាក្យសុំដដែលនោះសារជាថ្មី គឺជាគោលការណ៍មិនត្រូវបានអនុញ្ញាតទេ ។ ក៏ប៉ុន្តែ ក្នុងករណីពេលវេលានៃអនុវត្ត បានផុតកំណត់ ដូចក្នុងករណីចោទសួរនោះ គ្មានជម្រើសអ្វីផ្សេងក្រៅអំពីការដាក់ពាក្យសុំដដែលនោះសារជាថ្មីទេ ។ ដូច្នេះ ភាពចាំបាច់នៃការដាក់ពាក្យសុំសារថ្មី អាចទទួលស្គាល់ជាលក្ខណៈពិសេសបាន ។

## ៨- តើការបញ្ជូនពាក្យសុំដីកាសម្រេចរក្សាការពារដល់កូនបំណុល មានលក្ខណៈចាំបាច់ដែរឬទេ?

គន្ថីទី៧នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនមានបញ្ញត្តិណាមួយចែងទាក់ទងនឹងការបញ្ជូនពាក្យសុំដីកាសម្រេចរក្សាការពារដល់កូនបំណុលទេ ដូច្នេះមានតែមាត្រា ៧៩(១)(គន្ថីទី២): "ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់" និង មាត្រា ៥៣៩:"បញ្ញត្តិពីគន្ថីទី២ ដល់ទី៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស" ដែលទាក់ទងនឹងសំណួរនេះ ។

"អនុវត្តដូចគ្នា" (ម.៥៣៩) មានន័យថា "យកបញ្ញត្តិស្តីអំពីចំណុចណាមួយទៅអនុវត្តចំពោះចំណុចផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នា ដោយមានការកែសំរួលខ្លះៗដែលចាំបាច់" ។ ដូច្នេះ ទាក់ទងនឹងសំណួរនេះមានសំណួរសួរថាតើបញ្ញត្តិនៃមាត្រា ៧៩(១)អំពីការបញ្ជូនពាក្យបណ្តឹង អាចយកមកអនុវត្តចំពោះការបញ្ជូនពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារបានដែរឬទេ ។

បញ្ញត្តិនៃមាត្រា ៧៩(១) គឺជាផ្នែកសំខាន់នៃពាក្យបណ្តឹងដោយសន្មត់ថាក្នុងការចេញសាលក្រម យើងត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ចុងចំលើយដើម្បីឱ្យគេធ្វើអំណះអំណាងតបត យោងតាមគោលការណ៍ចំពោះមុខ (ម. ៣(១))។ ផ្ទុយទៅវិញ ក្នុងនីតិវិធីចាត់ចែងរក្សាការពារ ការទាមទារនូវ"ភាពសំងាត់" ជាចំណុចដែលគេយកចិត្តទុកដាក់ ដែលជាលក្ខណៈសម្បត្តិសំខាន់មួយនៃនីតិវិធីនេះ ។ និយាយម្យ៉ាងវិញទៀត ប្រសិនបើកូនបំណុលដឹងថាមានពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ មុនពេលអនុវត្តនូវដីកានោះ វាអាចធ្វើឱ្យកូនបំណុលរារាំងដល់ការអនុវត្ត ដោយលាក់នូវទ្រព្យសម្បត្តិដែលត្រូវរក្សាការពារនោះ ។ល។ ដែលទង្វើនេះអាចបំផ្លាញនូវអានុភាពនៃការរក្សាការពារនេះ ។ ដូច្នេះ នីតិវិធីចាត់ចែងរក្សាការពារ ចាំបាច់ត្រូវដំណើរទៅដោយរក្សាការសំងាត់មិនឱ្យកូនបំណុលដឹង ។ ជាសរុប ក្នុងនីតិវិធីចាត់ចែងរក្សាការពារ ការអនុវត្តគោលការណ៍ចំពោះមុខគឺមានកំរិតខ្លះ (យោង មាត្រា ៥៣៥(១), បញ្ញត្តិនៃ ម.១១៤(១), ម.៥៦២(៣) ។ ដោយសារការបញ្ជូនពាក្យសុំដីកាចាត់ចែងរក្សាការពារ ផ្ទុយនឹងភាពចាំបាច់នៃ"ការរក្សាការសំងាត់"ក្នុងនីតិវិធីដូចដែលបានពន្យល់ខាងលើ គេបកស្រាយថា មាត្រា ៧៩(១) មិនគួរយកមកអនុវត្តចំពោះនីតិវិធីចាត់ចែងរក្សាការពារឡើយ ។

ហេតុនេះ តុលាការមិនគួរបញ្ជូនពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារទៅកូនបំណុលឡើយ ។

| ៩- ប្រសិនបើបណ្តឹងអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តើម្ចាស់បំណុលអាចដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅតុលាការនៃការជំនុំជម្រះលើកទី១ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទបានដែរឬទេ? |
|---|

យើងអាចធ្វើបាន ។

យោងតាមមាត្រា ៥៤០(១) ទាំងតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី និង តុលាការនៃការជំនុំជម្រះលើកទី១ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ មានសមត្ថកិច្ចលើរឿងក្តីចាត់ចែងរក្សាការពារនេះ។

ដូចនេះ ម្ចាស់បំណុលអាចដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅតុលាការដែលមានសមត្ថកិច្ចលើ បណ្តឹងអង្គសេចក្តី (តុលាការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ក្នុងករណីសំណួររបស់អ្នក) និងម្ចាស់បំណុលក៏អាចដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅតុលាការនៃការជំនុំជម្រះលើកទី១ ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅបានផងដែរ ។

ប្រសិនបើគេដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅកាន់តុលាការនៃការជំនុំជម្រះលើកទី១ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ តុលាការនោះត្រូវចេញដីកាសម្រេចចាត់ចែងរក្សាការពារ ។

១០-　ប្រសិនបើបណ្ដឹងអង្គសេចក្ដី ត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងសាទុក្ខ តើម្ចាស់បំណុលអាចដាក់ ពាក្យសុំការចាត់ចែងរក្សាការពារទៅសាលាឧទ្ធរណ៍បានដែរឬទេ?

មិនអាចដាក់បានទេ ។

តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី និង តុលាការនៃការជំនុំជម្រះលើកទី១ ដែលមានសមត្ថកិច្ចលើវត្ថុដែលត្រូវរឹបអូស ឬលើកម្មវត្ថុដែលមានវិវាទ មានសមត្ថកិច្ចលើរឿងក្ដីការចាត់ចែងរក្សាការពារ (មាត្រា ៥៤០(១)) ។

តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះលើកទី១ ។ ប៉ុន្តែបើអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ (មាត្រា ៥៤០(២)) ។

ផ្អែកលើបញ្ញត្តិខាងលើ ករណីបណ្ដឹងអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងសាទុក្ខ ម្ចាស់បំណុលមិនអាចដាក់ពាក្យសុំការចាត់ចែងរក្សាការពារទៅកាន់តុលាការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍បានឡើយ ។

១១-   តើក្រុមប្រឹក្សាជំនុំជម្រះអាចចាត់ការរឿងក្ដីចាត់ចែងរក្សាការពារបានដែរឬទេ?

អាចធ្វើបាន ។

ទាក់ទងនឹងការជ្រើសរើសចៅក្រមម្នាក់ ឬប្រព័ន្ធក្រុមប្រឹក្សាជំនុំជម្រះសំរាប់ចាត់ការរឿងក្ដីចាត់ចែង រក្សាការពារ មាត្រា ២៣ អនុវត្តចំពោះតុលាការនៃការជំនុំជម្រះលើកទី១ ហើយច្បាប់រៀបចំតុលាការរបស់កម្ពុជា(ពង្រៀង) នឹងអនុវត្តចំពោះតុលាការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ។

១២- ក្នុងករណីមានការដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ ហើយបណ្តឹងអង្គសេចក្តីកំពុងតែ ចាត់ការ តើចៅក្រមដែលជំរះក្តីបណ្តឹងអង្គសេចក្តីអាចទទួលបន្ទុកលើរឿងចាត់ចែងការរក្សាការពារបន្ថែមទៀត បានដែរ ឬទេ?

ចៅក្រមដែលជំរះក្តីបណ្តឹងអង្គសេចក្តី
អាចទទួលបន្ទុកលើរឿងពាក្យសុំដីកាសម្រេចចាត់ការរក្សាការពារនេះ បានក្នុងករណីតែមួយ ពីព្រោះមិនមានការហាមប្រាមនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ ។

ទាក់ទងនឹងការបែងចែករឿងក្តីចាត់ចែងរក្សាការពារ គេយកមាត្រា ២៦ មកអនុវត្ត ។ ដូច្នេះ ប្រធាន តុលាការនីមួយៗ ត្រូវកំណត់ការបែងចែករឿងក្តីចាត់ចែងរក្សាការពារនេះជារៀងរាល់ឆ្នាំទុកជាមុន ។

ទាក់ទងនឹងការបែងចែករឿងក្តីចាត់ចែងរក្សាការពារ បើសិនជាប្រធានតុលាការកំណត់ថារឿងក្តីចាត់ចែងរក្សាការពារត្រូវបែងចែកទៅឱ្យចៅក្រមជំរះក្តីបណ្តឹងអង្គសេចក្តី ហើយប្រសិនបើបណ្តឹងអង្គសេចក្តីនៃករណីនោះ កំពុងចាត់ការ ករណីបណ្តឹងចាត់ចែងរក្សាការពារនេះត្រូវបែងចែកទៅឱ្យចៅក្រមដែលទទួល បន្ទុកបណ្តឹងអង្គសេចក្តីនោះ ។

១៣- សូមផ្តល់ឧទាហរណ៍ "ករណីដែលមានស្ថានភាពពិសេស" (មាត្រា ៥៤៨ កថាខណ្ឌ៤ វាក្យខណ្ឌ គេអាច ចេញដីកាចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ ឋានៈបណ្តោះអាសន្ន ដោយមិនចាំបាច់រៀបចំនីតិវិធីទាញ ហេតុផលដោយផ្ទាល់មាត់ ឬ សាកសួរទេ ។

១.ជាទូទៅ គេនិយាយសំដៅដល់ករណី "ដែលកូនបំណុលអាចមានលទ្ធភាពខ្ពស់ក្នុងការជ្រៀតជ្រែកនឹងកិច្ចការអនុវត្ត ប្រសិនបើយើងរៀបចំការសាកសួរ " ឬ ក្នុងករណី "ដែលនឹងកើតមានគ្រោះថ្នាក់ធំៗដល់ម្ចាស់បំណុល" ជាអាទិ៍

២.ឧទាហរណ៍:

-នៅពេលមនុស្សម្នាក់ដែលបានទិញឡានដោយបង់រំលោះ (ជាធម្មតាតែងមានកិច្ចព្រមព្រៀងរវាងអ្នកលក់ និងអ្នកទិញ ថាកម្មសិទ្ធលើឡានជារបស់អ្នកលក់រហូតដល់ពេលបង់ប្រាក់គ្រប់ចំនួន) យឺតយ៉ាវក្នុងការបង់ប្រាក់អស់រយៈពេលយ៉ាងយូរ ពេលនោះអ្នកលក់ទាមទារការចាត់ចែងជាបណ្តោះអាសន្នលើការប្រគល់ឡាន នោះ ។

-ក្រោយពេលដីកាសម្រេចមួយបានចេញហើយទាក់ទងនឹងការចាត់ចែងជាបណ្តោះអាសន្នដោយទុកដីឱ្យនៅទំនេរ មានជនម្នាក់សមគំនិតជាមួយនឹងកូនបំណុល ចាប់ផ្តើមកាន់កាប់ដីដែលមានវិវាទនោះ ហើយម្ចាស់បំណុលទាមទារនូវការចាត់ចែងជាបណ្តោះអាសន្នថ្មីមួយទៀតដោយទុកដីឱ្យនៅទំនេរទល់នឹងជននោះ ។

-នៅពេលដែលអ្នកជិតខាងម្នាក់ជីកដីដែលនៅជាប់គ្នាជាមួយនឹងអ្នកជិតខាងម្នាក់ទៀតដើម្បីសង់អាគារមួយ អ្នកជិតខាងម្នាក់ នោះទាមទារការចាត់ចែងជាបណ្តោះអាសន្នដើម្បីហាមឃាត់ការសាងសង់បន្តពីព្រោះវាអាចមានលទ្ធភាពខ្ពស់ចំពោះការបាក់ដី ។

-ទាក់ទងនឹងជំលោះអំពីផ្ទះជួលមួយកន្លែង ភតិបតីបានចាក់បេតុងចូលក្នុងបង្គន់ផ្ទះជួល ក្នុងពេលអវត្តមានភតិកៈ ភតិកៈនោះទាមទារការចាត់ចែងជាបណ្តោះអាសន្នសុំឱ្យប្រមូលបេតុងនោះចេញវិញ ។

-នៅពេលការចេញផ្សាយទស្សនាវត្តីលេខបន្ទាប់មានអត្ថបទពាក់ពន្ធ័នឹងការបរិហាកេរ្តិ៍ខុសច្បាប់ ជនដែលជាទិសដៅនៃបទបរិហាកេរ្តិ៍ នោះទាមទារការចាត់ចែងជាបណ្តោះអាសន្នក្នុងការផ្អាកការបោះពុម្ពផ្សាយ ។

៣.ទោះបីក្នុងប្រភេទករណីខាងលើក៏ដោយ

យើងគួរធ្វើការវិនិច្ឆ័យអោយបានប្រុងប្រយ័ត្នដើម្បីជៀសវាងកុំឱ្យ កូនបំណុលបាត់បង់ឱកាសក្នុងការតវ៉ា ដោយត្រូវគិតអំពីភាពគ្រប់គ្រាន់នៃសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល ក៏រិតនៃការដោះសារ ដែលសមហេតុផលរបស់កូនបំណុល ជាអាទិ៍

១៤- តើអាចសួរតតីយជនដែលជាជនក្រៅពីភាគីបានដែរឬទេក្នុងការវិនិច្ឆ័យលើពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ ឬក្នុងការវិនិច្ឆ័យបណ្តឹងតវ៉ាចំពោះការចាត់ចែងរក្សាការពារ?

១- តាមធម្មតាមិនអាចធ្វើបានទេ ។

មាត្រា ១១៤(២) (អនុវត្តដូចគ្នាចំពោះនីតិវិធីការចាត់ចែងរក្សាការពារ មាត្រា ៥៣៩) ចែងថា "តុលាការអាចសួរភាគី" ហើយបញ្ញត្តិនេះមិនបានរួមបញ្ចូលតតីយជនជាប្រធាននៃការសួរទេ ។

ហេតុនេះ ដើម្បីយកភស្តុតាងពីអ្នកផ្សេងក្រៅអំពីភាគី គេត្រូវធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដើម្បីសាកសួរសាក្សី (ម.១១៤(១),ម.៥៣៩) ។

២- ប៉ុន្តែ ក្នុងករណីតុលាការគិតថាសមរម្យក្នុងការសួរជន ដែលមានការពាក់ពន្ធ័នឹងកិច្ចការរដ្ឋបាលដែលធ្វើឡើងសំរាប់ភាគី ឬដើម្បីជួយដល់ភាគី គេបកស្រាយថាការសួរជនប្រភេទ"ដូចជាភាគី"នេះគឺអាចធ្វើបាន ។

នេះគឺដោយសារ ក្រៅអំពីគេចាត់ទុកថាជនប្រភេទនេះគឺដូចភាគី ជននេះគឺមានការពាក់ពន្ធ័ផ្ទាល់ក្នុងរឿងក្តីក្នុងនាមភាគី ។ ក្នុងន័យនេះ ជននោះមានការយល់ដឹងច្រើនអំពីទំនាក់ទំនងអង្គហេតុជាងភាគី ហើយវាជារឿងសំខាន់ខ្លាំងណាស់ ដែលត្រូវតែអនុញ្ញាតឱ្យមានការសួរជននោះក្នុងគោលបំណងដោះស្រាយនូវរឿងក្តី ។

ឧទាហរណ៍ នៅពេលតុលាការចាត់ទុកថាសមហេតុផល ក្នុងការសួរជនម្នាក់ដែលស្ថិតក្នុងប្រភេទណាមួយដូចខាងក្រោមនេះ យើងអាចសួរជននោះក្នុងនាមជា"ដូចជាភាគី" :

- បុគ្គលិករបស់ក្រុមហ៊ុនដែលទទួលបន្ទុកកិច្ចការដែលពាក់ពន្ធ័នឹងពាក្យសុំ នៅពេលក្រុមហ៊ុនមួយបានដាក់ពាក្យសុំការចាត់ចែងរក្សាការពារទាក់ទងនឹងជំនួញរបស់ខ្លួន

- មន្ត្រីសហជីពពាណិជ្ជកម្ម (ករណីសហជីពពាណិជ្ជកម្មពាក់ពន្ធ័ខ្លាំងក្នុងដំណើរការបណ្តេញកម្មករ) នៅពេល និយោជិកម្នាក់បានដាក់ពាក្យសុំការចាត់ចែងជាបណ្តោះអាសន្នដោយឱ្យក្រុមហ៊ុនបង់ប្រាក់ខែជាបណ្តោះអាសន្នជាអាទិ៍ ដោយអះអាងថាការបណ្តេញចេញលើរូបគាត់ខុសច្បាប់ ។

- ស្ថាបត្យករ ឬគណនេយ្យករផ្នែកពន្ធដារដែលបំពេញការងាររដ្ឋបាលក្នុងនាមភាគីដោយប្រើនូវជំនាញឯកទេសរបស់ខ្លួន ។

- ប្តីឬប្រពន្ធ ឬកូនរបស់ភាគីដែលបានធ្វើការចរចារជាមួយនឹងភាគីម្ខាងទៀតក្នុងនាមភាគីនោះ ។

១៥- សូមផ្តល់ឧទាហរណ៍គំរូក្នុងករណីតុលាការចេញដីកាចាត់ចែងរក្សាការពារ ដោយមិនបង្គាប់ឱ្យដាក់ប្រាតិភោគ ។

តាមការអនុវត្តនៅប្រទេសជប៉ុន ករណីចៅក្រមចេញដីកាសម្រេចចាត់ចែងការរក្សាការពារដោយមិនបង្គាប់ឱ្យ ដាក់ប្រាតិភោគ គឺមានតិចតួចណាស់ ។

ឧទាហរណ៍ នៅក្នុងករណីការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យកូនបំណុលបង់ប្រាក់ខែបណ្តោះអាសន្នដល់អតីតបុគ្គលិក(ម្ចាស់បំណុល) ដែលជាអ្នកប្តឹងសុំបញ្ជាក់នូវឋានៈជាបុគ្គលិក ចៅក្រមអាចចេញដីកាសម្រេចរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគបាន ។

ឧទាហរណ៍មួយទៀត នៅក្នុងករណីការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យកូនបំណុលបង់សំណងបណ្តោះអាសន្នដល់ជនរងគ្រោះ (ម្ចាស់បំណុល)ដែលប្តឹងទាមទារសំណង ខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ ចៅក្រមអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគបាន ។

ពីព្រោះ ក្នុងឧទាហរណ៍ខាងលើ មូលហេតុនៃការចេញដីកា ភាពចាំបាច់នៃដីកា គឺថាម្ចាស់បំណុលមិនអាចរស់នៅ បានទេប្រសិនបើគ្មានប្រាក់ខែ ឬសំណងជាបណ្តោះអាសន្ននោះ ហើយការចេញដីកានេះ គឺចាំបាច់ណាស់ ដើម្បីជៀសវាងនូវការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល (ម.៥៤៨(២) ។ ក្នុងករណីទាំងនេះ ការបង្គាប់ម្ចាស់បំណុលឱ្យដាក់ប្រាតិភោគ គឺមិនត្រូវនឹងហេតុផលខាងលើទេ ជាហេតុផលដែលគាំទ្រនូវភាពចាំបាច់នៃដីកាសម្រេចចាត់ចែងរក្សាការពារ ។ ដូច្នេះហើយ នៅប្រទេសជប៉ុន តុលាការតែងចេញនូវដីកាសម្រេចចាត់ចែងរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគនោះទេក្នុងករណីទាំងអស់នេះ ។ ប៉ុន្តែ ស្ទើរគ្រប់ករណីទាំងអស់ តុលាការចេញដីកាសម្រេចចាត់ចែងរក្សាការពារដោយបង្គាប់ឱ្យមានការដាក់ប្រាតិភោគ ។

១៦- តើវាជាការចាំបាច់ទេ ក្នុងការបញ្ជូនដីកាទាក់ទងនឹងការដាក់ប្រាតិភោគទៅកាន់ កូនបំណុល ឬក្នុងការជូនដំណឹងកូនបំណុលអំពីដីកានោះ ?

១- ទាក់ទងនឹងការបញ្ជូន

ជាគោលការណ៍ ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងអំពីដីកានោះ( ម.២១៣ (១)) ហើយការបញ្ជូនដីកាសម្រេច មានការចាំបាច់លុះត្រាតែមានបញ្ញត្តិពិសេសចែង ( យោង ម.៥៤៣, ម.៥៥៤( ៣), ម.៥៥៧( ៨), ម.៥៥៨( ៣) ,ម.៥៥៩( ៣), ម. ៤១៩ (២) ។ល ។)

ដោយសារមិនមានបញ្ញត្តិទាក់ទងនឹងការបញ្ជូនដីកាសម្រេចអំពីការដាក់ប្រាតិភោគ ការបញ្ជូនដីកានេះ មិនចាំបាច់ទេ ។

២- ទាក់ទងនឹងការជូនដំណឹង

មាត្រា ២១៣( ១) ( គន្លីទី២) ចែងថា "ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ" និង មាត្រា ៥៣៩ ចែងថា "បញ្ញត្តិពីគន្លីទី២ ដល់គន្លីទី៤ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារលើកលែងតែមានបញ្ញត្តិពិសេស ។"

"អនុវត្តដូចគ្នា" ( ម.៥៣៩) មានន័យថា "យកបញ្ញត្តិស្តីអំពីចំណុចណាមួយទៅអនុវត្តចំពោះចំណុចផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នា ដោយមានការកែសំរួលខ្លះៗដែលចាំបាច់" ។ ដូច្នេះ ទាក់ទងនឹងសំណួរនេះ មានសំណួរសួរថាតើបញ្ញត្តិនៃមាត្រា ២១៣( ១) ដែលទាមទារនូវការជូនដំណឹងដី កាសម្រេចយកទៅអនុវត្តចំពោះ ដីកាសម្រេចអំពីការដាក់ប្រាតិភោគបានដែរឬទេ ។

បើសិនជាកូនបំណុលទទួលដំណឹងអំពីដីកាសម្រេចអំពីការដាក់ប្រាតិភោគហើយ កូនបំណុលអាចស្វែងយល់ឱ្យដឹងអំពីពាក្យសុំដីកាសម្រេចការចាត់ចែងរក្សាការពារ មុនពេលគេអនុវត្តវា ហើយការធ្វើបែបនេះ វាផ្ទុយ នឹងការទាមទារ "ការសំងាត់" នៃនីតិវិធីចាត់ចែងរក្សាការពារ ដែលមានផលប៉ះពាល់ដល់ម្ចាស់បំណុល ។ លើសពី នេះទៀត ដីកាសម្រេចអំពីការដាក់ប្រាតិភោគខ្លួនវាផ្ទាល់ មិនរំលោភលើសិទ្ធិរបស់

កូនបំណុលទេ ។ បើទោះជា កូនបំណុលមិនពេញចិត្តនឹងចំនួនប្រាតិភោគក៏ដោយ គេអាចផ្តល់ឱកាសដល់កូនបំណុលក្នុងការតតាំងក្នុង បណ្តឹងតវ៉ា ប្រឆាំងនឹងដីកាសម្រេចចាត់ចែងរក្សាការពារ ។

ដូចដែលបានពន្យល់ខាងលើ មាត្រា ២១៣(១) មិនត្រូវយកទៅអនុវត្តចំពោះដីកាសម្រេចអំពីការដាក់ប្រាតិភោគឡើយ ដោយសារការជូនដំណឹងអំពីដីកានេះដល់កូនបំណុល គឺប៉ះពាល់ដល់នីតិវិធី ហើយភាពចាំបាច់នៃ ការជូនដំណឹងនេះ មិនសូវខ្ពស់ទេ ។

ដូចនេះ តុលាការមិនគួរជូនដំណឹងកូនបំណុលអំពីដីកាសម្រេចដាក់ប្រាតិភោគនេះឡើយ ។

១៧- ក្នុងករណីម្ចាស់បំណុលចាញ់ក្តីនៅក្នុងបណ្តឹងអង្គសេចក្តី ក្រោយពេលតុលាការបានចេញនិងអនុវត្ត ដីកាចាត់ចែងរក្សាការពាររួចហើយ តើការខូចខាតដែលកើតមានចំពោះកូនបំណុលតាមរយៈការចាត់ចែង រក្សា ការពារនេះត្រូវសងវិញដោយវិធីណា?

១.កូនបំណុលអាចប្តឹងម្ចាស់បំណុលដើម្បីទាមទារសំណងខូចខាតអំពីទង្វើអនីត្យានុកូលរបស់គាត់ (មាត្រា ៧៤៣-១ ក្រមរដ្ឋប្បវេណី)។

២. មានល័ក្ខខ័ណ្ឌ បីយ៉ាងក្នុងការទទួលស្គាល់នូវអំពើអនីត្យានុកូល គឺ" ការបំពានច្បាប់" "កំហុសដោយចេតនា ឬដោយអចេតនា" និង"ព្យសនកម្ម"។ ការពន្យល់ខាងក្រោមអំពីរបៀបដែលម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តី មានឥទ្ធិពលដល់បណ្តឹង ទាមទារសំណងបន្ទាប់ទៀតនៅប្រទេសជប៉ុន

(១) ការបំពានច្បាប់

ទាក់ទងនឹងអង្គហេតុដែលថា

សិទ្ធិដែលនឹងត្រូវបានរក្សាការពារនៅក្នុងដីកាសំរេចចាត់ចែងរក្សាការពារមិនត្រូវ បានគេទទួលស្គាល់ អាជ្ញាអស់ជំនុំនៃសាលក្រម(មាត្រា ១៩៤) នៅក្នុងបណ្តឹងអង្គសេចក្តី ពន្លាតដល់បណ្តឹងទាម ទារសំណងការខូចខាត។ ដូច្នេះគេចាត់ទុកថា ម្ចាស់បំណុលបានដាក់ពាក្យសុំចាត់ចែងរក្សាការពារដោយផ្អែកលើ នត្ថិភាពនៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ហើយដូច្នេះ នៅក្នុងករណីជាច្រើន"ការបំពានច្បាប់" មិនអាចតតាំង នៅក្នុងបណ្តឹងទាមទារសំណងការខូចខាតបានទេ។

(២) កំហុសដោយអចេតនា

សាលក្រមរបស់តុលាការកំពូលសម្រេចដូចខាងក្រោមៈ

ជាទូទៅ នៅពេលដែលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ត្រូវគេលុបចោលតាមរយៈនីតិវិធីតវ៉ា ឬ ឧទ្ធរណ៍ ឬដើមចោទចាញ់ក្តីក្នុងបណ្តឹងអង្គសេចក្តី ហើយសាលក្រមស្ថាពរ វាជារឿងសមស្របដោយគិតថា អ្នកដាក់ពាក្យសុំដីកាមានការធ្វេសប្រហែស លើកលែងមានស្ថានភាពពិសេសផ្សេងពីនេះ ។ ដូច្នេះហើយ ការវិនិច្ឆ័យ ត្រូវធ្វើឡើងដោយទាញចេញពីទស្សនៈថាតើមានស្ថានភាពពិសេសដែរឬទេ ដើម្បីបដិសេធនូវភាព ធ្វេសប្រហែសរបស់ដើមចោទ ។

ករណីគំរូមួយអំពីស្ថានភាពពិសេសដែលបដិសេធនូវភាពធ្វេសប្រហែសរបស់អ្នកដាក់ពាក្យសុំ គឺនៅពេល ដែលទំនាក់ទំនងគតិយុត្តមានភាពស្មុគស្មាញ ហើយការបកស្រាយគតិយុត្ត ឬសាលក្រមមានការលំបាក ឬនៅពេល

ដែលកូនបំណុលក៏មានកំហុសផងដែរដែលធ្វើអោយម្ចាស់បំណុលធ្វើការសំរេចចិត្តខុស (គេនិយាយថាមានករណីពិសេសមួយចំនួនតូចដែលគេទទួលស្គាល់ ក្នុងការបដិសេធនូវភាពធ្វេសប្រហែសរបស់ដើមចោទ) ។

(៣) ការកំណត់ទំហំនៃសំណងក្នុងបណ្តឹងទាមទារសំណង

រាល់ការខូចខាតទាំងអស់ដែលទាក់ទងនឹងនីតិវិធីរក្សាការពារ រួមមានប៉ុន្តែមិនកំរិតត្រឹមៈប្រាក់ប្រដាប់ក្តី សោហ៊ុយលើការអនុវត្ត សោហ៊ុយដឹកជញ្ជូនដើម្បីរក្សាភាពដើមនៃកម្មវត្ថុ ការប្រាក់ចំពោះប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ថ្លៃជួលដែលខាតបង់ដោយសារមិនអាចជួលអាគារបាននៅពេលមានវិវាទអំឡុងពេលនីតិវិធីរក្សាការពារ ការខាតបង់ប្រាក់ចំណេញដោយសារមិនអាចធ្វើអាជីវកម្មបានអំឡុងពេលនីតិវិធីរក្សាការពារ ការខូច ខាតផ្នែកផ្លូវចិត្ត ឬ អារម្មណ៍ ជាអាទិ៍ មានការជជែកគ្នាថាតើត្រូវបញ្ចូលថ្លៃជួលមេធាវីត្រឹមកំរិតណា ។

៣.ការបង់ប្រាក់ប្រាតិភោគក្នុងនីតិវិធីរក្សាការពារ

កូនបំណុលដែលឈ្នះក្តីទាមទារសំណងខូចខាត មានសិទ្ធិអាទិភាពក្នុងការទទួលប្រាក់ប្រាតិភោគដែលម្ចាស់បំណុលបង់ក្នុងនីតិវិធីរក្សាការពារ (មាត្រា ៧២) ។ កូនបំណុលអាចទទួលបាននូវប្រាតិភោគវិញតាមរយៈនីតិវិធីទាមទារឱ្យបញ្ជូនត្រឡប់មកវិញនូវរបស់ដែលបានផ្ញើទុក ដោយដាក់សាលក្រមជូនដល់តុលាការដែលទទួលទុកនូវប្រាតិភោគនោះ ។

១៨- តើតុលាការគួរធ្វើដូចម្តេច នៅពេលតុលាការបានចេញដីកាសម្រេចដោយមិនទាមទារឱ្យដាក់ប្រាតិភោគ និង ការខូចខាតបានកើតឡើងចំពោះកូនបំណុល? សូមពន្យល់អំពីភាពខុសគ្នារវាងការដាក់តម្កល់ ប្រាតិភោគ និង ការមិនដាក់តម្កល់ប្រាតិភោគ?

បើការដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារបង្កការខូចខាតដល់កូនបំណុល កូនបំណុលនោះអាចដាក់ពាក្យបណ្តឹងទាមទារសំណងខូចខាត ពីម្ចាស់បំណុល ដោយផ្អែកតាមមាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី (មើលសំណួរ១៨) ។

បើតុលាការបានឱ្យម្ចាស់បំណុលដាក់តម្កល់ប្រាតិភោគ កូនបំណុលមានអទិភាពទទួលបានប្រាតិភោគនោះ មុនម្ចាស់បំណុលផ្សេងទៀត (ម.៧២) ក្រោយពេលកូនបំណុលឈ្នះក្តីខាងលើ និងពេលសាលក្រមស្ថាពរ ។

និតិវិធីទទួលបាននូវប្រាតិភោគ មានចែងក្នុងប្រកាសរបស់ក្រសួងស្តីពីនីតិវិធីដាក់តម្កល់នៅតុលាការ ដែលប្រកាសនេះត្រូវបានកំពុងពង្រាងដោយក្រសួងយុត្តិធម៌ ។

យោងតាមសេចក្តីព្រាងខាងលើនេះ ជនណា (កូនបំណុលក្នុងសំណួរ) ដែលសង្ឃឹមធ្វើការទាមទារនូវការប្រគល់មកវិញនូវរបស់ដែលបានទុកតំកល់ ត្រូវបញ្ជាក់ពីសិទ្ធិរបស់ខ្លួនក្នុងការទាមទារនោះ ។ ក្នុងករណីសំណួរនេះ កូនបំណុល ត្រូវដាក់នូវសាលក្រមខាងលើ និង ពាក្យសុំអំពីការប្រគល់វត្ថុតំកល់មកវិញ ។

បើសិនជាតុលាការមិនបានឱ្យម្ចាស់បំណុលដាក់តម្កល់ប្រាតិភោគទេ កូនបំណុលមិនអាចទទួលអ្វីពីប្រាតិភោគនោះទេ ។

បើសិនជាកូនបំណុលឈ្នះក្តីទាមទារសំណងការខូចខាត ដែលបង្កពីការដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ ហើយសាលក្រមចូលជាស្ថាពរ កូនបំណុលត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រមខាងលើ ដែលវានឹងក្លាយជាលិខិតអនុវត្ត (ម.៣៥០(១),(២)(ក)) ។ តែបើសិនជាមិនមានទ្រព្យសម្បត្តិសំរាប់រឹបអូសទេ ការអនុវត្តដោយបង្ខំ មិនអាចធ្វើបានទេ ។ ដើម្បីជៀសវាងករណីនេះ តុលាការត្រូវបង្គាប់ម្ចាស់បំណុលឱ្យដាក់តម្កល់ប្រាតិភោគ ក្នុងករណីស្ទើរតែទាំងអស់ នៅពេលតុលាការចេញដីកាសម្រេចចាត់ចែងរក្សាការពារ ។ ក្នុងន័យនេះ យើងអាចនិយាយបានថា តុលាការមានឆន្ទានុសិទ្ធិចង្អៀតក្នុងការសំរេចថាតើម្ចាស់បំណុលត្រូវដាក់តម្កល់ប្រាតិភោគ ឬអត់ ។

១៩- ប្រសិនបើកម្មវត្ថុនៃការចាត់ចែងរក្សាការពារ ត្រូវបានគេចាត់ចែងហើយ តើតុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងនោះបានដែរឬទេ?

ប្រសិនបើកម្មវត្ថុនៃការចាត់ចែងរក្សាការពារត្រូវបានគេចាត់ចែងរួចមុនចេញដីកាសម្រេច តុលាការមិនអាចចេញដីកាសម្រេចហាមឃាត់ការចាត់ចែងកម្មវត្ថុនោះទេ ។

តាមហេតុផលតុលាការមិនអាចហាមឃាត់កូនបំណុលនូវការចាត់ចែងកម្មវត្ថុបានឡើយ ចំពោះកម្មវត្ថុដែលកូនបំណុលបានចាត់ចែងរួចរាល់ហើយនោះ ។

២០- ទ្រព្យសម្បត្តិរបស់កូនបំណុល ស្ថិតក្រោមហ៊ីប៉ូតែក:

(១) តើតុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបានដែរឬទេចំពោះទ្រព្យសម្បត្តិដូចខាងលើនេះ? តើមាននីតិវិធីអ្វីក្នុងការអនុវត្តនូវដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន?

(២) ប្រសិនបើគេគណនានូវទ្រព្យសម្បត្តិរបស់កូនបំណុល ហើយឃើញថាមិនមានសល់ទ្រព្យអ្វីសោះ តើតុលាការអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារបានដែរឬទេ?

១- អាចបាន ។ ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើតាមមាត្រា ៥៦៧ ។

២- តុលាការអាចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ ដោយសារមិនមានមាត្រាណាមួយហាមប្រាមការរឹបអូសជាបណ្ដោះអាសន្ននោះទេក្នុងករណីសំណួរខាងលើនេះ ។ មិនអាចយកមាត្រា ៤៣៥ ទៅអនុវត្តដូចគ្នានឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុបានទេ (មើលម.៥៦៧(៤)) ។ តាមការពិតជាក់ស្ដែង គេកម្រនឹងកំណត់តំលៃអចលវត្ថុ ឬ ហ៊ីប៉ូតែកឱ្យបានច្បាស់ឡើយ ក្នុងដំណាក់កាលដាក់ពាក្យសុំរឹបអូសជាបណ្ដោះអាសន្ន ។

២១- តើគេអាចកំណត់នូវទឹកប្រាក់រំដោះពីការចាត់ចែងជាបណ្តោះអាសន្ន ដូចគ្នានឹងទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នបានដែរឬទេ?

១. គេបកស្រាយថាមិនអាចកំណត់ទឹកប្រាក់រំដោះពីការចាត់ចែងជាបណ្តោះអាសន្នបានឡើយ ។

មាត្រា ៥៤៧(១) ចែងអំពីទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ចំណែកឯការចាត់ចែងជាបណ្តោះអាសន្នវិញ គ្មានមាត្រាចែងឡើយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីអំពីប្រាក់រំដោះពីការចាត់ចែងជាបណ្តោះ អាសន្ន ។

២. មូលហេតុគេមិនកំណត់អំពីប្រព័ន្ធប្រាក់រំដោះពីការចាត់ចែងជាបណ្តោះអាសន្ន- ទំនាក់ទំនងរបស់វាជាមួយគោលបំណងនៃប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។

១- មានហេតុផលពីរយ៉ាងអំពីអត្ថិភាពនៃប្រព័ន្ធប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ដូចខាងក្រោម:

ក. ដោយសារការរឹបអូសជាបណ្តោះអាសន្នធ្វើឡើងដើម្បីធានានូវ សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ នៅពេលណាកូនបំណុលផ្តល់ទឹកប្រាក់ដែលស្មើគ្នានឹងបំណុលឱ្យសងជាប្រាក់នោះហើយ ម្ចាស់បំណុលមិនត្រូវបានទទួលនូវសំណងខូចខាតឡើយ សូមបីនៅពេលមានការលុបចោលនូវ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននោះក៏ដោយ ។

ខ. នៅពេលណាដែលការអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានគេលុបចោលហើយ ក្នុងពេលបង់ប្រាក់រំដោះ កូនបំណុលអាចចាត់ចែងកម្មវត្ថុតាមចិត្តរបស់ពួកគេបាន ហេតុដូចនេះហើយប្រព័ន្ធនេះ គឺមានសារប្រយោជន៍ចំពោះកូនបំណុលផងដែរ ។

២- ក្នុងករណីការចាត់ចែងជាបណ្តោះអាសន្ន ដោយសារសិទ្ធិដែលត្រូវរក្សាការពារមិនមែនជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប្រាក់រំដោះពីការចាត់ចែងជាបណ្តោះអាសន្នខ្វះនូវលក្ខខណ្ឌ(ក) ខាងលើ ហេតុដូចនេះហើយវាមិនស្របគ្នាទៅនឹងប្រព័ន្ធប្រាក់រំដោះនោះទេ ។ ឧទាហរណ៍

ក្នុងករណីការចាត់ចែងជាបណ្តោះអាសន្ន ហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ទោះបីជាកូនបំណុលដាក់ប្រាក់មួយចំនួនក៏ដោយ សិទ្ធិដែលត្រូវរក្សាការពារ ដែលជាសិទ្ធិទាមទារការលុបបំបាត់អចលនវត្ថុនោះ គឺមិនត្រូវបានធានាទេ។ ដូច្នេះ ប្រព័ន្ធប្រាក់រំដោះចំពោះការចាត់ចែងជាបណ្តោះអាសន្នមិនមានចែងទេ ។

៣. ប៉ុន្តែ មានប្រភេទការចាត់ចែងជាបណ្តោះអាសន្នមួយចំនួន ដែលគោលបំណងរបស់វាអាចបំពេញបានតាមរយៈការទទួលយកជាប្រាក់ បើទោះជាសិទ្ធិដែលត្រូវរក្សាការពារនោះ មិនមែនជាការទាមទារឱ្យសងជាប្រាក់ក៏ដោយ ។ អ្នកធ្វើពង្រាងក្រមនេះ ប្រហែលជាគិតថា នៅពេលកូនបំណុលតម្កល់ប្រាក់ប្រាតិភោគក្នុងករណីការចាត់ចែងជាបណ្តោះអាសន្ន ការលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស គឺអាចផ្តល់ឱ្យ បានតាមមាត្រា ៥៩៩ ដូចនេះហើយប្រព័ន្ធប្រាក់រំដោះពីការចាត់ចែងជាបណ្តោះអាសន្ន គឺមិនចាំបាច់ទេ ( មើល កំណត់មាត្រា ៥៥៩) ។

ប្រភេទការចាត់ចែងជាបណ្តោះអាសន្នខាងក្រោមនេះ គឺជាឧទាហរណ៍អំពីការចាត់ចែងជាបណ្តោះអាសន្នដែល គោលបំណងរបស់វា អាចបំពេញតាមការទទួលយកប្រាក់ ។ ប៉ុន្តែត្រូវធ្វើការពិនិត្យមើលឱ្យបានច្បាស់ទៅតាមករណីនីមួយៗ ហើយទោះបីមានករណីណាមួយស្ថិតក្នុងប្រភេទដូចប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្នទាំងនេះក៏ដោយ យើងត្រូវពិចារណាឱ្យបានទូលំទូលាយចំពោះស្ថានភាពរបស់វា ។

- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់

- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ ករណីដែលសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិលុបចោលអំពើខុសច្បាប់ ( មាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណី)

- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ ករណីដែលសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ( មាត្រា ១២៣៥ នៃក្រមរដ្ឋប្បវេណី)

- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការកាប់ឈើ និង ដឹកឈើ ករណីដែលសិទ្ធិដែលត្រូវរក្សាការពារ គឺជា សិទ្ធិទាមទារប្រគល់វត្ថុដោយផ្អែកលើកម្មសិទ្ធិ ។

**២២- តើដីកាសម្រេចចាត់ចែងរក្សាការពារគួរចែងអំពីបន្ទុកនៃសោហ៊ុយសំរាប់នីតិវិធីដែរឬទេ?**

១- ដើម្បីឆ្លើយសំណួរនេះ យើងគួរពិនិត្យមើលចំណុចពីរដូចខាងក្រោមៈ

១. តើបន្ទុកនៃសោហ៊ុយសំរាប់នីតិវិធីសំរាប់ការចាត់ចែងរក្សាការពារ អាចចែងដាច់ដោយឡែកពីបន្ទុកនៃប្រាក់ប្រដាប់ក្តីក្នុងបណ្តឹងអង្គសេចក្តីបានដែរឬទេ? ក្នុងករណីបន្ទុកនៃសោហ៊ុយសំរាប់នីតិវិធីចែងក្នុងដីកាសម្រេចចាត់ចែង រក្សាការពារ តើវាបង្កនូវការលំបាកដែរឬទេ ប្រសិនបើសេចក្តីសម្រេចក្នុងបណ្តឹងអង្គសេចក្តី បែជាសម្រេចផ្ទុយមកវិញនោះ?

២. គេអាចប្តឹងតវ៉ាចំពោះដីកាសំរេចទទួលស្គាល់នូវពាក្យសុំការចាត់ចែងរក្សាការពារក្នុងតុលាការតែមួយបាន។ ដូចនេះ តើដីកាបែបនេះ វាមិនស្របគ្នានឹង "សេចក្តីសម្រេចបញ្ចប់រឿងក្តី" មែនដែរឬទេ ដូចដែលមានចែងក្នុងមាត្រា ៦៥(១)?

២- ទាក់ទងនឹងចំណុច(១)ខាងលើ

នៅប្រទេសជប៉ុន មានមតិយោបល់ច្រើនយ៉ាង ប៉ុន្តែការបកស្រាយដែលមានឧត្តមភាពក្នុងការអនុវត្តជាក់ស្តែង គឺ ដោយសារ"នីតិវិធីចាត់ចែងរក្សាការពារ" និង "បណ្តឹងអង្គសេចក្តី" ជានីតិវិធីខុសគ្នា សោហ៊ុយសំរាប់នីតិវិធីសំរាប់ចាត់ចែងរក្សាការពារ មិនគួរបញ្ចូលក្នុងបន្ទុកនៃប្រាក់ប្រដាប់ក្តីក្នុងបណ្តឹងអង្គសេចក្តីទេ ហើយសោហ៊ុយសំរាប់នីតិវិធីគប្បីចែងដាច់ ដោយឡែកក្នុងនីតិវិធីចាត់ចែងរក្សាការពារ ។

ក្នុងករណីកូនបំណុលទទួលបន្ទុកសោហ៊ុយសំរាប់នីតិវិធី ផ្អែកលើដីកាសម្រេចចាត់ចែងរក្សាការពារ ហើយក្រោយមក សេចក្តីសម្រេចក្នុងអង្គសេចក្តីបញ្ច្រាស់មកវិញ កូនបំណុលអាចទាមទារសំណងពីម្ចាស់បំណុល ដោយគិតរួមទាំងសោហ៊ុយសំរាប់នីតិវិធីដែលខ្លួនបានចំណាយផងដែរ ដោយសារម្ចាស់បំណុលដាក់ពាក្យសុំចាត់ចែងរក្សាការពារដោយខុសច្បាប់ ។

៣-　ទាក់ទងនឹងចំណុច(២)ខាងលើ

១.　នៅប្រទេសជប៉ុន តាមទស្សនៈនៃចំនុចទី ២ ខាងលើ គេអនុវត្តដូចខាងក្រោមៈ

ក-　នៅពេលដែលសេចក្តីសម្រេចលើកចោលពាក្យសុំចាត់ចែងរក្សាការពារ ត្រូវបានធ្វើឡើង សេចក្តីសម្រេចនោះ ត្រូវកំណត់បន្ទុកនៃសោហ៊ុយសំរាប់នីតិវិធី (បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចអាចធ្វើឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ ហេតុដូចនេះហើយបានជាការសម្រេចនេះ គឺស្រប គ្នានឹង"ការសម្រេចបញ្ចប់រឿងក្តី" យោងមាត្រា ៥៤៤) ។

ខ-　នៅពេលដែលដីកាសម្រេចទទួលស្គាល់នូវពាក្យសុំចាត់ចែងរក្សាការពារ ត្រូវបានធ្វើឡើង ដីកានោះមិនត្រូវកំណត់បន្ទុកនៃសោហ៊ុយសំរាប់នីតិវិធីទេ (ការប្តឹងតវ៉ាចំពោះដីកានេះអាចធ្វើទៅកាន់តុលាការដែលបានចេញដីកានេះ ដូចនេះហើយ ដីកានេះមិនស្របនឹង "សេចក្តីសម្រេចបញ្ចប់រឿងក្តី"ឡើយ យោងតាមមាត្រា ៥៥០) ។

គ-　នៅពេលដែលដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះការចាត់ចែងរក្សាការពារ ត្រូវបានធ្វើឡើង ដីកានោះត្រូវកំណត់បន្ទុកនៃសោហ៊ុយសំរាប់នីតិវិធី (ការប្តឹងជំទាស់ចំពោះដីកានេះ អាចធ្វើទៅកាន់តុលាការជាន់ខ្ពស់ ដូចនេះហើយ ដីកានេះស្របនឹង"សេចក្តីសម្រេចបញ្ចប់រឿងក្តី" យោងតាមមាត្រា ៥៦១) ។

២.　ក៏ប៉ុន្តែ ទាក់ទងនឹងការអនុវត្តចំណុច(ខ)ខាងលើ គេមិនចេះតែប្តឹងជំទាស់ចំពោះដីកាសម្រេចទទួលស្គាល់ពាក្យសុំចាត់ចែងរក្សាការពារឡើយ។ ក្នុងករណីនេះ ការកំណត់បន្ទុកនៃសោហ៊ុយសំរាប់នីតិវិធីត្រូវទុកចោលមិនសម្រេច ។ ដើម្បីជៀសវាងនូវស្ថានភាពបែបនេះ គេបកស្រាយថា វាជារឿងសមហេតុផលដែលថា ដីកាសម្រេចទទួលស្គាល់ពាក្យសុំចាត់ចែងរក្សាការពារត្រូវកំណត់បន្ទុកនៃសោហ៊ុយសំរាប់នីតិវិធី ។

២៣- តើចាំបាច់ត្រូវតែបញ្ជូន ឬជូនដំណឹងដល់កូនបំណុលអំពីសេចក្តីសម្រេចលើកចោលពាក្យសុំ ចាត់ចែងរក្សាការពារ ឬ សេចក្តីសម្រេចលើកចោលបណ្តឹងជំទាស់នឹងសេចក្តីសម្រេចនេះ ដែរឬទេ?

១- ការរៀបចំបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី

មាត្រា ៥៤៣ ដែលចែងថា "តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី " មិនអនុវត្តចំពោះសេចក្តីសម្រេចលើកចោលពាក្យសុំចាត់ចែងរក្សាការពារទេ ។ ក្រមនីតិវិធីរដ្ឋប្បវេណី បែងចែកដាច់ដោយឡែករវាងពាក្យ "ដីកាសម្រេចចាត់ចែងរក្សាការពារ" ពីពាក្យ "សេចក្តីសម្រេចលើកចោលពាក្យសុំចាត់ចែងរក្សាការពារ" ហើយការបែងចែកនេះ គឺបង្ហាញឃើញយ៉ាងច្បាស់ បើប្រៀបធៀបបញ្ញត្តិនៃមាត្រា ៥៥០ (ពាក្យសុំ តវ៉ាចំពោះដីកាសម្រេចរក្សាការពារ) និង មាត្រា ៥៤៤ (បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល) ។

ដូចនេះ សំណួរនេះស្ថិតក្រោមបញ្ញត្តិនៃមាត្រា ២១៣(១) (ជំពូក ២) ដែលចែងថា "ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ" ហើយមាត្រា ៥៣៩ ចែងថា "បញ្ញត្តិពីគន្ថីទី២ ដល់ គន្ថីទី៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។"

២- ការសាកសួរ

"ការអនុវត្តដូចគ្នា" (មាត្រា ៥៣៩) មានន័យថា " យកបញ្ញត្តិស្តីអំពីចំណុចណាមួយទៅអនុវត្តចំពោះចំណុចផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នា ដោយមានការកែសំរួលខ្លះៗដែលចាំបាច់" ។ ដូចនេះ ទាក់ទងនឹងសំណួរនេះ គេអាចចោទសួរថាតើចាំបាច់ដែរឬទេក្នុងការកែសំរួលមាត្រា ២១៣(១) នៅពេលយកវាទៅអនុវត្តចំពោះសេចក្តីសម្រេចលើកចោលពាក្យសុំចាត់ចែងរក្សាការពារ ឬសេចក្តីសម្រេចលើកចោលបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចនោះ (ខាងក្រោយទៀត ចំពោះសេចក្តីសម្រេចទាំងពីរនេះ យើងប្រើពាក្យ "សេចក្តីសម្រេចលើកចោល" ។ សរុបមក ការកែសំរួល គឺចាំបាច់ដូចខាងក្រោម ។

ដំបូង គេបកស្រាយថា ក្នុងករណីកូនបំណុលមិនត្រូវបានគេកោះហៅចូលរួមនីតិវិធីទាញហេតុផលដោយ ផ្ទាល់មាត់ ឬ ការសាកសួរមុនពេលចេញសេចក្តីសម្រេចលើកចោល តុលាការមិនត្រូវជូនដំណឹងកូនបំណុលអំពី សេចក្តីសម្រេចលើកចោលនេះទេ ដោយសារហេតុផលពីរយ៉ាងដូចខាងក្រោមៈ

១. សេចក្តីសម្រេចលើកចោល មិនបំពានលើសិទ្ធិកូនបំណុលទេ ដូចនេះ កូនបំណុលមិនមានសិទ្ធិពាក់ពន្ធ័នឹងការធ្វើបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចនេះឡើយ ។

២. សំណុំរឿងពាក្យសុំចាត់ចែងរក្សាការពារភាគច្រើនដែលគេមិនកោះហៅកូនបំណុលឱ្យចូលរួមនីតិវិធី ទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរ ចាំបាច់ត្រូវជំនុំជំរះដោយសំងាត់ ហើយប្រសិនបើគេជូនដំណឹងអំពី សេចក្តីសម្រេចលើកចោលនេះ ដល់កូនបំណុល គេបារម្ភខ្លាចថាម្ចាស់បំណុលអាចត្រូវគេរាំងមិនឱ្យដាក់ពាក្យសុំចាត់ចែងរក្សាការពារម្តងទៀត នៅពេលរៀបចំឯកសារចាំបាច់ ។

ផ្ទុយទៅវិញ គេបកស្រាយថាក្នុងករណីកូនបំណុលត្រូវបានគេកោះហៅចូលមកជំនុំជំរះមុនពេលចេញសេចក្តីសម្រេចលើកចោល គេត្រូវជូនដំណឹងដល់កូនបំណុលអំពីសេចក្តីសម្រេចនោះ ដូចមានចែងក្នុងមាត្រា ២១៣(១) ។ ដោយហេតុថាក្នុងករណីនេះគេមិនទាមទារឱ្យ មានភាពសំងាត់ទេ ពីព្រោះកូនបំណុលដែលគេកោះហៅចូលមកជំនុំជំរះ គឺបានដឹងអំពីពាក្យសុំចាត់ចែងរក្សាការពារនោះ ហើយត្រៀមខ្លួនចំពោះពាក្យសុំនោះ នៅពេលក្រោយទៀតដោយឥតបានការ លុះត្រាតែគេជូនដំណឹងអំពីសេចក្តីសម្រេចលើកចោល ។

៣- សន្និដ្ឋាន

មានការបកស្រាយថា ការជូនដំណឹងគឺជារឿងចាំបាច់នៅពេលគេកោះហៅកូនបំណុលចូលមកជំនុំជំរះ មុនពេលចេញសេចក្តីសម្រេចលើកចោល ហើយមិនមានការចាំបាច់ទេ នៅពេលកូនបំណុលមិនត្រូវបានកោះហៅ ។

ចំពោះម្ចាស់បំណុលវិញ ការជូនដំណឹង គឺជារឿងចាំបាច់ក្នុងគ្រប់ករណីទាំងអស់ ។

២៤- តុលាការបានចេញដីកាសម្រេចទទួលស្គាល់នូវពាក្យសុំចាត់ចែងរក្សាការពារមួយចំណែក ហើយលើកចោលផ្នែកដែលនៅសេសសល់ ។ តើតុលាការគួរបញ្ជូនដីកាសម្រេចនេះដែរឬទេ?

ក្នុងករណី តុលាការចេញដីកាសម្រេចដែលគាំទ្រនូវពាក្យសុំចាត់ចែងរក្សាការពារមួយចំណែក ហើយលើកចោលផ្នែកដែលនៅសេសសល់ ដីកាសម្រេចនេះត្រូវតែបញ្ជូនទៅភាគីទាំងពីរ ។ ដោយហេតុថា ដីកាសម្រេចនេះបង្គាប់ការចាត់ចែងរក្សាការពារមួយផ្នែក ដូចនេះដីកាបែបនេះ ត្រូវបានគេចាត់ទុកថាជា "ដីកាសម្រេចចាត់ចែងរក្សាការពារ" តាមមាត្រា ៥៤៣ ។

| |
|---|
| ២៥- ក្នុងករណីចៅក្រមបានចេញដីកាសម្រេចចាត់ចែងរក្សាការពារ ហើយក្រោយមកទៀតទើបរកឃើញកំហុសក្នុងការសម្រេចចិត្ត តើចៅក្រមអាចលុបចោល ឬកែប្រែដីកាសម្រេចនោះ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនបានដែរឬទេ? |

១- ទាក់ទងនឹងអត្តពន្ធភាពនៃការកាត់ក្តី

តាមគោលការណ៍ នៅពេលដែលការកាត់ក្តីបានធ្វើឡើងហើយ ចៅក្រមដែលបានកាត់ក្តីនោះ ត្រូវគោរពតាមការកាត់ក្តីរបស់ខ្លួន និងក្រោយមកទៀតមិនអាចលុបចោល ឬកែប្រែខ្លឹមសាររបស់វាបានទេ ។

២- ទាក់ទងនឹង"សាលក្រម" មាត្រា ១៩១ ចែងអំពីអត្តពន្ធភាពនៃសាលក្រម ហើយមានតែមាត្រា ១៩២ ស្តីអំពី "ការកែតម្រូវ" ទេ ដែលមានចែងករណីដែលអាចលុបចោល ឬកែប្រែសាលក្រមនៅពេលក្រោយបាន ។

ផ្ទុយទៅវិញ ទាក់ទងនឹង "ដីកាសម្រេច" ការបកស្រាយអំពីអត្តពន្ធភាព គឺមិនសូវតឹងតែងដូចជាអត្តពន្ធភាពនៃ"សាលក្រម"ទេ ហើយមានបញ្ញត្តិចែងថាដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធី អាចលុបចោលនៅពេលណាក៏បាន ( មាត្រា ២១៤, ៥៣-៣ និង ៥៨-២) ។ ទាក់ទងនឹងដីកា សម្រេចដែលមិនមានច្បាប់ ចែងដូចខាងលើ មានការពិភាក្សាគ្នាថាតើត្រូវអនុញ្ញាតការ លុបចោល ឬកែប្រែសេចក្តីសម្រេចបែបនេះពេលក្រោយបានដែរឬទេ ។ នៅប្រទេសជប៉ុន ក្នុងបញ្ញត្តិច្បាប់ដែល មានលក្ខណៈស្រដៀងគ្នានេះ គេបកស្រាយថា សេចក្តីសម្រេចខ្លះដែលមិនមានច្បាប់ដូចខាងលើចែង អាចត្រូវគេលុបចោលឬកែប្រែនៅពេលក្រោយបាន អាស្រ័យលើ លក្ខណៈនៃសេចក្តីសម្រេចទាំងនោះ ។

៣- ទាក់ទងនឹងដីកាសម្រេចចាត់ចែងរក្សាការពារ ដោយហេតុថាលទ្ធភាពលុបចោលឬកែប្រែអាចត្រូវគេសំរេច ដោយផ្អែកលើលក្ខណៈរបស់វា គេគួរតែធ្វើការពិចារណានូវស្ថានភាពដូចខាងក្រោមអោយ បានទូលំទូលាយៈ

១. ស្ថេរភាពផ្លូវច្បាប់ ភាពចាំបាច់ក្នុងការការពារភាគីដែលដីកាសម្រេចគាំទ្រ ភាពចាំបាច់ក្នុងការរក្សាការពារ ឆន្ទានុសិទ្ធិនៃការកាត់ក្តី អត្ថិភាពនីតិវិធីដែលគេប្រើសំរាប់ការតវ៉ា ដូចជាការតវ៉ាចំពោះការចាត់ចែងរក្សាការពារ ការលុបចោលដីកាសម្រេចរក្សាការពារ ជាអាទិ៍ និង

២. ការកាត់បន្ថយសោហ៊ុយសំរាប់នីតិវិធី និង បន្ទុកករណីបណ្តឹងឧទ្ធរណ៍ លទ្ធភាពលើកកំពស់ឆន្ទានុសិទ្ធិនៃការកាត់ក្តីតាមរយៈចៅក្រមកែលំអរខ្លួនដោយខ្លួនឯង ក្នុងករណីមានកំហុសច្បាស់លាស់ ភាពចាំបាច់រក្សា ការពារដែលត្រូវធ្វើជាបន្ទាន់ ។

មតិផ្ទាល់របស់អ្នកនិពន្ធមានដូចតទៅ:

ដីកាសម្រេចចាត់ចែងរក្សាការពារ គឺដូចគ្នាច្រើននឹងសាលក្រម ដោយសារវាវិនិច្ឆ័យលើទំនាក់ទំនងផ្នែកសារធាតុនៃកម្មវត្ថុដែលមានវិវាទ ទោះបីជាមានលក្ខណៈសាកល្បងក៏ដោយ ហើយនីតិវិធីអនុវត្តដោយបង្ខំធ្វើឡើងដោយផ្អែកលើដីកាសម្រេច ។ ហេតុនេះហើយ គួរតែបកស្រាយថា អត្តពន្ធភាពនៃដីកាសម្រេចចាត់ចែងរក្សាការពារ គឺមានឥទ្ធិពលខ្លាំង ។ ទោះបីជាចៅក្រមរកឃើញថាមានកំហុសក៏ដោយ ចៅក្រមគួររងចាំរហូតដល់មានបណ្តឹងតវ៉ាចំពោះដីកានេះ ហើយចៅក្រមខ្លួនឯងមិនអាចលុប ឬកែប្រែវាបានទេ ។

| |
|---|
| ២៦- នៅពេលដែលពាក្យតវ៉ាចំពោះការចាត់ចែងរក្សាការពារត្រូវបានដាក់មក តើចៅក្រមរូបណាទទួលបន្ទុកជំរះក្តី ជាចៅក្រមដែលចេញដីកាសម្រេចមុនដំបូងគេ ឬចៅក្រមផ្សេងទៀត? |

១- មានបញ្ញត្តិចែងថា កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារទៅតុលាការដែលចេញដីកាសម្រេចនោះ (មាត្រា ៥៥០) ហើយ ពាក្យសុំតវ៉ានេះត្រូវធ្វើទៅកាន់តុលាការដែលជាស្ថាប័នសាធារណៈដែលទទួលបន្ទុក (ឧទាហរណ៍ "តុលាការក្រុងភ្នំពេញ" ជាអាទិ៍)

របៀបជ្រើសចៅក្រមទទួលបន្ទុកជំរះក្តីការតវ៉ានេះដែលយកចេញពីចំណោមចៅក្រមទាំងឡាយ របស់តុលាការដែលគេដាក់ពាក្យសុំតវ៉ានោះ គឺត្រូវសំរេចទៅតាមវិធីបែងចែករឿងក្តីដែលមានកំនត់ទុកជាមុន(មាត្រា ២៦) ។

២- ដូចនេះ មានសំណួរលើកឡើងថាតើត្រូវកំណត់ការបែងចែករឿងក្តីដោយវិធីណា?
ដោយហេតុថា ក្រមនីតិវិធីរដ្ឋប្បវេណីមិនមានបញ្ញត្តិចែងទាក់ទងនឹងសំណួរនេះ មិនមានសំណួរចោទឡើងអំពីបញ្ហានីត្យានុកូលភាពទេ មិនខ្វល់ថានរណាជាអ្នកទទួលបន្ទុករឿងក្តីទេ ។
តាមទស្សនៈទាញចេញពីការសំរេចដ៏ត្រឹមត្រូវ មានមតិពីរលើកឡើងដូចខាងក្រោមៈ

១. ដោយសារវាមានចរិតលក្ខណៈជានីតិវិធីបណ្តឹងឧបាស្រ័យ វាជាការប្រសើរប្រសិនបើចៅក្រមផ្សេងពីចៅក្រមដែលបានចេញដីកាសម្រេចចាត់ចែងរក្សាការពារ ទទួលបន្ទុកការជំនុំជំរះក្តីការតវ៉ាដើម្បីងាយស្រួលទទួលបាននូវការយល់ព្រមពីកូនបំណុល ។

២. ដោយសារតែវាមិនមែនជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ប៉ុន្តែវាជាពាក្យសុំតវ៉ា នៅក្នុងតុលាការដដែលនេះ ហើយការវិនិច្ឆ័យមានលក្ខណៈបន្តពីការវិនិច្ឆ័យគ្រាកន្លងមក ជាការប្រសើរបើចៅក្រមដែលចេញដីកាសម្រេចចាត់ចែងរក្សាការពារ ទទួលបន្ទុកការជំរះក្តីការតវ៉ា ។

៣- នៅប្រទេសជប៉ុន ក្នុងស្ថានភាពបញ្ញត្តិច្បាប់ស្រដៀងគ្នានេះ វិធីសាស្រ្តបែងចែករឿងក្តី គឺគេកំណត់ឡើងភាគច្រើនចៅក្រមផ្សេងទទួលបន្ទុកការវិនិច្ឆ័យបណ្តឹងតវ៉ានេះ (ដូចចំណុចទី១ ខាងលើ) ។

ផ្ទុយទៅវិញ ក៏មានករណីដែលគេកំណត់ឱ្យក្រុមប្រឹក្សាជំនុំជំរះដដែលជាអ្នកចាត់ការបណ្តឹងតវ៉ាចំពោះការចាត់ចែងរក្សាការពារ នៅពេលក្រុមប្រឹក្សាជំនុំជំរះនោះជាអ្នកចេញដីកាចាត់ចែងរក្សាការពារ

ឬនៅពេលដែលពាក្យសុំតវ៉ាចំពោះការចាត់ចែងរក្សាការពារត្រូវគេធ្វើឡើងចំពេលបណ្ដឹងអង្គសេចក្ដីកំពុងប្រព្រឹត្តទៅ ចៅក្រមដែលទទួលបន្ទុកបណ្ដឹងអង្គសេចក្ដី ត្រូវទទួលបន្ទុកករណីតវ៉ានេះ។ ដូចនេះ គេមិនជ្រើសតែវិធីសាស្ត្រទីមួយខាងលើជានិច្ចនោះទេ ។

នេះគឺជាបញ្ហាដែលគួរតែធ្វើការសំរេចដោយផ្អែកលើស្ថានភាពជាក់ស្ដែងក្នុងប្រទេសកម្ពុជា ។

៤- ទាក់ទងនឹងចៅក្រមដែលទទួលបន្ទុកពាក្យសុំលុបចោលការចាត់ចែងរក្សាការពារដែលមានចែងក្នុងមាត្រា ៥៥៨ និង ៥៥៩ គេអនុវត្តទ្រឹស្ដីស្ទើរតែដូចគ្នាសុទ្ធសាធនឹងទ្រឹស្ដីខាងលើនេះ ចំពោះករណីនេះ ។

២៧- ទាក់ទងនឹងការដាក់ពាក្យសុំការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ប្រសិនបើ តុលាការចេញដីកាសម្រេចក្រោយពេលសាកសួរ ( មាត្រា ៥៤៨ កថាខណ្ឌ ៤) ហើយបន្ទាប់មកទៀតមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ ក្នុងករណីនេះតើចាំបាច់ត្រូវរៀបចំការសាកសួរម្តងទៀតដែរឬទេក្នុងពេលតវ៉ានេះ ( មាត្រា ៥៥២) ?

១.ការសាកសួរត្រូវធ្វើសារជាថ្មីនៅពេលវិនិច្ឆ័យអំពីពាក្យសុំតវ៉ាចំពោះការចាត់ចែងជាបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា ៥៥២ ។

២.នៅប្រទេសជប៉ុន មានករណីជាច្រើនដែលចៅក្រមទទួលបន្ទុកចាត់ការរឿងដីកាសម្រេចចាត់ចែងរក្សាការពារ និងចៅក្រមទទួលបន្ទុកវិនិច្ឆ័យអំពីការតវ៉ា ផ្សេងគ្នា ទោះបីជាចៅក្រមទាំងនេះស្ថិតនៅក្នុងតុលាការតែមួយក៏ដោយ ។ ក្នុងករណីនេះ គេត្រូវធ្វើការសាកសួរសារជាថ្មី ។

៣.គេអាចនិយាយបានថា ទោះបីចៅក្រមចេញដីកាចាត់ចែងរក្សាការពារ និងចៅក្រមវិនិច្ឆ័យអំពីពាក្យសុំតវ៉ាជាមនុស្សតែ មួយក៏ដោយ ចាំបាច់ត្រូវតែធ្វើការសាកសួរសារជាថ្មីទៀត ។

ផ្នែកតាមច្បាប់ នៅពេលវិនិច្ឆ័យអំពីពាក្យសុំតវ៉ា យ៉ាងហោចណាស់ត្រូវរៀបចំការសាកសួរឱ្យបានម្តងតាមវិធីតទល់គ្នា ( មាត្រា ៥៥២) តែផ្ទុយទៅវិញមិនមានបញ្ញត្តិដូច្នេះទេចំពោះដំណាក់កាលចេញដីកាចាត់ចែងជាបណ្តោះអាសន្ន ហើយចៅក្រមអាចស្តាប់ម្ចាស់បំណុល និងកូនបំណុលដោយឡែក។ លើសពីនេះទៀត ក្នុងដំណាក់កាលវិនិច្ឆ័យអំពីពាក្យសុំតវ៉ា ចាំបាច់ត្រូវកំណត់អំពីការបញ្ចប់ការវិនិច្ឆ័យ ( មាត្រា ៥៥៣)តែចំពោះការចេញដីកាសម្រេចវិញ មិនមានបញ្ញត្តិដូចនេះទេ ។

តាមការអនុវត្ត នៅក្នុងការវិនិច្ឆ័យដើម្បីចេញដីកា គេចាំបាច់ត្រូវការនូវដីកាសម្រេចប្រញាប់ ហើយករណីបែបនេះមានច្រើន ឧទាហរណ៍ដូចជាករណីដែលដីកាសម្រេចធ្វើឡើងដោយសាកសួរម្ចាស់បំណុល និង កូនបំណុលដាច់ដោយឡែក ។
ដូចដែលបានពន្យល់ខាងលើ បញ្ញត្តិច្បាប់ទាមទារឱ្យមានការវិនិច្ឆ័យប្រុងប្រយ័ត្នចំពោះការវិនិច្ឆ័យអំពីពាក្យសុំតវ៉ាជាងដំណាក់កាលចេញដីកាសម្រេច ហើយក្នុងករណីជាច្រើន ចាំបាច់ត្រូវបញ្ចូលនីតិវិធីធម្មតា ក្នុងដំណាក់កាលចេញដីកា ។ ហេតុដូច្នេះហើយ ចាំបាច់ត្រូវធ្វើការសាកសួរក្នុងការវិនិច្ឆ័យអំពីពាក្យសុំតវ៉ា ។

៤.ក្នុងករណីខ្លះ ការសាកសួរត្រូវបានគេរៀបចំបានគ្រប់គ្រាន់ហើយក្នុងដំណាក់កាលចេញដីកាសម្រេច ហើយការធ្វើអំណះអំណាងដូចគ្នា អាចត្រូវបានលើកឡើងសារថ្មីក្នុងពេលវិនិច្ឆ័យការតវ៉ា ។ ក្នុងករណីនេះ គេអាចរៀបចំយ៉ាងខ្លីក្នុងការបញ្ចប់ការសាកសួរ និង ចេញដីកាសម្រេចចំពោះពាក្យសុំតវ៉ានោះ ។

២៨-
តើត្រូវសរសេរខ្លឹមសារសំខាន់នៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះការចាត់ចែងរក្សាការពារដោយវិធីណា ?

ការសរសេរខ្លឹមសារសំខាន់ៗនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះការចាត់ចែងរក្សាការពារ គឺធ្វើដូច ខាងក្រោម :

"ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារ ដែលចេញដោយតុលាការ កក នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០០៨ ដែលសម្រេចអំពីរឿងក្តីចាត់ចែងរក្សាការពារ (សំណុំរឿងលេខ ៩៩៩) រវាងម្ចាស់បំណុល ក និង កូនបំណុល ខ ត្រូវបានទទួលស្គាល់ ។"

យោងតាមមាត្រា ៥៥៤(១) នៅពេលដែលតុលាការសំរេចរក្សាទុកការសន្និដ្ឋាននៃដីកាសម្រេចចាស់ តុលាការត្រូវទទួលស្គាល់ដីកាចាស់នោះ។ ប៉ុន្តែ តុលាការមិនត្រូវលើកចោលពាក្យសុំតវ៉ាឡើយ ។ ដោយសារ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចកន្លងមក គឺគេចាត់ទុកថាជាពាក្យសុំរបស់កូនបំណុលសុំឱ្យតុលាការធ្វើនីតិវិធី ទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរ ដែលភាគីទាំងសងខាងអាចចូលរួមបាន និង ពិនិត្យមើលដីកា សម្រេចកន្លងមកដែលចេញដោយមិនមានការរៀបចំនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរ ។

ដូច្នេះ នៅពេលដែលតុលាការសំរេចចិត្តរក្សាទុកដីកាសម្រេចមុន តុលាការមិនត្រូវលើកចោលពាក្យសុំ តវ៉ាចំពោះ ដីកាសម្រេចមុននេះទេ ប៉ុន្តែត្រូវចេញដីកាសម្រេចទទួលស្គាល់នូវដីកាសម្រេចមុន ។

ផ្ទុយទៅវិញ នៅពេលដែលតុលាការបានសំរេចលុបចោលនូវដីកាសម្រេចគ្រាមុន តុលាការត្រូវចេញនូវ ដីកាសម្រេចទីពីរ ដើម្បីផ្តល់អានុភាពថា តុលាការលើកចោលពាក្យសុំដែលធ្វើឡើងដោយម្ចាស់បំណុល ចំពោះ ដីកាសម្រេចគ្រាមុន ព្រមទាំងលុបចោលនូវដីកាសម្រេចគ្រាមុននោះ ។

២៩- សូមពន្យល់ខ្លឹមសារនៃមាត្រា ៥៩៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនបានដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) កថាខណ្ឌ២ ដែលចែងថា "អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌ១ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ សប្ដាហ៍ ។" តើនៅប្រទេសជប៉ុន ការអនុវត្តជាក់ស្ដែងចំពោះមាត្រានេះយ៉ាងដូចម្ដេចដែរ?

១.ក្នុងករណីដីកាសម្រេចរក្សាការពារបានចេញហើយ ហើយម្ចាស់បំណុលមិនបានដាក់ពាក្យបណ្ដឹងអង្គសេចក្ដីទេ កូនបំណុលអាចដាក់ពាក្យសុំលុបចោលដីការក្សាការពារបាន ស្របតាមមាត្រា ៥៩៧ កថាខណ្ឌ១ ។

តុលាការដែលទទួលនូវពាក្យសុំនេះត្រូវបង្គាប់ឱ្យម្ចាស់បំណុលចាត់ការរឿងដូចខាងក្រោមក្នុងរយៈពេលមួយដែលចាត់ទុកថាសមរម្យ ។

១.ដាក់ពាក្យបណ្ដឹងអង្គសេចក្ដី

២.ដាក់ឯកសារបញ្ជាក់ពីបណ្ដឹងអង្គសេចក្ដី ហើយមាត្រា ៥៩៧ កថាខណ្ឌ ២ ចែងថារយៈពេលដែលរៀបរាប់ខាងលើ គួរតែយ៉ាងហោចណាស់ឱ្យបាន ២ សប្ដាហ៍យ៉ាងតិច ។

២.បញ្ញត្តិនៃមាត្រា ៥៩៧ កថាខ័ណ្ឌ ២ មានគោលបំណងផ្ដល់ពេលវេលាដល់ម្ចាស់បំណុលក្នុងការរៀបចំបណ្ដឹងអង្គសេចក្ដី ។ ដោយសារតែពេលវេលាចាំបាច់សំរាប់រៀបចំ អាចខុសគ្នាទៅតាមរឿងក្ដីនីមួយៗ តុលាការអាចសម្រេចពីរឿងរយៈពេលចាំបាច់សំរាប់រៀបចំនេះដោយឆន្ទានុសិទ្ធិ ។ ក៏ប៉ុន្តែដោយសារតែមិនសូវមានភាពខុសគ្នាច្រើនរវាងពេលវេលាចាំបាច់សំរាប់រៀបចំពាក្យសុំដីកាសម្រេចរក្សាការពារ និងពេលវេលាចាំបាច់រៀបចំដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ប្រសិនបើតុលាការទទួលបាននូវឆន្ទានុសិទ្ធិទាំងស្រុងដូច្នេះ ពេលវេលាដែលតុលាការផ្ដល់ទៅឱ្យ ម្ចាស់បំណុលអាចខ្លីបំផុតប៉ុណ្ណោះ ។ ដូច្នេះហើយបានជាអ្នកច្បាប់ចែងក្នុងច្បាប់ "យ៉ាងហោចណាស់រយៈពេល ២ សប្ដាហ៍ ដើម្បីធានាពេលវេលាជាអប្បបរមាសំរាប់ម្ចាស់បំណុល ។

៣.ក្នុងការអនុវត្តជាក់ស្ដែង មិនមានការអនុញ្ញាតពេលវេលាយូរដូច្នេះទេ សំរាប់ការរៀបចំ ដោយពិចារណាថា មិនមានភាពខុសគ្នាច្រើនទេរវាងការរៀបចំសុំការរក្សាការពារ និង ការរៀបចំបណ្ដឹងអង្គសេចក្ដី ។ ឧទាហរណ៍ គេអាចផ្ដល់ពេលវេលារយៈពេល "មួយឆ្នាំ "នៅក្នុងច្បាប់ ប៉ុន្តែគេអាចបកស្រាយថាមិនសមហេតុផល ។

នៅតុលាការអូសាកា ជាទូទៅគេអនុញ្ញាតរយៈពេល "១៩ថ្ងៃ " ។ (១៤ ថ្ងៃ និង ៥ថ្ងៃ សំរាប់ ១.រៀបចំបណ្ដឹងអង្គសេចក្ដី) និង ២(២.ដាក់ឯកសារបញ្ជាក់ពីការរៀបចំបណ្ដឹងអង្គសេចក្ដី) ខាងលើ ។ ពតិមាននេះ

ទទួលបានតាមរយៈការសំភាសជាមួយនឹងចៅក្រមនៃតុលាការដែលនិយាយខាងលើ) ។ យោងតាមអត្ថបទនិពន្ធដោយចៅក្រមប្រចាំតុលាការតូក្យូ តុលាការនេះជាទូទៅអនុញ្ញាតរយៈពេល "មួយខែ" ។

៣០- តើ "សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ " ក្នុងដីកាសម្រេច រក្សាការពារចាំបាច់ត្រូវដូចគ្នានឹង"សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវទាមទារ"នៅក្នុងបណ្តឹងអង្គសេចក្តីដែរទេ?

១.នៅពេលបង្គាប់ឱ្យដាក់បណ្តឹងអង្គសេចក្តី (មាត្រា ៥៥៧-១.សូមមើលសំណួរទី ៣០ នៅក្នុងសៀវភៅនេះ) ម្ចាស់បំណុល ត្រូវដាក់បណ្តឹងអង្គសេចក្តី និង ដាក់ឯកសារបញ្ជាក់អំពីបណ្តឹងនោះក្នុងរយៈពេលកំណត់មួយ ។ បើមិនដូច្នោះទេ ដីការក្សា ការពារនឹងត្រូវលប់ចោល ។

ពេលខ្លះ ក៏មានករណីម្ចាស់បំណុលត្រូវការប្តូរសិទ្ធិនៅដំណាក់កាលដាក់បណ្តឹងអង្គសេចក្តី ដោយសារខ្វះពេលពិចារណាអំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ឬដោយសារការប្តូរស្ថានភាពក្រោយពេលដីការក្សាការពារចេញហើយ ។

ឧទាហរណ៍លោក ក បានដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នហាមឃាត់មិនអោយផ្ទេរការកាន់កាប់ចំពោះលោក ខ " ដោយមានសិទ្ធិទាមទារឱ្យប្រគល់ដីត្រឡប់មកវិញដោយផ្អែកលើការបញ្ចប់កិច្ចសន្យាជួល "ជាសិទ្ធិនឹងត្រូវបានរក្សាការពារ ហើយតុលាការបានទទួលស្គាល់ពាក្យសុំនោះ។ ប៉ុន្តែក្រោយពេលពិចារណាដោយល់អិតរួចមក លោក ក រកឃើញថា កិច្ចសន្យាជួលនេះមិនមានអត្ថិភាពតាំងពីដំបូងមកម្លេះ។ ហេតុដូច្នេះហើយលោក ក ចង់ដាក់ពាក្យបណ្តឹងអង្គសេចក្តីចំពោះលោក ខ ដោយផ្អែកលើ "សិទ្ធិទាមទារឱ្យប្រគល់ដីត្រឡប់មកវិញដោយផ្អែកលើកម្មសិទ្ធិ" ជាសិទ្ធិទាមទារ។

ក្នុងករណីទាំងនេះ ម្ចាស់បំណុលត្រូវដាក់បណ្តឹងអង្គសេចក្តីដោយផ្អែកលើ "សិទ្ធិទាមទារ" ខុសពី "សិទ្ធិដែលត្រូវរក្សាការពារ" ក្នុងដីការក្សាការពារ ។ បន្ទាប់មកទៀត បញ្ហាគឺត្រង់ថាតើគេអនុញ្ញាតនូវភាពខុសគ្នានេះត្រឹមកំរិតប៉ុណ្ណា ទាក់ទងនឹងការបង្គាប់ឱ្យដាក់បណ្តឹងអង្គសេចក្តីខាងលើ (ថាតើម្ចាស់បំណុលអាចជៀសផុតពីការលុបចោលការរក្សា ការពារដែរឬ តាមរយៈការដាក់បណ្តឹងអង្គសេចក្តីដោយផ្អែកលើ "សិទ្ធិទាមទារខាងក្រោយ"

២.នៅប្រទេសជប៉ុន គេបកស្រាយថា ភាពខុសគ្នារវាងសិទ្ធិដែលនឹងត្រូវបានរក្សាការពារ និងសិទ្ធិទាមទារ គឺគេអនុញ្ញាតត្រឹមកំរិតមួយដែលមាន"អត្តសញ្ញាណនៃការទាមទារ" រវាងសិទ្ធិទាំងពីរ ។ នេះគឺផ្អែកលើទស្សនៈដូចគ្នានឹងទំហំនៃ ការកែប្រែការទាមទារដែលគេអនុញ្ញាតក្នុងបណ្តឹងអង្គសេចក្តី (មាត្រា ៨៤) ។

ជាក់ស្តែង គេបកស្រាយថា ភាពខុសគ្នារវាងសិទ្ធិទាំងពីរត្រូវគេទទួលយកអោយតែបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

១.ផលប្រយោជន៍នៃសិទ្ធិពីមុន និង សិទ្ធិថ្មីក្នុងសង្គម ដូចគ្នា

២.សំណុំរឿងក្តីទាក់ទងនឹងសិទ្ធិពីមុន អាចយកមកប្រើប្រាស់បានច្រើនទាក់ទងនឹងសិទ្ធិថ្មី

| |
|---|
| ៣១- ក្រោយពេលដីកាសម្រេចអំពីការចាត់ចែងរក្សាការពារ បានចេញ ទាក់ទងនឹងវិវាទដីធ្លី កូនបំណុលដាក់ពាក្យសុំ "លុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ ដោយហេតុថា ម្ចាស់បំណុលមិនបានដាក់បណ្តឹងអង្គសេចក្តី" (មាត្រា ៥៩៧) ហើយបន្ទាប់មកម្ចាស់បំណុលដាក់ ពាក្យសុំសំរបសំរួល ឬ សុំសេចក្តីសម្រេចពីភ្នាក់ងាររដ្ឋបាល (ដូចជាគណៈកម្មការសុរិយោដី ជាអាទិ៍) ក្នុងករណីនេះ តើពាក្យសុំរបស់ម្ចាស់បំណុលអាចចាត់ទុកថាជាករណីបណ្តឹងអង្គសេចក្តី បាន ដែរឬទេ? |

១- នីតិវិធីចាត់ចែងរក្សាការពារ មានគោលបំណងការពារជាបណ្តោះអាសន្ននូវសិទ្ធិរបស់ម្ចាស់បំណុលដើម្បីកុំឱ្យ ម្ចាស់បំណុលរងការខូចខាតមុនពេលមានការសំរេច និង ប្រើប្រាស់សិទ្ធិរបស់គេដោយផ្អែកលើគំនិតថាម្ចាស់បំណុល នឹងចាត់វិធានការចាំបាច់ក្នុងការបង្កើតនូវសិទ្ធិរបស់ខ្លួន នៅពេលក្រោយទៀត ។ នៅពេលណាគេចេញនូវដីកា សម្រេចចាត់ចែងរក្សាការពារហើយ កូនបំណុលនឹងបង្កនូវគុណវិបត្តិនានាដូចជាបង្កើតនូវស្ថានភាពដែលទ្រព្យ សម្បត្តិរបស់គាត់ដាក់ស្ថិតក្រោមការរឹតត្បិត ។ ដូចនេះហើយ មាត្រា ៥៩៧ ផ្តល់វិធានការដល់កូនបំណុល ក្នុងការ ស្វែងរកការលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ នៅពេលម្ចាស់បំណុលមិនបានចាត់នីតិវិធីដើម្បីបង្កើតសិទ្ធិរបស់ខ្លួន ក្រោយពេលដែលទទួលបានដីកាបែបនេះ ។

ដោយវិនិច្ឆ័យពីខ្លឹមសារនៃបញ្ញត្តិនៃមាត្រា ៥៩៧ មានការបកស្រាយថា "បណ្តឹងអង្គសេចក្តី" មិនមានន័យជាចាំបាច់ថាជា បណ្តឹងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីប៉ុណ្ណោះទេ ហើយវានិយាយទាក់ទងនឹងនីតិវិធីកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ ប្រកបដោយអានុភាពអាជ្ញាអស់ជំនុំ (ប្រៀបធៀប មាត្រា ១៩៤) ។

២- ទាក់ទងនឹងសំណួរនេះ ចំលើយអាចខុសគ្នា អាស្រ័យលើប្រព័ន្ធដោះស្រាយជម្លោះដីធ្លីនៅកម្ពុជា ។ (អ្នកនិពន្ធ មិនអាចយល់ចំណុចលំអិតអំពីប្រព័ន្ធនោះទាំងស្រុងទេ ។ គេណែនាំឱ្យធ្វើការពិនិត្យមើលនូវទស្សនៈខាងក្រោម ដោយឆ្លុះបញ្ចាំងនូវស្ថានភាពជាក់ស្តែងនៅកម្ពុជា) ។

ក- ក្នុងប្រព័ន្ធដែលតម្រូវឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងបាន ទាល់តែក្រោយពេលឆ្លងកាត់នូវនីតិវិធីសំរបសំរួល ឬ ការសម្រេចក្តីហើយ ជាអាទិ៍ ដោយគណៈកម្មការសុរិយោដី ជាអាទិ៍ គេអាចបកស្រាយថា ការដាក់ពាក្យសុំសំរបសំរួល ឬសេចក្តីសម្រេច គឺគេចាត់ទុកថាជា "ការដាក់ពាក្យបណ្តឹងអង្គសេចក្តី" ដោយសារមូលហេតុពីរយ៉ាង : ទី១ ការដាក់ពាក្យសុំសំរបសំរួល សេចក្តីសម្រេច ជាអាទិ៍ របស់ម្ចាស់បំណុល មានន័យថា ម្ចាស់បំណុលបានធ្វើនូវ ជំហានទី ១នៃនីតិវិធីចាំបាច់ដើម្បីកំណត់នូវសិទ្ធិរបស់គេ និង ទី២ នៅពេលណាតុលាការបានបង្គាប់ឱ្យម្ចាស់បំណុលដាក់

ពាក្យបណ្ដឹងក្នុងកំឡុងពេលណាមួយជាក់លាក់   ការបង្គាប់បែបនេះអាចធ្វើឱ្យម្ចាស់បំណុលមិនអាច ធ្វើតាមបានលុះត្រាតែនីតិវិធីសំរបសំរួល សេចក្ដីសម្រេច ជាអាទិ៍ បានបញ្ចប់មុនពេលអាជ្ញាយុកាល ផុតកំណត់ ។

ខ-   ក្នុងករណីមានប្រព័ន្ធដែលអាចឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីសំរ បសំរួល ឬ សេចក្ដីសម្រេចដូចរៀបរាប់ខាងលើ គេគួរបកស្រាយថា ការដាក់ពាក្យសុំសំរបសំរួល ឬសេចក្ដីសម្រេច មិនអាច ចាត់ទុកថាជា "ការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី"ទេ ហើយម្ចាស់បំណុល ត្រូវដាក់ពាក្យបណ្ដឹងផ្ទាល់ចំពោះមុខតុលាការ ។ ដោយហេតុថា ដើម្បីឱ្យស្របតាមខ្លឹមសារនៃ មាត្រា៥៥៧ ដែលរៀបរាប់ខាងលើ ម្ចាស់បំណុលគួរតែចាត់វិធីនីតិវិធីចាំបាច់ឱ្យបានលឿនតាមដែល អាចធ្វើបាន ដើម្បីឱ្យកូនបំណុលរួចចាកពីស្ថានភាពមិននឹងនក្នុងតំណាក់កាលដំបូង ។

៣២- ករណីកូនបំណុលដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ តើការអនុវត្តការចាត់ចែងរក្សាការពារដែលកំពុងប្រព្រឹត្តទៅត្រូវផ្អាកដែរឬទេ?

ការអនុវត្ត មិនត្រូវផ្អាកជាស្វ័យប្រវត្តិនោះទេ ។ លុះត្រាតែនៅពេលណាកូនបំណុលដាក់ពាក្យសុំ ដូចមានចែងក្នុងមាត្រា ៥៥១(១) ហើយតុលាការចេញសេចក្ដីសម្រេចទទួលស្គាល់ពាក្យសុំនោះ ទើបការអនុវត្តចាត់ចែងរក្សាការពារដែលកំពុងប្រព្រឹត្តទៅត្រូវផ្អាក ឬលុបចោល ។ សំរាប់ពត៌មានលំអិត សូមមើលកំណត់នៃមាត្រាដែលបានលើកឡើង ។

៣៣- ក្នុងករណីដែលសេចក្ដីសម្រេចត្រូវបានធ្វើឡើងដោយទទួលស្គាល់ដីកាសម្រេចចាត់ចែងរក្សាការពារប្រឆាំង ចំពោះពាក្យសុំតវ៉ានឹងដីកាសម្រេចនេះ ហើយកូនបំណុលធ្វើបណ្ដឹងជំទាស់ចំពោះ សេចក្ដីសំរេចនេះ តើការអនុវត្តដីកាសម្រេចចាត់ចែងរក្សាការពារដែលកំពុងប្រព្រឹត្តទៅត្រូវផ្អាកដែរឬទេ?

ការអនុវត្តមិនត្រូវផ្អាកជាស្វ័យប្រវត្តិទេ ។ លុះត្រាតែនៅពេលណាកូនបំណុលដាក់ពាក្យសុំ ដូចមានចែងក្នុងមាត្រា៥៥១(១)ដែលអនុវត្តដូចគ្នាក្នុងមាត្រា៥៦១(៣) ហើយតុលាការចេញក្តីសម្រេចទទួលស្គាល់ ពាក្យសុំនោះ ទើបការអនុវត្តចាត់ចែងរក្សាការពារដែលកំពុងប្រព្រឹត្តទៅ ត្រូវផ្អាក ឬលុបចោល ។

៣៤- សូមផ្តល់ករណីគំរូអំពី "បើយល់ឃើញថាចាំបាច់ពិសេស" ក្នុងមាត្រា ៥៥៦ វាក្យខ័ណ្ឌ ។

១- នៅពេលចេញសេចក្តីសំរេចលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ ក្នុងការវិនិច្ឆ័យអំពីពាក្យសុំតវ៉ានឹងដីកាសម្រេចនេះ សេចក្តីសម្រេចនឹងមានអានុភាពលុះត្រាតែសេចក្តីសម្រេចនោះចូលជាស្ថាពរ (មាត្រា ៥៥៦) ។ ប៉ុន្តែមានបញ្ញត្តិចែងថា តុលាការអាចប្រកាសថាសេចក្តីសម្រេចមានអានុភាពភ្លាម បើសិនជាតុលាការយល់ឃើញ ថាចាំបាច់ពិសេស (មាត្រា ៥៥៦) ។

២- ជាគោលការណ៍ សេចក្តីសម្រេចនឹងមានអានុភាពភ្លាម លុះត្រាតែត្រូវបានជូនដំណឹង (មាត្រា ២១៣(១)) ។ ប៉ុន្តែ បើសិនជាសេចក្តីសម្រេចលុបចោលខាងលើ មានអានុភាពភ្លាម កូនបំណុលអាចចាត់ចែងកម្មវត្ថុភ្លាមៗបាន ក្រោយពេលចាត់នីតិវិធីលុបចោលការអនុវត្តការរក្សាការពារ ដោយមិនទុកឱ្យ ម្ចាស់បំណុលរកវិធានការស្តារនូវ កម្មវត្ថុនោះវិញបានទេ សូម្បីមានការសម្រេចផ្ទុយក្នុងបណ្តឹងជំទាស់ពេល ក្រោយក៏ដោយ ។

ដូចនេះ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល ខ្លឹមសារសំខាន់នៃមាត្រា ៥៥៦ ចែងថា សេចក្តីសម្រេចលុបចោលខាងលើ នឹងមិនមានអានុភាពភ្លាមឡើយតាមគោលការណ៍ ហើយអានុភាពនៃដីកា សម្រេចចាត់ចែងរក្សាការពារ នៅមានបន្តរហូតទាល់តែសេចក្តីសម្រេចលុបចោលស្ថាពរ ។

៣- ក្នុងករណីគេផ្តល់អត្ថិភាពដល់ផលប្រយោជន៍របស់កូនបំណុលទោះបីជាប៉ះពាល់ដល់ផលប្រយោជន៍ម្ចាស់-បំណុល ក៏ដោយ ជាការចាំបាច់ត្រូវបង្កើតឱ្យមានអានុភាពភ្លាមដល់សេចក្តីសម្រេចលុបចោល ដើម្បីរំដោះកូនបំណុល ពី ការអនុវត្តការចាត់ចែងរក្សាការពារ ។

ដូច្នេះហើយបានជាមានចែងនូវបញ្ញត្តិមាត្រា ៥៥៦ "នៅពេលតុលាការយល់ឃើញថាចាំបាច់ពិសេស" ដើម្បីផ្តល់អានុភាពភ្លាមៗដល់សេចក្តីសម្រេចលុបចោល ដើម្បីរំដោះកូនបំណុលពីការអនុវត្តការចាត់ចែងរក្សាការពារ ។ ចំពោះការបកស្រាយអំពី "នៅពេលតុលាការយល់ឃើញថាចាំបាច់ពិសេស" លក្ខខណ្ឌរំដោះកូនបំណុលចេញពីការអនុវត្តការចាត់ចែងរក្សាការពារ ដូចមានចែងក្នុងមាត្រា ៥៥១ អាចធ្វើជាចំណុចយោងបាន ។ មានន័យ ថា គេអាចបកស្រាយថា តុលាការអាចចាត់ទុកចាំបាច់ពិសេសក្នុងករណីជាច្រើន នៅពេលណាដែល: ១) មានស្ថានភាពច្បាស់លាស់ដែលបង្កើតជាសំអាងហេតុសំរាប់លុបចោលដីការសម្រេចចាត់ចែងរក្សាការពារ និង ២) មានការបារម្ភថាការអនុវត្តដីកាសម្រេច ចាត់ចែងរក្សាការពារ អាចបង្កនូវការខូចខាតដែលមិនអាចជួសជុលបានចំពោះកូនបំណុល ។

ជាក់ស្តែង ខាងក្រោមនេះជាឧទាហរណ៍ករណី១ខាងលើៈ

- នៅពេលបកស្រាយគតិយុត្តអំពីដីកាសម្រេចចាត់ចែងរក្សាការពារដំបូងគេឃើញ មានកំហុសច្បាស់លាស់

- នៅពេលគេរកឃើញថា ភស្តុតាងជាឯកសារដែលជាមូលដ្ឋានចេញដីកាសម្រេចរក្សាការពារ ជាឯកសារក្លែងបន្លំ ។

ខាងក្រោមនេះជាឧទាហរណ៍ករណី២ ខាងលើៈ

- នៅពេលណា ការបន្តនៃអនុវត្តចាត់ចែងរក្សាការពារ អាចបង្កឱ្យកូនបំណុលក្ស័យធន ។

- នៅពេលណា ការបន្តនៃអនុវត្តចាត់ចែងរក្សាការពារ អាចបង្កឱ្យជីវិតរបស់កូនបំណុលដួលរលំ ។

៣៥- តើមានករណីណាខ្លះដែលយើងអាចធ្វើដីកាសម្រេចចាត់ចែងរក្សាការពារ និង ដីកាសម្រេចអនុវត្តនៃដីកាសម្រេចចាត់ចែងរក្សាការពារនោះ ដោយតាមរយៈពាក្យសុំតែ១? ឧទាហរណ៍ តើគេអាចសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និងការអនុវត្តដីកាសំរេចនោះ ដោយគ្រាន់ធ្វើពាក្យសុំតែមួយបានដែរឬទេ?

មានរឿងវិវាទដូចខាងក្រោមៈ

នៅពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គេធ្វើបានតាមរបៀបចុះបញ្ជីអំពីការរឹបអូសដោយក្រឡាបញ្ជីតែម្យ៉ាងប៉ុណ្ណោះ (មាត្រា ៥៦៧) ។ អីចឹងហើយទើបមានអ្នកខ្លះនិយាយថា មិនចាំបាច់ឱ្យ ម្ចាស់បំណុលដាក់ពាក្យសុំមួយទៀតទេ ហើយអាចអនុញ្ញាតឱ្យម្ចាស់បំណុលដាក់ពាក្យសុំដីកាសម្រេច និង ការអនុវត្ត ដីកានោះ ក្នុងពេលជាមួយគ្នាបាន ។

ទាក់ទងនឹងចំណុចនេះ មានមតិពីរលើកឡើងៈ

១- ទីស្តីអវិជ្ជមានៈ មាត្រា ៥៣២(២) មាត្រា ៥៣៤(ច) និង មាត្រា៣៤៩(២) អនុវត្តដូចគ្នា តាមមាត្រា ៥៦៤ "ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ" គួរតែត្រូវបានដាក់ដាច់ដោយឡែកពី "ពាក្យសុំដីកាសម្រេច រឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុ" ។

ចំណោទបញ្ហា និង ដំណោះស្រាយ

១. គេត្រូវអនុវត្តនូវនីតិវិធីដ៏វែងខាងក្រោម ដែលវាផ្ទុយនឹងភាពចាំបាច់នៃនីតិវិធីចាត់ចែងរក្សាការពារ ដែលត្រូវធ្វើអោយបានលឿនៈ

"ការបញ្ជូនដីកាសម្រេច"-"ពាក្យសុំឱ្យអនុវត្ត"-"ការរៀបចំចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន"- "ការចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន"

- ➢ គេអាចជូនដំណឹងដល់ម្ចាស់បំណុលអំពីដីកាសម្រេចតាមរយៈទូរសព្ទ័នៅពេលបញ្ជូនដីកានោះ ។

២. ករណីដីកាសម្រេចអំពីការរឹបអូសជាបណ្ដោះអាសន្ន បានបញ្ជូនទៅឱ្យម្ចាស់បំណុល និង កូនបំណុល ក្នុងពេលប្រហាក់ប្រហែលគ្នា ( មាត្រា ៥៤៣) គេខ្លាចថាកូនបំណុលធ្វើការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ មុនពេលនីតិវិធី ចប់សព្វគ្រប់: "ពាក្យសុំឱ្យអនុវត្ត"-"ការរៀបចំចុះបញ្ជីការរឹបអូសជាបណ្ដោះអាសន្ន"-ការចុះបញ្ជីការរឹបអូសជា បណ្ដោះអាសន្ន" ។

- ដើម្បីកុំឱ្យមានស្ថានភាពនេះកើតឡើង គេអាចបញ្ជូនដីកាទៅម្ចាស់បំណុលមុនគេ ហើយពន្យាពេលការបញ្ជូនទៅកូនបំណុលជាបណ្ដោះអាសន្ន រហូតដល់ពេលការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន បានធ្វើរួចរាល់ហើយ ។

២- ទ្រឹស្ដីវិជ្ជមាន: តាមរយៈ "ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ" គេក៏អាចដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចនេះផងដែរ ដើម្បីត្រៀមលក្ខណៈចំពោះករណីពាក្យសុំមុន ត្រូវគេផ្ដល់ការយល់ព្រមនៅពេល អនាគត ។

ចំណោទបញ្ហា និង ដំណោះស្រាយ

១. ទ្រឹស្ដីនេះប្រឆាំងនឹងបញ្ញត្តិនៃមាត្រា ៥៦៤ និង មាត្រា ៣៤៩(២) ដែលចែងថាពាក្យសុំឱ្យ អនុវត្តត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ។

- ករណីគេអាចបំពេញនូវលក្ខខណ្ឌទាំងអស់នេះ គេអាចបកស្រាយថា តាមការពិចារណាភាពចាំបាច់ក្នុងការអនុវត្តនីតិវិធី ពាក្យសុំឱ្យអនុវត្តអាចធ្វើតាមរយៈពាក្យសុំដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ។

  ១- មានតម្រូវការខ្ពស់ជាពិសេសការអនុវត្តឱ្យបានលឿន និង ការអនុវត្តដោយសំងាត់ ។

  ២- ស្ថាប័នទទួលបន្ទុកចេញដីកាសម្រេចចាត់ចែងរក្សាការពារ ក៏ជាស្ថាប័នទទួលបន្ទុកអនុវត្តដីកានោះផងដែរ ។

  ៣- ខ្លឹមសារនៃការអនុវត្តការចាត់ចែងរក្សាការពារ គឺត្រូវច្បាស់លាស់ ។

២. បញ្ញត្តិច្បាប់ចែងមិនច្បាស់ថាប្រភេទចាត់ចែងរក្សាការពារណា ដែលគេអនុវត្តនូវទ្រឹស្តីនេះ ។

គេអាចបកស្រាយថា ទ្រឹស្តីនេះអនុវត្តចំពោះករណីទាំងឡាយណា ដែលបំពេញតាមតម្រូវការទាំងអស់ពីចំណុច(១)ដល់(៣)នៃចំណុច ១ខាងលើ ឬ និយាយម្យ៉ាងវិញទៀត "ការអនុវត្តការចាត់ចែងរក្សាការពារតាមវិធីចុះបញ្ជី ឬវិធីបញ្ជូនដីកាសម្រេចអំពីការចាត់ចែងរក្សាការពារទៅកាន់កូនបំណុលទី ៣ ឬ តតិយជនដែលដូចភាគី" ។ ឧទាហរណ៍ ទ្រស្តីនេះ គេអនុវត្តក្នុងករណីការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងអចលនវត្ថុ ករណីរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ជាអាទិ៍ ព្រមទាំងការរឹបអូសជាបណ្តោះ អាសន្នចំពោះអចលនវត្ថុ ។

នៅពេលចាប់ផ្តើម ជាការប្រសើរត្រូវជ្រើសរើសទ្រឹស្តីទី១ខាងលើ ដែលស្របតាមបញ្ញត្តិច្បាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ បើពិចារណាអំពីភាពចាំបាច់ជាក់ស្តែង ការបកស្រាយ និង ទ្រឹស្តីទី២ខាងលើ អាចមានលទ្ធភាពច្រើន ។ (នៅប្រទេសជប៉ុន បញ្ញត្តិច្បាប់ អាចបកស្រាយដូចចំណុចទី ២ ខាងលើបាន ) ។ ក្នុងករណីនេះ គេត្រូវចាប់អារម្មណ៍ចំពោះសេចក្តីណែនាំនៅពេលទទួលពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ ។ គឺថា ក្នុងករណីមានពាក្យសុំដែលបំពេញតាមលក្ខខណ្ឌពីចំណុច(១)ដល់(៣)នៃចំណុចទី២ ខាងលើ គេគួរណែនាំឱ្យដាក់ពាក្យសុំអនុវត្តដីកាសម្រេចនោះផងដែរ ហើយវាមានប្រយោជន៍ក្នុងការរៀបចំគំរូពាក្យសុំជាមុនសំរាប់អ្នកដាក់ពាក្យសុំ។ តាមខ្លឹមសារនៃពាក្យសុំត្រូវចែងដូចតទៅៈ" ហេតុនេះ ខ្ញុំសូមឱ្យមានការវិនិច្ឆ័យ ថា "ដើម្បីធានាការអនុវត្តសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ចំពោះកូនបំណុល ដូចដែលមានបញ្ជាក់ក្នុងបញ្ជីស្តីពីសិទ្ធិលើបំណុលដែលមានភ្ជាប់មកជាមួយ អចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលដូចដែលមានបញ្ជាក់នៅក្នុងបញ្ជីអចលនវត្ថុ ដែលមានភ្ជាប់មកជាមួយត្រូវធ្វើការរឹបអូសជាបណ្តោះអាសន្ន និងត្រូវស្នើសុំការអនុវត្តនូវការ រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុខាងលើនេះផងដែរ" ។

៣៦- ដីរបស់កូនបំណុលមិនបានចុះបញ្ជី បើសិនជាតុលាការចេញដីកាបង្គាប់ចាត់ចែងរក្សាការពារ តើតុលាការត្រូវធ្វើដូចម្តេច?

នីតិវិធីអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺមានចែងក្នុងមាត្រា ៥៦៧ មាត្រា ៤២០ ជាអាទិ៍ ប្រសិនបើដីដែលត្រូវរឹបអូសជាបណ្តោះអាសន្នមិនទាន់បានចុះបញ្ជីទេនោះ អញ្ជើងក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យ ស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីដីនោះ ព្រមទាំងចុះញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នផង ។

៣៧

១- តើការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើដោយរបៀបណា?

២- នៅពេលអចលនវត្ថុ ត្រូវគេរឹបអូសជាបណ្តោះអាសន្ន តើត្រូវបង្ខំកូនបំណុលឱ្យចាកចេញពីអចលនវត្ថុនោះដែរឬទេ? ឬ តើកូនបំណុលអាចជួលទ្រព្យសម្បត្តិនោះបានដែរឬទេ?

៣- តើការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមានអានុភាពអ្វីខ្លះ?

១- ទាក់ទងនឹង (១)

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៦៧(១)) ។ ដោយឡែក ក្រឡាបញ្ជីនៃតុលាការដែលចេញដីការឹបអូសជាបណ្តោះអាសន្ន ត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះដែលពាក់ព័ន្ធនឹងដីកា សម្រេចនោះ (មាត្រា ៥៦៧(២)ដល់(៤)និង មាត្រា ៤២០) ។

២- ទាក់ទងនឹង (២)

ខុសពីការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ (ប្រៀបធៀប មាត្រា ៥៦៥) ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មិនត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលាឡើយ ។ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នពុំត្រូវរារាំងកូនបំណុលក្នុងការប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុតាមវិធីប្រើធម្មតាឡើយ (មាត្រា ៥៦៧(៤) និង មាត្រា ៤២១(៣)) ។

ដូច្នេះ កូនបំណុលមិនត្រូវបានរារាំងពីការប្រើប្រាស់អចលនវត្ថុដែលមានវិវាទនោះទេ ហើយមិនចាំបាច់ចាកចេញឡើយ ។ លើសពីនេះទៀត ក្នុងករណីកូនបំណុលជួលអចលវត្ថុនោះទៅអ្នកផ្សេងមុនពេលអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ការជួលបន្តនៃអចលវត្ថុនេះមិនប្រឆាំងនឹងអានុភាពនៃការរឹបអូសជាបណ្តោះអាសន្នឡើយ ។

ផ្ទុយទៅវិញ ការជួលសារថ្មីនៃអចលវត្ថុដែលមានវិវាទទៅអ្នកដទៃក្រោយ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន មិនត្រូវចាត់ទុកដូចជាការប្រើប្រាស់ធម្មតានោះទេ ហើយវាប្រឆាំងនឹងអានុភាពនៃការរឹបអូស ជាបណ្តោះអាសន្ន បើទោះបីជាកិច្ចសន្យាជួលរវាងកូនបំណុល និង អ្នកជួល មានសុពលភាពក៏ដោយ ។ តែទោះជាយ៉ាងណាក៏ដោយ ក្នុងករណីម្ចាស់បំណុលឈ្នះក្តីក្នុងបណ្តឹងអង្គសេចក្តី

ពេលក្រោយទៀតក៏ដោយ ហើយចាប់ផ្តើមអនុវត្តនីតិ វិធីចំពោះអចលនវត្ថុនោះក៏ដោយ (មាត្រា ៤១៧ និង មាត្រាក្រោយទៀត) កិច្ចសន្យាជួលខាងលើ ត្រូវចាត់ទុកថាមិនមានសុពលភាពទេក្នុងនីតិវិធី ។ដូចនេះ អ្នកជួលមិនអាចតតាំង នឹងម្ចាស់បំណុល អ្នកទិញអចលនវត្ថុនោះ ជាអាទិ៍ ដោយប្រើសិទ្ធិជួល របស់ខ្លួនបានឡើយ ។

៣- ទាក់ទងនឹង (៣)

ត្រូវបង្គាប់កូនបំណុលកុំឱ្យចាត់ចែងអចលនវត្ថុដែលមានវិវាទ តាមរយៈការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។ មានន័យថា បើទោះបីជាកូនបំណុលក្រោយមកធ្វើទង្វើដូចជាការផ្ទេរអចលនវត្ថុដែលមានវិវាទ ឬ យកវាទៅដាក់ប្រាតិភោគ (ការចុះបញ្ជីអចលនវត្ថុនេះត្រូវតែទទួល) កូនបំណុលមិនអាចតតាំងនឹងម្ចាស់បំណុលដោយអានុភាពនៃទង្វើរបស់ខ្លួនឡើយ ។ ដូច្នេះ ដូចបានពន្យល់ខាងលើ នៅពេលដែលម្ចាស់បំណុល បានចាប់ផ្តើមនីតិវិធីអនុវត្តចំពោះអចលនវត្ថុនោះហើយ (មាត្រា ៤១៧ និង មាត្រាបន្ទាប់ទៀត) ទង្វើរបស់កូនបំណុលបែបនេះមិនត្រូវបានគេចាត់ទុកថាមានសុពលភាពទេ ។

៣៨- ហេតុអ្វីបានជា ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ជារឿង ចាំបាច់? តើអានុភាពនៃការអនុវត្តរបស់វាមានអ្វីខ្លះ?

១- ពិនិត្យមើលករណីគំរូខាងក្រោមដើម្បីងាយស្រួលពន្យល់

(ករណីគំរូ)

លោក‘ក ’ប្តឹងលោក ‘ខ ’ ឱ្យប្រគល់របស់ ហើយ លោក ‘ក ’ ឈ្នះក្តី ហើយសាលក្រមចូលជាស្ថាពរ ។ ប៉ុន្តែ នៅពេលដែល ‘ក ’ មានបំណងដាក់ពាក្យសុំអនុវត្តដោយបង្ខំ លោក ‘គ កាន់កាប់វត្ថុដែលមានវិវាទនោះ ។ តើ លោក ‘ក ’ អាចចាត់ការការអនុវត្តដោយបង្ខំនេះចំពោះលោក ‘គ ’ បានដែរឬទេ ដោយផ្អែកលើសាលក្រម ដែល សម្រេចឱ្យគាត់ឈ្នះនោះ ?

២- ក្នុងករណីគំរូនេះ បើសិនជា ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ មិនត្រូវបាន អនុវត្តមុនពេលដាក់ពាក្យបណ្តឹង :

ក- ប្រសិនបើ ‘គ ’ បានទទួលវត្ថុនោះពី ‘ខ’ នៅពេលបណ្តឹងរវាង ‘ក ’ និង ‘ខ ’ កំពុងចាត់ការ:

ក្នុងបណ្តឹងទាមទារឱ្យប្រគល់វត្ថុ
ទោះបីជាចុងចំលើយបានផ្ទេរវត្ថុដែលមានវិវាទនោះទៅឱ្យ តតិយជនក៏ដោយក្នុងអំឡុងពេលបណ្តឹងកំពុងចាត់ការ ដើមចោទអាចបន្តបណ្តឹងចំពោះចុងចំលើយ បាន (មាត្រា ៨៨(២))។ អានុភាពនៃសាលក្រមចំពោះចុងចំលើយ អាចបន្តរហូតដល់សន្តតិជន (អ្នកស្នងសិទ្ធិ ឬកាតព្វកិច្ច)របស់ចុងចំលើយ (មាត្រា ១៩៨ ចំណុច គ ) ហើយដើមចោទ អាច អនុវត្តដោយបង្ខំចំពោះ អ្នកស្នងរបស់ចុងចំលើយដែលជាកូនបំណុលនៃការអនុវត្តនោះ (មាត្រា ៣៥១(១)(គ)) ។ ក្នុងករណីនេះ ត្រូវផ្តល់ដល់ដើមចោទនូវរូបមន្តអនុវត្តពិសេសដោយភ្ជាប់ជាមួយ នឹងសាលក្រមដែលកាត់ឱ្យដើមចោទឈ្នះនោះ(មាត្រា ៣៥៦(២)និង(៣) ដើម្បីធ្វើការអនុវត្ត ដោយបង្ខំនោះជាមួយនឹងសន្តតិជន ដែលរៀបរាប់ខាងលើ ។

ដូចនេះ លោក ‘ក’ អាចចាត់ការនូវការអនុវត្តដោយបង្ខំចំពោះ លោក ‘គ ’បានតាមរយៈនីតិវិធីខាងលើ ។

ខ- ប្រសិនបើ ‘គ ’ ទទួលបានវត្ថុនោះ ពី ‘ខ ’ មុនពេលបណ្តឹងរវាងលោក ‘ក ’ និង ‘ខ ’ កំពុងចាត់ការ

ដោយសារគ្មានបញ្ញត្តិណាមួយនៃមាត្រា ៨៨(២) និង ១៩៨ ចំណុច គ មាត្រា ៣៥១-១ ចំណុច គ ដូចចែងក្នុងចំណុច ក ខាងលើ អនុវត្តចំពោះករណីនេះទេ លោក ‘ក ’ មិនអាចអនុវត្តដោយបង្ខំចំពោះ លោក ‘គ ’ បានទេ ។

គេបកស្រាយថា ចំណាត់ការបណ្តឹងចាប់ផ្តើមនៅពេលបញ្ជូនពាក្យបណ្តឹងដល់ចុងចំលើយ ។

គ- បើសិនជា ‘គ’បានចាប់ផ្តើមកាន់កាប់វត្ថុដែលមានវិវាទហើយ ដោយមិនមានទំនាក់ទំនងជាមួយនឹងលោក ខ ( អាចជាអ្នកកាន់កាប់ខុសច្បាប់ ជាអាទិ៍)

ដោយសារ គ មិនចូលក្នុងប្រភេទនៃសន្តតិជនរបស់លោក ខ គ្មានបញ្ញត្តិណាមួយនៃមាត្រា ១៩៨ ចំណុច គ និង ៣៥១(១) ចំណុច គ ដូចចែងក្នុងចំណុច ‘ក’ ខាងលើ អនុវត្តចំពោះករណីនេះទេ ហើយលោក‘ក’ មិនអាចអនុវត្តដោយបង្ខំចំពោះ លោក គ បានទេ ។ វាអនុវត្តបាន មិនថាពេលលោក ‘គ’បានចាប់ផ្តើមកាន់កាប់ មិនថាមុនពេល ឬក្រោយពេល បណ្តឹងរវាងលោក ‘ក’ និង ‘ខ’ ចូលនីតិវិធីចាត់ការនោះទេ ។

ឃ- ក្នុងករណី ចំណុច ក ខាងលើ បើសិនជា លោក ‘គ ’ មានសិទ្ធិតតាំងចំពោះលោក ក : ឧទាហរណ៍ករណីដែលលោក គ ទទួលបានវត្ថុដែលមានវិវាទដោយសុចរិត (ខសំខាន់នៃមាត្រា ១៩៣ នៃ ក្រមរដ្ឋប្បវេណី) ឬ លោក ‘គ ’ ស្ថិតក្នុងប្រភេទ "តតិយជន" ដូចរៀបរាប់ក្នុង ខ សំខាន់នៃមាត្រា ៣៩៣(២) នៃក្រមរដ្ឋប្បវេណី លោក គ អាចតតាំងសិទ្ធិរបស់គាត់តាមក្រមរដ្ឋប្បវេណី ដើម្បីបដិសេធនូវការទាមទាររបស់លោក ក ឱ្យប្រគល់វត្ថុ ។ ដូច្នេះ បើទោះបីជា លោក ‘ក ’ទទួលបាននូវរូបមន្តអនុវត្តពិសេសដែលភ្ជាប់ជាមួយនឹងសាលក្រមដែលសំរេចឱ្យគាត់ឈ្នះតាមរយៈនីតិវិធីដែលបានរៀបរាប់ក្នុងចំណុច ក ខាងលើក៏ដោយ ការអនុវត្តដោយបង្ខំមិនអាចធ្វើបានទេ ជាចុងក្រោយនៅពេល លោក ‘គ ’ ដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្ត អនុវត្តបែបនេះ ( មាត្រា ៣៦៤) ។

៣- ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់

ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ គឺមានសារសំខាន់ដើម្បីដោះស្រាយស្ថានភាពដូចជាចំណុច ២ ខ គនិង ឃ ខាងលើ ។
ទាក់ទងនឹងពាក្យសុំ ចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ តាមការអនុវត្តជាទូទៅ តុលាការចេញសេចក្ដីសម្រេចដោយគ្រាន់តែស្ដាប់មតិរបស់ម្ចាស់បំណុលប៉ុណ្ណោះ ដោយមិនកោះហៅកូនបំណុលទេ ( ប្រៀបធៀប មាត្រា ៥៣៩ មាត្រា ១១៤(១)និង(២)) ។

វិធីសាស្ត្រអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ មានចែងក្នុងមាត្រា ៥៧១-១ ។

នៅពេលគេអនុវត្ត ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបានដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ( មាត្រា ៥៧១ (២)) ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន នោះត្រូវបានធ្វើហើយ (មាត្រា ៥៧១(២) វាក្យខណ្ឌ។ ជនដែលកាន់កាប់វត្ថុ ដែលពាក់ព័ន្ធ ក្រោយពេលការអនុវត្តចាត់ចែង ជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះ ត្រូវបានធ្វើហើយ ( មាត្រា ៥៧១(៣)) ។

៤- ក្នុងករណីគំរូនេះ ក្នុងករណីការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់បានធ្វើមុនពេលដាក់ពាក្យបណ្ដឹង :

ក- ប្រសិនបើ លោក ‘គ ’ បានទទួលវត្ថុដែលមានវិវាទពីលោក ‘ខ’ ខណៈពេលដែលបណ្ដឹងរវាង ‘ក ’ និង ‘ខ ’ កំពុងចាត់ការ ( ទាក់ទងនឹងករណីទី ២ ក ខាងលើ):

ក្នុងករណីនេះ លោក ‘ក ’ អាចធ្វើការអនុវត្តដោយបង្ខំបានតាមនីតិវិធីដែលពន្យល់ក្នុងចំណុច ២ កខាងលើដោយមិនចាំបាច់ឆ្លងកាត់ផ្ទាល់ចំពោះអានុភាពនៃ ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់នោះទេ ។ (ទាក់ទងនឹងការបញ្ជាក់ភស្តុតាងដែលងាយស្រួលក្នុងការបញ្ជាក់នៅពេលផ្ដល់រូបមន្តអនុវត្តពិសេសនៅ ពេលធ្វើការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នខាងលើ សូមមើលទៅចំណុច ៥ ខាងក្រោម) ។

ខ- ប្រសិនបើ លោក គ បានទទួលវត្ថុដែលមានវិវាទពី លោក ‘ខ’ ក្រោយពេលការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ត្រូវបានធ្វើ និងមុនពេលបណ្តឹងរវាងលោក ‘ក’ និង ‘ខ’ ចូលនីតិវិធីចាត់ការ (ទាក់ទងនឹងករណី ២ ខ ខាងលើ) ។

លោក ‘ក’ អាច ធ្វើការអនុវត្តដោយបង្ខំចំពោះលោក ‘គ ’បាន ដោយផ្អែកលើមាត្រា ៥៧១(២) និង ការទទួលបាននូវរូបមន្តអនុវត្តពិសេសដែលភ្ជាប់នឹងសាលក្រមដែលកាត់ឱ្យគាត់ឈ្នះ ។ ទោះបីជា លោក គ អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តពិសេសបែបនេះក៏ដោយ ដើម្បីឈ្នះក្តីគាត់ត្រូវបញ្ជាក់ក្រោមការសន្មត់ដែលចែងក្នុងមាត្រា ៥៧១(៣)ថា គាត់មិនបានដឹងអំពីការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់នោះទេ (ឧទាហរណ៍ ការប្រកាសជាសាធារណៈ អំពីការចាត់ចែងជាបណ្តោះអាសន្ន បានបាត់បង់នៅពេលចាប់ផ្តើមកាន់កាប់) ។

គ- លោក ‘គ ’បានចាប់ផ្តើមកាន់កាប់វត្ថុដែលមានវិវាទ ក្រោយពេលការអនុវត្ត ការចាត់ចែងជាបណ្តោះអាសន្ន ហាមឃាត់ការផ្ទេរការកាន់កាប់ ដោយមិនមានទំនាក់ទំនងជាមួយនឹងលោក ខ ទេ (ទាក់ទងនឹងករណីទី ២ គ ខាងលើ) ។

លោក ‘ក’ អាចធ្វើការអនុវត្តដោយបង្ខំចំពោះ លោក ‘ខ’ ហើយនីតិវិធី គឺដូចគ្នា នឹង ចំណុច ៤ ខ ខាងលើ ។

ឃ- ករណី ក ខាងលើ បើសិនជា លោក ‘គ ’ មានសិទ្ធិតតាំងចំពោះលោក ‘ក’ (ទាក់ទងនឹងករណី ២ ឃ ខាងលើ)៖

តាមរយៈនីតិវិធីរៀបរាប់ក្នុងចំណុច ២ ក ខាងលើ លោក ‘ក’ អាចធ្វើការអនុវត្តដោយបង្ខំចំពោះលោក គ ។ ដូចចំណុច ២ ឃ ខាងលើ លោក ‘គ’ អាចដាក់ពាក្យបណ្តឹងតវ៉ា ជាអាទិ៍ ចំពោះការផ្តល់រូបមន្តអនុវត្ត ដោយតតាំងសិទ្ធិ ផ្ទាល់របស់ខ្លួនតាមក្រមរដ្ឋប្បវេណី ។ ប៉ុន្តែឆ្លងកាត់នូវការសន្មត់ដែលមានចែងក្នុងមាត្រា ៥៧១(៣) លោក ‘ក’ អាច ជួបការលំបាកក្នុងការបញ្ជាក់ថាគាត់ស្ថិតក្នុងប្រភេទ "តតិយជន" ដូចចែងក្នុង ខ សំខាន់៧នៃ មាត្រា ១៩៣ និង ៣៥៣(២) នៃក្រមរដ្ឋប្បវេណី ។

៥- នីតិវិធីផ្តល់រូបមន្តអនុវត្តពិសេស

លោក 'ក' អាចត្រូវគេផ្តល់រូបមន្តអនុវត្តពិសេស ដោយចាត់ទុកលោក 'គ' ជាកូនបំណុលនៃការអនុវត្ត បាន លុះត្រាតែ "ក្នុងករណីដែលមានភាពច្បាស់លាស់ថាអាចនឹងធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តធ្វើជាកូនបំណុលនៃការអនុវត្ត ឬ ករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ដោយលិខិតអំពីហេតុការណ៍នោះ" (មាត្រា ៣៥៦(៣)) ។

ក្នុងករណីទី២ ក ខាងលើ នៅខណៈពេលដែលលោក 'ក' ត្រូវបញ្ជាក់ថា លោក 'គ' ស្ថិតក្នុងប្រភេទ "អ្នកស្នង" ដូចចែងក្នុងមាត្រា ១៩៨ ចំណុច គ និង មាត្រា ៣៥១(១)(គ) ដែលមានន័យថា លោក 'គ' បានស្នងនូវការ កាន់កាប់បន្តពីលោក 'ខ' ជាទូទៅរឿងនេះមិនងាយស្រួលទេ ។

ផ្ទុយទៅវិញ ក្នុងករណីទី ៤ ក ដល់ ៤ឃ ខាងលើ (នៅពេល ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ត្រូវបានធ្វើ) វាគ្រប់គ្រាន់សំរាប់លោក ក ក្នុងមាត្រា ៥៧១(២)-(៣) ដើម្បីបញ្ជាក់ថា លោក 'គ' បានចាប់ផ្តើមកាន់កាប់វត្ថុដែលមានវិវាទនោះ ក្រោយពេលអនុវត្តការចាត់ចែងជាបណ្តោះអាសន្នខាងលើនេះ ។ លំអិតជាងនេះទៅទៀត លោក 'ក' អាចបញ្ជាក់ការពិតយ៉ាងងាយស្រួលថា ការចាត់ចែងជាបណ្តោះអាសន្ន ហាមឃាត់ការផ្ទេរការកាន់កាប់ ត្រូវបានគេអនុវត្ត និង លោក 'គ' មិនបានកាន់កាប់វត្ថុដែលមានវិវាទនោះទេ ក្នុងពេលអនុវត្តដោយគ្រាន់តែបង្ហាញឯកសារចំលងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន និង កំណត់ហេតុនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ។

៣៩-១.តើគេអនុវត្តការរឹបអូសជាបណ្ដោះអាសន្នលើចលនវត្ថុដោយវិធីណា?
២.ក្នុងករណីចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានផ្ទេរ និង ប្រគល់ដល់តតីយជន ហើយ តើមានវិធានការតតាំងណាខ្លះដែលយើងអាចធ្វើបាន?

១.ទាក់ទងនឹងសំនួរទី១

(១)វិធីសាស្ត្រអនុវត្ត

ក.ក្នុងករណីដែលកូនបំណុលកាន់កាប់ចលនវត្ថុដែលមានវិវាទ:

អាជ្ញាសាលាត្រូវកាន់កាប់ចលនវត្ថុនោះ (មាត្រា៥៦៥(៤) មាត្រា ៣៨៥(១)

ខ.ក្នុងករណីតតីយជនកាន់កាប់ចលនវត្ថុដែលមានវិវាទ:

ក) នៅពេលដែលតតីយជនស្មគ្រ័ចិត្តប្រគល់របស់នោះ អាជ្ញាសាលាត្រូវកាន់កាប់វាទុក ។ (មាត្រា ៥៦៥(៤), ៣៨៦ I )

ខ) នៅពេលដែលតតីយជនបដិសេធមិនព្រមប្រគល់របស់នោះ គាត់មិនអាចត្រូវគេបង្ខំឱ្យប្រគល់នោះទេ គ្មានវិធីណាក្រៅពីម្ចាស់បំណុលធ្វើការរឹបអូសជាបណ្ដោះអាសន្នលើសិទ្ធិរបស់កូនបំណុល ដើម្បីទាមទារការប្រគល់ចលនវត្ថុនោះ ។

(២) ការរក្សាទុកកម្មវត្ថុដែលរឹបអូសជាបណ្ដោះអាសន្ន

ជាគោលការណ៍អាជ្ញាសាលាជាអ្នករក្សាទុកនូវកម្មវត្ថុ ។ ប៉ុន្តែ នៅពេលណាដែលគេគិតថាសមហេតុផល អាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលរក្សាទុក និង ប្រើប្រាស់កម្មវត្ថុរឹបអូសនោះ ។ ក្នុងករណីនេះ ចាំបាច់ត្រូវបិទសញ្ញានៃការរឹបអូស ជាអាទិ៍ (មាត្រា ៥៦៥ IV, ៣៨៥ IVនិង V) ។

២.ទាកទងនឹងសំណួរទី២

សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅទីនោះ អាចបង្គាប់ឱ្យតតីយជនប្រគល់កម្មវត្ថុមានវិវាទទៅឱ្យអាជ្ញាសាលាតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៦៥ IV, ៣៩០ I) ។ អាជ្ញាសាលាអាចទទួលយកមកវិញនូវ កម្មវត្ថុដែលរឹបអូសជាបណ្ដោះអាសន្ន ក្នុងស្ថានភាពដូចគ្នានឹងករណីអនុវត្តការប្រគល់ចលនវត្ថុដូចចែងក្នុង មាត្រា ៥២៥

៤០- តើគេអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុដោយមិនកំណត់ជាក់លាក់នូវកម្មវត្ថុរឹបអូសនោះដោយវិធីណា ( មាត្រា ៥៤៦ )? ក្នុងករណីនេះ តើមានការរឹតត្បិតអ្វីខ្លះ ចំពោះកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ននោះ?

១- ទាក់ទងនឹងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុដោយមិនកំណត់ជាក់លាក់នូវកម្មវត្ថុ

មានបញ្ញត្តិចែងថា ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវចេញ ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ( មាត្រា ៥៤៦) ប៉ុន្តែក្នុងករណីចលនវត្ថុ ដោយសារក្នុងករណីខ្លះមានការលំបាកក្នុងការកំណត់ជាក់លាក់នូវកម្មវត្ថុ ក្នុងពេលចេញដីកាសម្រេច គេអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយមិនកំណត់ជាក់លាក់នូវកម្មវត្ថុនោះបាន ( មាត្រា ៥៤៦ វាក្យខណ្ឌ) ។ ក្នុងករណីបែបនេះ ខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវចែងដោយមិនកំណត់ជាក់លាក់នូវកម្មវត្ថុថា ចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលត្រូវធ្វើការរឹបអូសជាបណ្ដោះអាសន្ន។

២- ទាក់ទងនឹងការអនុវត្ត

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ( មាត្រា ៥៦៥(១)) ហើយទាក់ទងនឹងវិធីសាស្ត្រជាក់ស្ដែង បញ្ញត្តិទាក់ទងនឹងការអនុវត្តចំពោះចលនវត្ថុ ត្រូវអនុវត្តដូចគ្នាផងដែរ ( មាត្រា ៥៦៥(៤) មាត្រា ៣៨៤(២)) មាត្រា ៣៨៥ ដល់មាត្រា ៣៩២ ។ មានន័យថា ពាក្យសុំអនុវត្ត ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវរៀបរាប់ពីទីតាំងនៃចលនវត្ថុដែលត្រូវរឹបអូសនោះ ( មាត្រា ៣៨៤) ។ បន្ទាប់មក អាជ្ញាសាលាដែលគេដាក់ពាក្យសុំទៅនោះ ត្រូវកត់ត្រា ទីតាំងនោះក្នុងពាក្យសុំ ហើយត្រូវស្វែងរក និងជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន ក្នុងចំណោមចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ( មាត្រា ៣៨៥(១) ដល់ (៣)) ។

៣- ការរឹតត្បិតចំពោះការកំណត់កម្មវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន

១. អាជ្ញាសាលាអាចអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល បាន( មាត្រា ៣៨៥(១)) ហើយមិនចាំបាច់ស្រាវជ្រាវថាតើចលនវត្ថុដែលមានវិវាទនោះជាកម្មសិទ្ធិ

របស់កូនបំណុលនោះឡើយ។ ប៉ុន្តែក្នុងករណីវាបង្ហាញច្បាស់ពីលក្ខណៈខាងក្រៅនៃចលនវត្ថុនោះថា វាជាកម្មសិទ្ធិរបស់តតិយជន អាជ្ញាសាលាមិនត្រូវអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុនោះឡើយ (ប្រៀបធៀប វាលីដែលមាន ផ្លាកឈ្មោះ)

២. ដោយសារការរឹបអូសជាបណ្ដោះអាសន្ន មានគោលបំណងធានាការអនុវត្តនៅពេលអនាគតចំពោះចលនវត្ថុ ការរឹបអូសជាបណ្ដោះអាសន្ន តាមធម្មតាមិនត្រូវធ្វើចំពោះចលនវត្ថុណាដែលមានការហាមឃាត់មិនឱ្យរឹបអូសក្នុងមាត្រា ៣៨០ ឡើយ ។

៣. ក្នុងករណី ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុដែលមានវិវាទ ស្ថិតក្នុងប្រភេទនៃ "ការរឹបអូសហួសប្រមាណ" ឬ "ការរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់" ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុបែបនេះ មិនត្រូវធ្វើឡើយ (មាត្រា ៥៦៥(៤) មាត្រា ៣៩១ និង ៣៩២) ។

៤១-
តើគេអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់មិនឱ្យធ្វើសកម្មភាពណាមួយដោយវិធីណា? ឧទាហរណ៏ តើគេអនុវត្តការ ចាត់ចែងជាបណ្តោះអាសន្នក្នុងការហាមឃាត់ដូចជា ១.ការសាងសង់ និង

១.ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការសាងសង់ （នៅពេលដែលរបស់មួយត្រូវបង្កើតឡើងដែលត្រូវដកចេញដោយសារទង្វើខុសច្បាប់）
ក្នុងករណីការសាងសង់ធ្វើឡើងរំលោភបំពានលើការចាត់ចែងជាបណ្តោះអាសន្ន ផ្អែកលើដីកាចាត់ចែងជាបណ្តោះអាសន្នដែលជាលិខិតអនុវត្ត ម្ចាស់បំណុលអាចដកចេញនូវផ្នែកដែលសាងសង់រំលោភបំពាននោះ តាមមធ្យោបាយនៃការអនុវត្តជំនួសក្នុងមាត្រា ៥២៧ ។ មិនចាំបាច់ឱ្យម្ចាស់បំណុលដាក់ពាក្យសុំចាត់ចែងបណ្តោះអាសន្នម្តងទៀតទេក្នុងការសុំដកចេញនូវផ្នែកសាងសង់នោះ ។

២.ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់សំលេងរំខាន （នៅពេលដែលមិនមានវត្ថុណាមួយបង្កើតឡើង ដែលត្រូវដកចេញដោយសារទង្វើខុសច្បាប់）
នៅពេលដែលមានអំពើណាមួយរំលោភបំពានលើការចាត់ចែងជាបណ្តោះអាសន្ន កើតឡើង ផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលជាលិខិតអនុវត្ត ម្ចាស់បំណុលអាចទាមទារការបង់ប្រាក់ក្នុងចំនួនដែលគិតថាសមស្រប ដើម្បីធានាឱ្យបាននូវការផ្អាកនៃអំពើនោះតាមរយៈវិធានបង្ខំដោយប្រយោល ក្នុងមាត្រា ៥២៨ ។

៣.ការអនុវត្តដោយបង្ខំលើប្រភេទចាត់ចែងជាបណ្តោះអាសន្នទាំងនេះ មិនមានទេ លើកលែងតែកូនបំណុលប្រព្រឹត្តនូវអំពើល្មើសណាមួយ ហើយមតិទាក់ទងនឹងរយៈពេលអនុវត្តចែកចេញដូចបន្តបន្ទាប់: ១.ការកំណត់ពេលសំរាប់អនុវត្ត មិនយកមកប្រើទេ（២សប្តាហ៏: មាត្រា ៥៦២ កថាខណ្ឌ២）និង ២. រយៈពេល២សប្តាហ៏នៃការកំណត់ពេលសំរាប់អនុវត្ត យកមកប្រើចាប់ពីពេលណាដែលអំពើខុសច្បាប់ប្រព្រឹត្តឡើង ។ នៅប្រទេសជប៉ុន ទ្រឹស្តីទី១មានឧត្តមានុភាព ។

៤២- ក្នុងករណីដីកាសម្រេចចាត់ចែងរក្សាការពារត្រូវគេលុបចោលក្រោយពេលអនុវត្ត (ដោយសារ ការតវ៉ាចំពោះដីកា ការលុបចោលការចាត់ចែងរក្សាការពារ ការបង់ប្រាក់រំដោះរឹបអូសជាបណ្ដោះ អាសន្ន ។ល។) តើត្រូវចាត់នីតិវិធីអ្វីខ្លះ?

ក្នុងអត្ថបទពន្យល់នេះ " តុលាការ រ" មានន័យថា ជាតុលាការដែលបានចេញដីកាសម្រេចចាត់ចែងរក្សា ការពារ ហើយ "តុលាការ អ" មានន័យថា ជាតុលាការដែលបានចាត់ចែងការអនុវត្តចាត់ចែងរក្សាការពារ ។ តុលាការទាំងពីរនេះមានបញ្ញត្តិផ្សេងៗពីគ្នា ប៉ុន្តែតាមពិត ចៅក្រមម្នាក់តែងដើរតួនាទីក្នុងតុលាការទាំងពីរនេះ ។

នីតិវិធីលុបចោលការអនុវត្តការចាត់ចែងរក្សាការពារ មានការប្រែប្រួលទៅតាមភាពខុសគ្នានៃនីតិវិធី អនុវត្តដីកាសម្រេចនៃប្រភេទនីមួយៗនៃការចាត់ចែងរក្សាការពារ ។ សេចក្ដីសង្ខេបអំពីនីតិវិធីនីមួយៗ មានបង្ហាញជូនដូចខាងក្រោម:

១- ទាក់ទងនឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

(១) នីតិវិធីអនុវត្ត:

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដោយតុលាការ រ (មាត្រា ៥៤៥ និង ៥៤៦)

- ការផ្ដុកផ្ដាក់ដោយតុលាការ អ ឱ្យធ្វើការចុះបញ្ជីការរឹបអូស (មាត្រា ៥៦៧)

- ការចុះបញ្ជីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

(២) នីតិវិធីលុបចោលការអនុវត្តការចាត់ចែងរក្សាការពារ

កូនបំណុលដាក់ជូនតុលាការ អ នូវដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ (មាត្រា ៥៦៤ និង មាត្រា ៣៧០(១)(ក) ។

- ដីកាលុបចោលការអនុវត្តដោយតុលាការ អ ការជូនដំណឹងអំពីដីកានេះ ត្រូវធ្វើទៅកាន់ភាគីទាំងពីរ ។

- ការផ្ទុកផ្តាក់ដោយតុលាការ **អ** ឱ្យធ្វើការចុះបញ្ជីលុបចោលនូវការចុះបញ្ជីខាងលើ

* គេអាចប្តឹងជំទាស់ចំពោះដីកាលុបចោលការអនុវត្តបាន ( មាត្រា ៥៦៤ មាត្រា ៣៤៥(១)(ក))

២- ទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

(១) នីតិវិធីអនុវត្តៈ

ដីការឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដោយតុលាការ **រ** ( មាត្រា ៥៤៥ និង ៥៤៦)

- ការកាន់កាប់វត្ថុដោយអាជ្ញាសាលា ( មាត្រា ៥៦៥)

(២) នីតិវិធីលុបចោលការអនុវត្តការចាត់ចែងរក្សាការពារ

កូនបំណុលដាក់ជូនអាជ្ញាសាលានូវ ដីកាលុបចោលដីការឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ( មាត្រា ៥៦៤ មាត្រា ៣៧០ (១)(ក)) ។

- ការចាត់ចែងលុបចោលការអនុវត្តដោយអាជ្ញាសាលា ("ដីកាសម្រេច" គឺជាសេចក្តីសំរេចដែលមានតែតុលាការប៉ុណ្ណោះមានសិទ្ធិចេញ ដូច្នេះអាជ្ញាសាលាអាចគ្រាន់តែធ្វើ"ការចាត់ចែង"ប៉ុណ្ណោះ) ។
  ជាពិសេសៈ

- ក្នុងករណីដែលអាជ្ញាសាលាទុកវត្ថុៈ
  ត្រូវជូនដំណឹងអំពីការលុបចោលការរឹបអូសជាបណ្តោះអាសន្នដល់កូនបំណុល ហើយ វត្ថុត្រូវប្រគល់ទៅឱ្យកូនបំណុលនៅកន្លែងរក្សាទុកវត្ថុនោះ ។

- ក្នុងករណីកូនបំណុលទុកវត្ថុៈ
  ការជូនដំណឹងអំពីការលុបចោលការរឹបអូសជាបណ្តោះអាសន្នដល់កូនបំណុល គឺគ្រប់គ្រាន់ហើយ ។

- ក្នុងករណីម្ចាស់បំណុលទុកវត្ថុៈ

កូនបំណុលអាចទទួលមកវិញនូវវត្ថុនោះពីម្ចាស់បំណុលតាមរយៈការទទួលបាននូវដីកា សំរេចបង្គាប់ឱ្យធ្វើបដិទាននៃវត្ថុ (មាត្រា ៥៥៥) ។

* គេអាចធ្វើការតវ៉ាចំពោះការចាត់ចែងលុបចោលការអនុវត្តបាន ហើយ គេអាចធ្វើបណ្តឹងជំទាស់ចំពោះដីកាលើកចោលការតវ៉ានោះ (មាត្រា ៥៦៤ មាត្រា ៣៨៤(២) មាត្រា ៣៨៥(១)(គ)) ។

៣- ទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល

(១) នីតិវិធីអនុវត្តៈ

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដោយតុលាការ **រ** (មាត្រា ៥៤៥ និង ៥៤៦)

- ការបញ្ជូនដីកាសម្រេចដោយតុលាការ **អ** ដល់កូនបំណុល និង កូនបំណុលទី ៣ (មាត្រា ៤០៣(៧)និង(៨))

(២) នីតិវិធីលុបចោលការអនុវត្តការចាត់ចែងរក្សាការពារ

កូនបំណុលត្រូវដាក់ជូនតុលាការ **អ** នូវដីកាសម្រេចលុបចោលដីការឹបអូសជាបណ្តោះអាសន្នចំពោះ សិទ្ធិលើបំណុល (មាត្រា ៥៦៤ និង ៣៧០(១)(ក)) ។

- តុលាការ **អ** ចេញដីកាលុបចោលការអនុវត្ត និង ផ្តល់ដំណឹងអំពីដីកានេះដល់ភាគីទាំងម្ចាស់បំណុល និង កូនបំណុល ព្រមទាំងជូនដំណឹងអំពីដីកានេះ និង អំពីការរឹបអូសជាបណ្តោះអាសន្នដែលបាត់បង់អានុភាពដល់កូនបំណុលទី ៣ ។

* គេអាចធ្វើបណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោលការអនុវត្ត (មាត្រា ៥៦៤ និង មាត្រា ៣៨៥(១)(ក)) ។

៤- ទាក់ទងនឹងការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងអចលនវត្ថុ

(១) នីតិវិធីអនុវត្តៈ

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងដោយតុលាការ ** វ**

- ការផ្ទុកផ្តាក់ដោយតុលាការ **អ** អំពីការចុះបញ្ជី

- ការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង

(២) នីតិវិធីលុបចោលការចាត់ចែងរក្សាការពារ

កូនបំណុលដាក់ជូនតុលាការ **អ** នូវដីកាលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង (មាត្រា ៥៦៤ និង មាត្រា ៣៧០(១)(ក)) ។

- ដីកាសម្រេចលុបចោលការអនុវត្តដោយតុលាការ **អ** ត្រូវជូនដំណឹងដល់ភាគីទាំងពីរ ។

- ការផ្ទុកផ្តាក់ដោយតុលាការ **អ** ឱ្យលុបចោលនូវការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នខាងលើ ។

* គេអាចប្តឹងជំទាស់ចំពោះដីកាលុបចោលការអនុវត្តបាន (មាត្រា ៥៦៤ និង ៣៤៥(១)(ក)) ។

៥- ទាក់ទងនឹង ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់

(១) នីតិវិធីអនុវត្តៈ

ដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់ដោយតុលាការ **វ**

- ការកាន់កាប់វត្ថុ និងប្រកាសជាសាធារណៈអំពីដីកានោះ ដោយអាជ្ញាសាលា (មាត្រា ៥៧១)

(២) នីតិវិធីលុបចោលការអនុវត្តការចាត់ចែងរក្សាការពារ

កូនបំណុលដាក់ជូនចំពោះអាជ្ញាសាលា នូវដីកាសម្រេចលុបចោលដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ។

- ការលុបចោលការអនុវត្តដោយអាជ្ញាសាលា ជាពិសេសៈ
  * ក្នុងករណីដែលអាជ្ញាសាលារក្សាទុកវត្ថុៈ

ត្រូវជូនដំណឹងអំពីការលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដល់កូនបំណុល ហើយវត្ថុត្រូវប្រគល់ទៅអោយកូនបំណុល ។

* ក្នុងករណីដែលកូនបំណុលរក្សាទុកវត្ថុ

ត្រូវជូនដំណឹងអំពីការលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដល់កូនបំណុល ។

* ក្នុងករណីដែលម្ចាស់បំណុលរក្សាទុកវត្ថុ

កូនបំណុលអាចយកវត្ថុពីម្ចាស់បំណុលវិញ តាមការទទួលបាននូវដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាននៃវត្ថុ (មាត្រា ៥៥៥) ។

៦- ទាក់ទងនឹងការចាត់ចែងជាបណ្ដោះអាសន្នបង្គាប់ឱ្យបង់ប្រាក់ និងប្រគល់ជាបណ្ដោះអាសន្ន

(១) នីតិវិធីអនុវត្តៈ

ការចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ឱ្យបង់ប្រាក់ជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមនីតិវិធីអនុវត្តសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ (ខាងក្រោយយើងប្រើពាក្យ "ការអនុវត្តជាប្រាក់") ។ ការអនុវត្តចំពោះអចលនវត្ថុ ឬសិទ្ធិលើបំណុល ត្រូវធ្វើដោយតុលាការ **អ** (មាត្រា ៤០២ និង ៤១៨) ហើយការអនុវត្តចំពោះចលនវត្ថុ ត្រូវធ្វើដោយ អាជ្ញាសាលា (មាត្រា ៣៨៤) ។

ការអនុវត្តការចាត់ចែងឱ្យប្រគល់ ត្រូវធ្វើដោយអាជ្ញាសាលាតាមរយៈនីតិវិធីអនុវត្តការប្រគល់ (មាត្រា ៥២៤ និង ៥២៥)

(២) នីតិវិធីលុបចោលការអនុវត្តចាត់ចែងរក្សាការពារ

ក្នុងប្រភេទទាំងពីរយ៉ាងនៃចាត់ចែងរក្សាការពារ នៅពេលនីតិវិធីអនុវត្តចប់ហើយ (ឧទាហរណ៍ នៅពេលគេធ្វើការប្រគល់ហើយ) នីតិវិធីនេះ មិនត្រូវធ្វើជាកម្មវត្ថុនៃការលុបចោលទៀតទេ ។ ក្នុងករណីនេះ កូនបំណុលអាចទទួលមកវិញនូវប្រាក់ដែលបានបង់ ឬវត្ថុពីម្ចាស់បំណុល តាមរយៈការទទួលបាននូវដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាននៃវត្ថុ (មាត្រា ៥៥៥) ។

នៅពេលនីតិវិធីអនុវត្តកំពុងធ្វើ នីតិវិធីលុបចោលការអនុវត្តត្រូវចាត់ការតាមមាត្រា ៥៦៤ និង ៣៧០(១)(ក)) ។

៧- ទាក់ទងនឹងការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការសាងសង់ជាអាទិ៍

(១) នីតិវិធីអនុវត្ត (ប្រៀបធៀបសំណួរ ៤២)

ទោះបីជាតុលាការ 'វ' បញ្ជូនដីកាសម្រេច ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការសាងសង់ដល់កូនបំណុលក៏ដោយ ដូចការហាមឃាត់នូវអំពើមួយដែរ ការអនុវត្តការចាត់ចែងរក្សាការពារមិនអាចធ្វើបានទេ លុះត្រាតែមានអំពើរំលោភច្បាប់កើតឡើង ។

ក្នុងករណីមានអំពើរំលោភច្បាប់ត្រូវបានធ្វើឡើង មានន័យថាការសាងសង់បានធ្វើហើយ ម្ចាស់បំណុលអាចដាក់ពាក្យសុំអនុវត្តជំនួសទាមទារការបំបាត់ចោលនូវផ្នែកដែលសាងសង់ និង ទទួលនូវដីកាសម្រេចដូចចែងក្នុងមាត្រា ៥២៧(១)(និង អាចទទួលបានដីកាសម្រេចដែលចែងក្នុងមាទ្រា ៥២៧(៤) ផងដែរ) ។ ក្នុងករណីដែលវិធានការខាងលើមិនគ្រប់គ្រាន់ក្នុងការរារាំងការបន្តនូវការសាងសង់ គេអាចប្រើវិធីអនុវត្តបង្ខំដោយប្រយោល ។ ក្នុងករណីនេះ ការចាត់ចែងជាបណ្ដោះអាសន្នត្រូវធ្វើតាមរយៈនីតិវិធីអនុវត្តជាប្រាក់តាមរយៈការទទួលនូវដីកាដែលចែងក្នុងមាត្រា ៥២៨(១) ។

(២) នីតិវិធីលុបចោលការអនុវត្តការចាត់ចែងរក្សាការពារ

ក-ក្នុងករណីមិនបានធ្វើការអនុវត្ត ក្រៅអំពីជូនដំណឹងអំពី ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការសាងសង់ដល់កូនបំណុលៈ

ដោយសារនីតិវិធីអនុវត្តការចាត់ចែងរក្សាការពារមិនទាន់ចាប់ផ្ដើម គេមិនអាចលុបចោលការអនុវត្តបាន ទេ ។

ខ- ក្នុងករណីការអនុវត្តជំនួសបានធ្វើ:

-ប្រសិនបើការអនុវត្តជំនួសបានបញ្ចប់ហើយ ការចាត់ចែងរក្សាការពារមិនត្រូវធ្វើជាកម្មវត្ថុនៃការលុបចោលការអនុវត្តទេ ហើយកូនបំណុលមិនមានជំរើសអ្វីក្រៅពីទាមទារសំណងពីម្ចាស់បំណុលឡើយ (ប្រៀបធៀបសំណួរទី១៨) ។

-ប្រសិនបើការអនុវត្តជំនួសកំពុងធ្វើ:

នៅពេលកូនបំណុលដាក់ជូនទៅតុលាការ **អ** នូវដីកាសំរេចលុបចោលការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការសាងសង់ តុលាការ **អ** ត្រូវចេញដីកាសំរេចលុបចោលដីកាដែលចែងក្នុងមាត្រា ៥២៧(១) (និងដីកាដែលមានក្នុង មាត្រា ៥២៧(៤) បើសិនជាចេញដីកានោះ) ហើយជូនដំណឹងដល់ភាគីទាំងពីរផង (មាត្រា ៥៦៤ និង ៣៧០(១)) ។

គ- ក្នុងករណីនីតិវិធីអនុវត្តបង្ខំដោយប្រយោលបានធ្វើ:

នៅពេលកូនបំណុលដាក់ជូនចំពោះតុលាការ **អ** នូវដីកាសំរេចលុបចោលដីកាសំរេចចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការសាងសង់តុលាការ **អ** ត្រូវចេញដីកាសំរេចលុបចោលដីកាដែលចែងក្នុងមាត្រា ៥២៨(១) និងជូនដំណឹងអំពីដីកានេះដល់ភាគីទាំងពីរផង ។

បើសិនជាការអនុវត្តជាប្រាក់ កំពុងប្រព្រឹត្តទៅ ដោយផ្អែកលើដីកាដែលចែងក្នុងមាត្រា ៥២៨(១) កូនបំណុលដាក់ជូននូវដីកាលុបចោលការចាត់ចែងជាបណ្ដោះអាសន្នខាងលើ ហើយតុលាការ **អ** ត្រូវចាត់នីតិវិធីលុបចោលការអនុវត្តជាប្រាក់នោះ ។

| |
|---|
| ៤៣- ក្រោយពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទាក់ទងនឹងកម្មវត្ថុហើយ តតីយជន X ម្នាក់ បានបង្ហាញខ្លួនដោយអះអាងអំពីកម្មសិទ្ធិរបស់គាត់លើកម្មវត្ថុនោះ តើតតីយជនរូបនោះអាចចាត់វិធានការដូចម្ដេចខ្លះ ដើម្បីដកអានុភាពនៃការរឹបអូសជា បណ្ដោះអាសន្ន? |

តតិយជន X អាចធ្វើបណ្ដឹងតវ៉ាចំពោះម្ចាស់បំណុល ( មាត្រា ៥៦៤ និង ៣៦៥) ។ នីតិវិធីរក្សាការពារ ចែកជាដំណាក់កាល ទី១ ចេញដីការក្សាការពារ និង ទី២ អនុវត្តនូវដីការរក្សាការពារ ។ លោក X អាចទទួលរងនូវការខូចខាត តែនៅពេលណាដែលគេអនុវត្តដីកានោះនៅដំណាក់កាលទី២ប៉ុណ្ណោះ ពីព្រោះនៅដំណាក់កាលទីមួយដីកាមានអានុភាពតែចំពោះម្ចាស់បំណុលនិងកូនបំណុលតែប៉ុណ្ណោះ ។ ដូច្នេះ មានតែការផ្ដល់នូវនីតិវិធីតវ៉ានឹងការអនុវត្តដីការក្សាការពារនៅដំណាក់កាលទី២ ប៉ុណ្ណោះ វាអាចគ្រប់គ្រាន់សំរាប់លោក X។ ដើម្បីកុំឱ្យយឺតពេល លោក X អាចដាក់ពាក្យបណ្ដឹងតវ៉ាមុនពេលគេអនុវត្តដីការក្សាការពារ នៅពេលនោះកម្មវត្ថុមានការកំណត់ច្បាស់លាស់ ក្នុងដីការក្សាការពារ ។ នៅពេលធ្វើដូច្នេះ លោក X អាចសុំឱ្យវិនិច្ឆ័យពីការផ្អាកអនុវត្ត ( ៥៦៤ និង ៣៦៧)

ប្រសិនបើទទួលស្គាល់ការទាមទាររបស់ លោក X ខ្លឹមសារនៃសាលក្រមសម្រេច គួរចែងដូចតទៅៈ"ហេតុនេះតុលាការមិនអនុញ្ញាតឱ្យអនុវត្តការចាត់ចែងរក្សាការពារឡើយលើ( កម្មវត្ថុ)ដែលចែងនៅក្នុងដីការក្សាការពារ ។" នៅពេល សាលក្រមនេះដាក់ជូនចំពោះតុលាការអនុវត្ត ការអនុវត្តនឹងត្រូវផ្អាក ហើយការចាត់ចែងដែលបានអនុវត្តរួចហើយ ត្រូវលប់ចោលវិញ ( ៥៦៤ និង ៣៧០ ( ១)( ខ)) ។

៤៤- សូមពន្យល់ នៅពេលប្រាក់រំដោះ បានបង់ហើយ តើយើងគិតដូចម្ដេចចំពោះការផ្អាក ការអនុវត្ត?

មាត្រា ៥៦៩(១)ចែងថា"នៅពេលកូនបំណុលបង់ប្រាក់ជូនតុលាការតាមចំនួនកំណត់ក្នុងមាត្រា ៥៤៧ ហើយតុលាការត្រូវលុបចោលការអនុវត្តរឹបអូសបណ្តោះអាសន្ន" ។ និយាយម្យ៉ាងទៀត មាត្រា ៥៦៩ មិនបានចែងអំពីការផ្អាកការអនុវត្តឡើយ ។

មូលហេតុមាត្រា ៥៦៩(១) និយាយតែអំពីការលុបចោលការអនុវត្ត ហើយមិននិយាយអំពីការផ្អាកការអនុវត្តនោះ គឺថាការផ្អាកការអនុវត្តមិនចាំបាច់ក្នុងស្ថានភាពនេះទេ ។

ករណីពាក្យសុំឱ្យអនុវត្តត្រូវបានដាក់ក្រោយពេលដីកាសម្រេចលុបចោលការអនុវត្តផ្អែកលើមាត្រា ៥៦៩(១) តុលាការត្រូវលើកចោលពាក្យសុំអនុវត្តនោះ។ ករណីពាក្យសុំឱ្យអនុវត្តត្រូវបានដាក់មុនពេលដីកាសម្រេចលុបចោលការអនុវត្តផ្អែកលើ មាត្រា ៥៦៩(១)(មានន័យថាករណីការអនុវត្តបានចាប់ផ្តើមហើយ មុនពេលដីកាសម្រេចលុបចោលការអនុវត្ត) តុលាការត្រូវលុបចោលការអនុវត្តដែលបានធ្វើរួចហើយនោះ ។
ដូច្នេះដីកាសម្រេចលុបចោលការអនុវត្ត គឺគ្រប់គ្រាន់ចំពោះម្ចាស់បំណុល ហើយដីកាសម្រេចផ្អាកការអនុវត្តមិនចាំបាច់ចំពោះម្ចាស់បំណុលទេ ។

មូលហេតុមួយទៀត គឺថា ដីកាសម្រេចផ្អាកការអនុវត្តអាចមានបង្កឱ្យមានការលំបាកក្នុងស្ថានភាពនេះ ។ បើសិនជាតុលាការចេញដីកាសម្រេចផ្អាកការអនុវត្ត ប៉ុន្តែម្ចាស់បំណុលដាក់ឯកសារចំលងយថាភូតនៃដីកានោះទៅស្ថាប័នអនុវត្តតាមមាត្រា ៣៧០(១) ចំណុច ឆ ក្រោយពេលការចាប់ផ្តើមអនុវត្ត ម្ចាស់បំណុលមិនអាចសុំការលុបចោលការអនុវត្តតាមដីកាផ្អាកការអនុវត្តនេះទេ ហើយម្ចាស់បំណុលត្រូវរកដីកាសម្រេចមួយទៀត ដែលជាដីកាលុបចោលការអនុវត្ត ដើម្បីលុបចោលការអនុវត្តដែលបានធ្វើហើយ ។

តាមការសន្និដ្ឋាន នៅពេលប្រាក់រំដោះបានបង់ហើយ ដីកាសម្រេចដែលតុលាការចេញ មិនមែនជាដីកាសម្រេចផ្អាកការអនុវត្តទេ ប៉ុន្តែជាដីកាសម្រេចលុបចោលការអនុវត្ត ។

# ប្រភេទនៃការរក្សាការពារ

| ប្រភេទនៃការរក្សាការពារ | ប្រភេទនៃការរក្សាការពារ | សិទ្ធិដែលត្រូវបានរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច គ) | ភាពចាំបាច់ដែលត្រូវរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ឃ) |
|---|---|---|---|
| **ការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៣១ ចំណុច ក)** | ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ | សិទ្ធិលើបំណុលដែលទាមទារឱ្យសងប្រាក់ ( មាត្រា ៥៤៥ កថាខណ្ឌទី១) | មានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តដោយបង្ខំ ( មាត្រា ៥៤៥ កថាខណ្ឌទី១) |
| | ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះចលនវត្ថុ | | |
| | ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើ បំណុល | | |
| **ការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រា ៥៣១ ចំណុច ខ)** | ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរ ការកាន់កាប់ | សិទ្ធិលើបំណុលដែលទាមទារឱ្យប្រគល់ នូវវត្ថុដែលជាកម្មវត្ថុនៃ វិវាទ | មានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ( មាត្រា ៥៤៨ កថាខណ្ឌទី១) |
| **ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ ឋានៈជាបណ្ដោះអាសន្ន (មាត្រា ៥៣១ ចំណុច គ)** | ការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន | សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលមានវិវាទ | ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាត ធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើត ឡើងដល់ម្ចាស់ បំណុល ចំពោះទំនាក់ទំនងគតិយុត្ត ដែលមានវិវាទ ( មាត្រា ៥៤៨ កថាខណ្ឌទី២) |

| ប្រភេទនៃការរក្សារការពារ | វិធីចេញដីកាសម្រេច | | វិធីអនុវត្តដីកាសម្រេច | អានុភាពនៃការអនុវត្ត | ទំនាក់ទំនងទៅនឹងការអនុវត្ត ដោយបង្ខំ |
|---|---|---|---|---|---|
| **ការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៣១ ចំណុច ក)** | តុលាការត្រូវ កំណត់ អំពីចំនួនទឹកប្រាក់រំដោះ ពិការរឹបអូសជាបណ្ដោះអាសន្ន ( មាត្រ ៥៤៧) | | តាមរបៀបចុះបញ្ជី អំពីការរឹបអូសជាបណ្ដោះអាសន្ន ( មាត្រា ៥៦៧ កថាខណ្ឌ ទី១) | ការចាត់ចែងទ្រព្យសម្បត្តិ ចំពោះការរឹបអូសជាបណ្ដោះអាសន្នគ្មានអានុភាពឡើយ ចំពោះនីតិវិធីនៃការអនុវត្ត ដោយបង្ខំ | ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដើម្បីចាប់ផ្ដើមអនុវត្តនីតិវិធីនៃការអនុវត្ត ដោយបង្ខំ |
| | | តុលាការមិនចាំបាច់កំណត់ជាក់លាក់អំពីកម្មវត្ថុ ( មាត្រា ៥៤៦) | នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ត្រូវសរសេរអំពី ទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះស្ថិតនៅ ។ ( មាត្រា ៥៦៥ កថាខណ្ឌ ទី៤ មាត្រា ៣៨៤ កថាខណ្ឌទី២) ។<br>ទាមរបៀបកាន់កាប់ វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលា ( មាត្រា ៥៦៥ កថាខណ្ឌទី១) | ការចាត់ចែងទ្រព្យសម្បត្តិ ចំពោះការរឹបអូសជាបណ្ដោះអាសន្នគ្មានអានុភាពឡើយ ចំពោះនីតិវិធីនៃការអនុវត្ត ដោយបង្ខំ | |
| | | | តាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូន បំណុលទីពាសងទៅកូនបំណុល ( មាត្រា ៥៦៦ កថាខណ្ឌទី១) | ការចាត់ចែងទ្រព្យសម្បត្តិ ចំពោះការរឹបអូសជាបណ្ដោះអាសន្នគ្មានអនុភាពឡើយ ចំពោះនីតិវិធីនៃការអនុវត្ត ដោយបង្ខំ | |
| **ការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រា ៥៣១ ចំណុច ខ)** | ដីកាសម្រេចហាមឃាត់មិនឱ្យធ្វើការផ្ទេរការកាន់កាប់វត្ថុ និងបង្គាប់ឱ្យប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការ កាន់កាប់នោះ ហើយ បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ និង បង្គាប់ឱ្យអាជ្ញា សាលាត្រូវប្រកាសជា សាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ ការផ្ទេរការកាន់កាប់វត្ថុនោះ ( មាត្រា ៥៧១ កថាខណ្ឌទី១) | | តាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលាចំពោះកម្មវត្ថុ ជាដើម ( មាត្រា ៥៧១) | ការផ្ទេរការកាន់កាប់ ចំពោះការចាត់ចែងជាបណ្ដោះអាសន្នគ្មានអានុភាពឡើយ ចំពោះ នីតិវិធីនៃការអនុវត្តដោយបង្ខំទេ ដូចេះកូនបំណុលនៃការអនុវត្តត្រូវបានចង ( មាត្រា ៥៧១) | ការអនុវត្ត ដោយបង្ខំអាចអនុវត្ត ចំពោះបុគ្គល ផ្សេងក្រៅពីភាគីដែលត្រូវបានសរសេរលើ លិខិត អនុវត្ត ដោយមានរូបមន្តអនុវត្តពិសេស ( មាត្រា ៥៦៤ មាត្រា ៣៥៦ កថាខណ្ឌទី២) |
| **ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ ឋានៈជាបណ្ដោះអាសន្ន (មាត្រា ៥៣១ ចំណុច គ)** | ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នមិនអាចចេញបានឡើយ បើមិន បានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយ ផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូល រួមបាន មាត្រា ៥៤៨ កថាខណ្ឌទី៤ ។<br>ប៉ុន្តែ ករណីលើកលែងគឺ មាត្រា ៥៤៨ កថាខណ្ឌទី៤ វាក្យខណ្ឌ | | តាមរបៀបដូចគ្នាទៅនឹងរបៀបនៃការអនុវត្ត ដោយបង្ខំ ដោយ ផ្អែកលើ សាលក្រមនៃបណ្ដឹងអង្គសេចក្ដី | កំណត់ឋានៈជាបណ្ដោះអាសន្ន លក្ខ័ខណ្ឌ ឬសិទ្ធិ ហើយម្ចាស់បំណុលអាចទទួលនូវការពេញចិត្តជាបណ្ដោះអាសន្ន | អ្នកមិនចាំបាច់អនុវត្តដោយបង្ខំ ដែលត្រូវបានធ្វើនៅក្នុងការអនុវត្តនៃការចាត់ចែងជាបណ្ដោះអាសន្នទេ |

# ប្រាតភោគ និង ប្រាក់រំដោះពីការរើបអូសជាបណ្តោះអាសន្ន

| | គោលបំណង | អ្នកដាក់ប្រាតិភោគ | ប្រភេទនៃរឿងក្តី | ការសម្រេចសេចក្តី (ត្រូវតែធ្វើ)? | ចំនួនទឹកប្រាក់ដែលត្រូវដាក់ |
|---|---|---|---|---|---|
| ប្រាតិភោគ (មាត្រា ៥៤២) | ដើម្បីធានានូវសំណងនៃការខូចខាតដែលកើតមានឡើងចំពោះ កូនបំណុល ដោយសារកំហុសដីកាសម្រេ រក្សាការពារ សូមមើលគូឡោនប្រអប់ចុងក្រោយនៅក្នុងជួរនេះ | ម្ចាស់បំណុល | ទាំងអស់<br>(-ការរើបអូសជាបណ្តោះ អាសន្ន។<br>- ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ។<br>- ឬ ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន) | ការសម្រេចសេចក្តី<br>ដីកាសម្រេចអាចធ្វើ ដោយ***អោយដាក់***ប្រាតិភោគ ឬ***មិនអោយដាក់***ប្រាតិភោគ (មាត្រា ៥៤២) | តុលាការគប្បីធ្វើការប៉ាន់ស្មាន អំពីចំនួនទឹកប្រាក់នៃការខូចខាត។<br>ចំណុចខាងក្រោម គប្បីយកមកពិចារណា<br>- ប្រភេទ និង ចំនួនទឹកប្រាក់នៃសិទ្ធិដែលត្រូវបានរក្សាការពារ<br>- ប្រភេទនៃការរក្សាការពារ<br>- ប្រភេទ និង ចំនួនទឹកប្រាក់នៃកម្មវត្ថុដែលត្រូវរក្សាការពារ<br>- មុខរបរ និងស្ថានភាពសេដ្ឋកិច្ចរបស់កូនបំណុល<br>- កម្រិតនៃការធ្វើសេចក្តីបញ្ជាក់តំបូង |
| *ទឹកប្រាក់រំដោះពីការរើបអូសជាបណ្តោះអាសន្ន (មាត្រា ៥៤៧)* | ដើម្បីទទួលបាននូវទ្រព្យដែលត្រូវរួចផុតពីការរើបអូសជាបណ្តោះអាសន្ន<br>ជំនួសទ្រព្យដែលត្រូវរើបអូស | កូនបំណុល | មានតែចំពោះករណីនៃការរើបអូសជាបណ្តោះអាសន្នប៉ុណ្ណោះ | ត្រូវតែកំណត់<br>តុលាការ***ត្រូវ***កំណត់ចំនួនទឹកប្រាក់នៅក្នុងដីកាសម្រេច (មាត្រា ៥៤៧) | ចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិដែលត្រូវបានរើបអូសជាបណ្តោះ អាសន្ន ឬ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ |

| | ពេលវេលាដែលបង្គាប់អោយដាក់ប្រាតិទោត | ប្រាតិទោតដែលត្រូវដាក់ | តុលាការដែលត្រូវដាក់ប្រាតិទោត | អានុភាពនៃការដាក់ប្រាតិទោត | ករណីដែលអ្នកដាក់ប្រាតិទោតអាចទាមទារ *អោយប្រគល់* ប្រាតិទោតត្រឡប់មកវិញ | **ករណីអ្នកទទួលផលប្រយោជន៍ពីប្រាតិទោតអាចទាមទារ *អោយប្រគល់* ប្រាតិទោតត្រឡប់មកវិញ** |
|---|---|---|---|---|---|---|
| ប្រាតិភោគ (មាត្រា ៥៤២) | តុលាការអាចបង្គាប់អោយដាក់ប្រាតិភោគមុនចេញដីកាសម្រេចរក្សាការពារ ឬ បង្គាប់អោយដាក់ នៅក្នុងដីកាសម្រេចរក្សាការពារតែម្តង (ជាលក្ខខណ្ឌមួយដើម្បីអនុវត្តដីកាសម្រេច) | ប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន | តុលាការដែលបង្គាប់អោយដាក់ប្រាតិភោគ ឬ តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៣៦) | តុលាការត្រូវចេញដីកាសម្រេច និង អនុវត្តដីកាសម្រេច | ហេតុដែលត្រូវដាក់ប្រាតិភោគត្រូវបានរលត់ (មាត្រា ៧៣ កថាខណ្ឌទី២)<br>ឧទាហរណ៍ ម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី<br><br>ម្ចាស់បំណុលបានទទួលការយល់ព្រម ពីកូនបំណុល (មាត្រា ៧៣ កថាខណ្ឌទី៣)<br>កូនបំណុលមិនបានប្រើសិទ្ធិក្នុងអំឡុង ពេល ២សប្តាហ៍ (មាត្រា ៧៣ កថាខណ្ឌទី៤) | ក្នុងករណីកូនបំណុលទទួលនូវការខូចខាតដែលបណ្តាលមកពីកំហុសនៃដីកាសម្រេច កូនបំណុលអាចដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតពីម្ចាស់បំណុលបាន។ ហើយក្នុងករណីដែលកូនបំណុលឈ្នះក្តី ហើយសាលក្រមបានចូលជាស្ថាពរ កូនបំណុលអាចទទួលការពេញចិត្ត ដោយខ្លួនមានសិទ្ធិ ជាអាទិភាពទៅលើ ម្ចាស់បំណុលផ្សេងទៀត យោងតាមមាត្រា ៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| ទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៤៧) | នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន | ប្រាក់រំដោះ (មាត្រា ៥៤៧) | តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៤៧ កថាខណ្ឌទី២) | តុលាការត្រូវលុបចោលការអនុវត្ត ការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៦៩ កថាខណ្ឌទី១) | ម្ចាស់បំណុលដកពាក្យសុំអោយចេញដីកាសម្រេចរឹបអូសជាបណ្តោះ អាសន្ន ឬ ដកពាក្យសុំអោយអនុវត្តដីកាសម្រេច។<br>ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោល ដោយយោងតាម ពាក្យសុំតវ៉ា (មាត្រា ៥៥០) ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ (មាត្រា ៥៥៧ ៥៥៨ និង មាត្រា ៥៥៩) ឬ បណ្តឹងជំទាស់ (មាត្រា ៥៦១) | ក្នុងករណីម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី ហើយសាលក្រមបានចូល ជាស្ថាពរ ម្ចាស់បំណុលអាចរឹបអូសសិទ្ធិលើបំណុល ដើម្បីយកប្រាក់ដែលបានដាក់ប្រាតិភោគនោះត្រឡប់មកវិញ ដោយផ្អែកលើ សាលក្រមចុងក្រោយ គឺថា ជាលិខិតអនុវត្ត (មាត្រា ៣៥០ និង មាត្រា៤០២) ។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលទទួលនូវការពេញចិត្ត តាមរបៀបនៃការអនុវត្តចំពោះ សិទ្ធិលើបំណុល (មាត្រា ៤០២)។ |

## បណ្តឹងតវ៉ា និង បណ្តឹងជំទាស់ ជាអាទិ៍

| | កម្មវត្ថុ | អ្នកដែលដាក់ពាក្យសុំ | មូលហេតុនៃការដាក់ពាក្យសុំ |
|---|---|---|---|
| *ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (មាត្រា ៥៥០)* | ដីកាសម្រេចរក្សាការពារ<br>x ដីកាសម្រេចលើកចោលពាក្យសុំ<br>ដីកាសម្រេចរក្សាការពារ | កូនបំណុល | ដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវ |
| *បណ្តឹងជំទាស់ ចំពោះ សេក្តីសម្រេចដែលលើកចោលពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ* (មាត្រា ៥៤២) | ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារ (មាត្រា ៥៤៩) | ម្ចាស់បំណុល | ដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវ |
| *ការលុបចោលដីកាសម្រេចរក្សាការពារ (មាត្រា ៥៥៧ ៥៥៨ និងមាត្រា ៥៥៩)* | ដីកាសម្រេចរក្សាការពារ<br>x ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារ | កូនបំណុល | ដីកាសម្រេចគឺត្រឹមត្រូវ ប៉ុន្តែស្ថានភាពបានផ្លាស់ប្តូរ បន្ទាប់ពីចេញដីកាសម្រេចរក្សាការពារនោះ |
| *បណ្តឹងជំទាស់ (មាត្រា ៥៦១)* | ដីកាសម្រេចដែលទាក់ទងនឹងពាក្យសុំតវ៉ា ឬពាក្យសុំលុបចោលដីកាសម្រេច ជាអាទិ៍ (មាត្រា៥៦១) | ម្ចាស់បំណុល ឬ កូនបំណុល | ដីកាសម្រេចមិនត្រឹមត្រូវ |

| | តុលាការដោះស្រាយបណ្តឹង | នីតិវិធី | តើភាគីអាចដាក់បណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ចំពោះដីកាសម្រេចម្តងទៀតបានដែរឬទេ? |
|---|---|---|---|
| *ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (មាត្រា ៥៥០)* | តុលាការដែលចេញដីកាសម្រេចដើម (មាត្រា ៥៥០) | តុលាការត្រូវធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ ឬ ធ្វើការសួរភាគីទាំងសងខាងដែលអាចចូលរួមបាន (មាត្រា ៥៥២)<br>តុលាការត្រូវសម្រេចថ្ងៃ បញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៥៣) | បាន (មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច ក)<br>ករណីលើកលែង: ដីកាសម្រេចអំពី ពាក្យសុំតវ៉ា ដែលធ្វើឡើង ដោយតុលាការនៃបណ្តឹងជំទាស់ (មាត្រា ៥៦១ កថាខណ្ឌទី១ វាក្យខណ្ឌ) |
| *បណ្តឹងជំទាស់ ចំពោះ សេចក្តីសម្រេចដែលលើកចោលពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ (មាត្រា ៥៤៤)* | តុលាការនៃបណ្តឹងជំទាស់ | ដូចនីតិវិធីដែលដីកាសម្រេចដើមត្រូវបានចេញ (មាត្រា ៣០៤ កថាខណ្ឌទី១ មាត្រា ២៧៣)<br>ការសួរភាគី (មាត្រា ១១៤ កថាខណ្ឌទី២) ការសម្រេចសេចក្តីចំពោះ នីតិវិធីការរក្សាការពារ (មាត្រា ៥៣៥ កថាខណ្ឌ ទី១ មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌ) | ទេ (មាត្រា ២៥៩ កថាខណ្ឌទី៣)<br>ប៉ុន្តែមានករណីលើកលែងមួយចំនួន សូមមើលនៅក្នុងតារាង |
| *ការលុបចោលដីកាសម្រេចរក្សាការពារ (មាត្រា ៥៥៧ ៥៥៨ និងមាត្រា ៥៥៩)* | តុលាការដែលចេញដីកាសម្រេចដើម (មាត្រា ៥៥៧ មាត្រា ៥៥៨ មាត្រា ៥៥៩) ឬ<br>តុលាការធ្វើការវិនិច្ឆ័យលើ បណ្តឹងអង្គសេចក្តី (មាត្រា ៥៥៨ មាត្រា៥៥៩) | តុលាការត្រូវធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ ឬ ធ្វើការសួរភាគី ទាំងសង ខាងដែលអាចចូលរួម បាន (មាត្រា ៥៦០ មាត្រា ៥៥២)<br>តុលាការត្រូវសម្រេចថ្ងៃ បញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៦០ មាត្រា ៥៥៣) | បាន (មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច ក) |
| *បណ្តឹងជំទាស់ (មាត្រា ៥៦១)* | តុលាការនៃបណ្តឹងជំទាស់ | តុលាការត្រូវធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ ឬ ធ្វើការសួរភាគីទាំងសង ខាងដែលអាចចូលរួម បាន (មាត្រា ៥៦១ កថាខណ្ឌទី៣ មាត្រា ៥៥២)។<br>តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៦១ កថាខណ្ឌទី៣ មាត្រា ៥៥៣) | ទេ (មាត្រា ២៥៩ កថាខណ្ឌទី៣)<br>ប៉ុន្តែមានករណីលើកលែងមួយចំនួន សូមមើលនៅក្នុងតារាង |

# លំហូរនីតិវិធីនៃពាក្យសុំខ្ចាស្រ័យចំពោះការចាត់ចែងរក្សាការពារ

កម្រិតតែករណីដែលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារត្រូវបានដាក់ទៅសាលាដំបូង
មិនរាប់បញ្ចូលនីតិវិធីនៃការលុបចោលដីកាសម្រេចរក្សាការពារ ( មាត្រា ៥៥៧ ដល់ មាត្រា ៥៦០)

